សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences Économiques

Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# នីតិវិធីនៃការចុះបញ្ជីអត្រានុកូលដ្ឋាន

ស្រាវជ្រាវចាប់ពីថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៣ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៣

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ កញ្ញា **ឆន ស្រីពេជ្រ**

ណែនាំដោយ

លោក **ម៉ៅ បុណ្ណា**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី២៨ (អាហារូបករណ៍)

ឆ្នាំចូលសិក្សា ២០១៩

ឆ្នាំសរសេរសារណា ២០២៣

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**
**Université Royale de Droit et des Sciences Économiques**
**Royal University of Law and Economics**

# សារណាបញ្ចប់ការសិក្សា

# នីតិវិធីនៃការចុះបញ្ជីអត្រានុកូលដ្ឋាន

ស្រាវជ្រាវចាប់ពីថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៣ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៣

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ កញ្ញា **ឆន ស្រីពេជ្រ**

ណែនាំដោយ
លោក **ម៉ៅ បុណ្ណា**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី២៨ (អាហារូបករណ៍)

ឆ្នាំចូលសិក្សា ២០១៩
ឆ្នាំសរសេរសារណា ២០២៣

# សេចក្តីថ្លែងអំណរគុណ

នាងខ្ញុំឈ្មោះ **ធន ស្រីពេជ្រ** ជានិស្សិតឆ្នាំទី៤ ថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ជំនាន់ទី២៨ (អាហារូបករណ៍) ឆ្នាំសិក្សា២០២២-២០២៣ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

សូមសំដែងនូវកត្តញ្ញូតាធម៌យ៉ាងជ្រាលជ្រៅជូនចំពោះអ្នកម្តាយ និងលោកឪពុក ដែលលោកអ្នកមានគុណទាំងពីរបានផ្តល់កំណើតដល់រូបកូន និងបានខិតខំទាំងកម្លាំងកាយចិត្ត ក្នុងការចិញ្ចឹមបីបាច់ថែរក្សាអប់រំទូន្មានប្រៀនប្រដៅកូន ព្រមទាំងបានធ្វើការឧបត្ថម្ភគាំទ្រទាំងផ្នែកស្មារតី សម្ភារៈ និងធនធាន តាំងពីរូបកូនចាប់កំណើតរហូតដល់ធំពេញវ័យ ដើម្បីឱ្យបានសិក្សារៀនសូត្រក្រេបជញ្ជក់ចំណេះដឹងតាំងពីថ្នាក់បឋមសិក្សា រហូតដល់បញ្ចប់ការសិក្សា។

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ ឯកឧត្តមបណ្ឌិត សាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង សាស្ត្រាចារ្យ និងបុគ្គលិកទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចដែលបានដឹកនាំគ្រប់គ្រងគ្រប់ផ្នែកយ៉ាងយកចិត្តទុកដាក់ និងបានខិតខំប្រឹងប្រែងអស់ពីកម្លាំងកាយចិត្ត ព្រមទាំងពេលវេលាដ៏មានតម្លៃ ក្នុងការបង្ហាត់បង្រៀននាងខ្ញុំ។

ជាពិសេសលោក **ម៉ៅ មុន្នីណា** ជាគ្រូបង្រៀននៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានចំណាយពេលវេលាដ៏មានតម្លៃរបស់លោក ក្នុងការណែនាំកិច្ចការសារណាមួយនេះ ដោយចង្អុលបង្ហាញ ផ្តល់ឯកសារ ជាមួយបទពិសោធន៍ និងផ្តល់ជាគំនិតល្អក្នុងការសរសេរសារណានេះ ព្រមទាំងធ្វើការកែប្រែកំហុសឆ្គងរបស់នាងខ្ញុំ ដើម្បីធានាដល់ការសម្រេចបានសារណាមួយនេះបញ្ចប់ទៅដោយជោគជ័យ។

ជាទីបញ្ចប់ នាងខ្ញុំសូមគោរពជូនពរ និងសូមបួងសួងដល់ទេវតាដែលថែរក្សាព្រះរាជាណាចក្រកម្ពុជា និងបារមីវត្ថុស័ក្តិសិទ្ធិទាំងពួងនៅលើលោក សូមជួយថែរក្សាការពារ លោកអ្នកមានគុណទាំងទ្វេ ឯកឧត្តមបណ្ឌិត សាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង សាស្ត្រាចារ្យ និងបុគ្គលិកទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ព្រមទាំងលោកគ្រូ **ម៉ៅ មុន្នីណា** ឱ្យជួបប្រទះតែសេចក្តីសុខ សុខភាពល្អ សុភមង្គល ជោគជ័យគ្រប់ភារកិច្ច និងពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ក្នុងឱកាសនៃការបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ នាងខ្ញុំបានជ្រើសរើសប្រធានបទ “**នីតិវិធីនៃការចុះបញ្ជីអត្រានុកូលដ្ឋាន**” ចងក្រងរៀបចំជាសារណា ដើម្បីឱ្យសាធារណជន និងអ្នកសិក្សាគ្រប់មជ្ឈដ្ឋាន បានយល់ដឹងឱ្យកាន់តែស៊ីជម្រៅពាក់ព័ន្ធនឹងអត្រានុកូលដ្ឋាន ព្រោះថាការយល់ដឹងពីលក្ខខណ្ឌបែបបទ និងដំណើរការនៃការស្នើសុំចុះបញ្ជីអត្រានុកូលដ្ឋាន នឹងធ្វើឱ្យបុគ្គលគ្រប់រូបមានភាពងាយស្រួលក្នុងដំណើរការស្នើសុំរបស់ខ្លួន និងអាចជៀសវាងរាល់បញ្ហាដែលកើតឡើងជាយថាហេតុនៅអំឡុងពេលស្នើសុំសំបុត្រអត្រានុកូលដ្ឋាន។

នាងខ្ញុំពិតជាមានសេចក្តីសោមនស្សរីករាយយ៉ាងខ្លាំងដែលទទួលបានឱកាសក្នុងការបញ្ចេញសមត្ថភាពព្រមទាំងចំណេះដឹងដែលទទួលបានតាមរយៈការសិក្សាកន្លងមក ហើយនាងខ្ញុំសង្ឃឹមថាប្រធានបទសារណាមួយនេះនឹងក្លាយជាពុទ្ធិ និងជាប្រយោជន៍ដល់អ្នកស្រាវជ្រាវ អ្នកសិក្សា សិស្សនិស្សិត សាធារណជន ដើម្បីយកមកធ្វើជាមូលដ្ឋានចំណេះដឹង និងជួយចែករំលែកបន្តទៀត។

ជាចុងបញ្ចប់ ដោយសារតែចំណេះដឹងក្នុងការស្រាវជ្រាវនៅមានកម្រិត និងបទពិសោធន៍មានតិចតួចនៅឡើយ ទោះបីជានាងខ្ញុំបានខិតខំប្រឹងប្រែងស្រាវជ្រាវសម្រិតសម្រាំងយ៉ាងណាក្តី ក៏សារណានេះនៅតែមានចំណុចខ្វះខាត ដោយអចេតនានៅត្រង់ចំណុចណាមួយដូចជា ពាក្យពេជន៍ ឃ្លាឃ្លោង អក្ខរាវិរុទ្ធ ការបកស្រាយស្រពិចស្រពិលជាដើម។ ហេតុដូចនេះ នាងខ្ញុំសូមធ្វើការអភ័យទោស រាល់កំហុសឆ្គងដែលកើតឡើងដោយអចេតនា និងទទួលយករាល់មតិយោបល់ ការរិះគន់ក្នុងន័យស្ថាបនាពីសំណាក់សាស្ត្រាចារ្យ រៀមច្បង មិត្តនិស្សិតទាំងអស់ ដើម្បីឱ្យសារណានេះមានភាពល្អប្រសើរឡើងបន្ថែមទៀត។

# មាតិកា

**សេចក្តីផ្តើម** ........................................ ១

**ជំពូកទី១**

**សញ្ញាណទូទៅនៃអត្រានុកូលដ្ឋាន**

១.១. និយមន័យនៃអត្រានុកូលដ្ឋាន ........................................ ៣

១.២. សៀវភៅអត្រានុកូលដ្ឋាន ........................................ ៣

១.៣. សំបុត្រ និងសំបុត្របញ្ជាក់អត្រានុកូលដ្ឋាន ........................................ ៣

១.៤. សេចក្តីចម្លង ឬសម្រង់អត្រានុកូលដ្ឋាន ........................................ ៤

១.៥. សមត្ថកិច្ចនៃមន្ត្រីអត្រានុកូលដ្ឋាន ........................................ ៤

១.៥.១. ថ្នាក់ជាតិ ........................................ ៥

១.៥.២. ថ្នាក់រាជធានី ខេត្ត ........................................ ៥

១.៥.៣. ថ្នាក់ក្រុង ស្រុក ខណ្ឌ ........................................ ៦

១.៥.៤. ថ្នាក់ឃុំ សង្កាត់ ........................................ ៧

១.៥.៥. ថ្នាក់ភូមិ ........................................ ៨

**ជំពូកទី២**

**នីតិវិធីនៃការស្នើសុំសំបុត្រអត្រានុកូលដ្ឋានទាំង០៣ (បី) ប្រភេទ**

២.១. អត្រានុកូលដ្ឋានកំណើត ........................................ ១០

២.១.១. សញ្ញាណទូទៅនៃកំណើត ........................................ ១០

២.១.២. នីតិវិធីនៃការស្នើសុំសំបុត្រកំណើត និងសំបុត្របញ្ជាក់កំណើត ........................................ ១០

២.១.៣. សេចក្តីចម្លង ឬសម្រង់សំបុត្រកំណើត និងសំបុត្របញ្ជាក់កំណើត ........................................ ១៥

២.២. អត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍ ........................................ ១៦

២.២.១. សញ្ញាណទូទៅនៃអាពាហ៍ពិពាហ៍ ........................................ ១៦

២.២.២. លក្ខខណ្ឌនៃការបង្កើត និងការហាមឃាត់ក្នុងការរៀបអាពាហ៍ពិពាហ៍ ........................................ ១៧

២.២.៣. នីតិវិធីនៃការស្នើសុំសំបុត្រអាពាហ៍ពិពាហ៍ ........ ២០
២.២.៤. សេចក្តីចម្លង ឬសម្រង់សំបុត្រអាពាហ៍ពិពាហ៍ និងសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ ........ ២៥
២.៣. អត្រានុកូលដ្ឋានមរណភាព ........ ២៦
២.៣.១. សញ្ញាណទូទៅនៃមរណភាព ........ ២៦
២.៣.២. នីតិវិធីនៃការស្នើសុំសំបុត្រមរណភាព ........ ២៦
២.៣.៣. សេចក្តីចម្លង ឬសម្រង់សំបុត្រមរណភាព និងសំបុត្របញ្ជាក់មរណភាព ........ ៣០

## ជំពូកទី៣

## សារៈប្រយោជន៍ បញ្ហាប្រឈម និងដំណោះស្រាយនៃអត្រានុកូលដ្ឋាន

៣.១. សារៈប្រយោជន៍នៃអត្រានុកូលដ្ឋាន ........ ៣២
៣.១.១. សម្រាប់សង្គមជាតិ ........ ៣២
៣.១.២. សម្រាប់ពលរដ្ឋ ........ ៣៣
៣.២. បញ្ហាប្រឈមនៃអត្រានុកូលដ្ឋាន ........ ៣៣
៣.២.១. ការគ្រប់គ្រងទិន្នន័យ ........ ៣៣
៣.២.២. កត្តាមន្រ្តីអត្រានុកូលដ្ឋាន ........ ៣៤
៣.២.៣. កត្តាប្រជាពលរដ្ឋ ........ ៣៤
៣.៣. ដំណោះស្រាយ ........ ៣៤
៣.៣.១. ការកែតម្រូវទិន្នន័យអត្រានុកូលដ្ឋាន ........ ៣៥
៣.៣.២. មោឃភាពទិន្នន័យអត្រានុកូលដ្ឋាន ........ ៣៧
**សេចក្តីសន្និដ្ឋាន** ........ ៣៨
**អនុសាសន៍** ........ ៤០
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

## លំនាំបញ្ហានៃការស្រាវជ្រាវ

ប្រទេសកម្ពុជាបានទទួលរងសង្គ្រាមជាបន្តបន្ទាប់ចាប់ពីចុងទសវត្សទី៧នៃសតវត្សទី២០មក ដែលនាំឱ្យរបបនយោបាយជាតិមានការប្រែប្រួល និងធ្វើឱ្យស្ថានភាពនៃការគ្រប់គ្រងអត្រានុកូលដ្ឋានមានការផ្លាស់ប្តូរ។ បន្ទាប់ពីបញ្ចប់សង្គ្រាមស៊ីវិល រហូតមកដល់ឆ្នាំ២០០២ ការងារអត្រានុកូលដ្ឋានបានចាប់ផ្តើមឡើងវិញនៅទូទាំងប្រទេសដោយរាជរដ្ឋាភិបាលបានរៀបចំបង្កើតក្របខណ្ឌច្បាប់ សម្រាប់ប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាននៅក្នុងប្រទេសតាមរយៈ អនុក្រឹត្យលេខ១០៣ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០០ ស្តីពីអត្រានុកូលដ្ឋាន ហើយបានដាក់ឱ្យអនុវត្តនៅថ្ងៃទី០១ ខែសីហា ឆ្នាំ២០០២ ក្នុងនោះមានក្រសួងមហាផ្ទៃ អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម និងអគ្គនាយកដ្ឋានអត្រានុកូលដ្ឋានបានរៀបចំមន្ត្រីជំនាញទៅធ្វើការបណ្តុះបណ្តាល ចេញសេចក្តីណែនាំ និងចងក្រងឯកសារការងារអត្រានុកូលដ្ឋាន ដើម្បីធ្វើការផ្សព្វផ្សាយជាសាធារណៈ ក្នុងគោលបំណងផ្តល់ឱ្យប្រជាពលរដ្ឋទាំងអស់មានលទ្ធភាពចុះបញ្ជីអត្រានុកូលដ្ឋានឱ្យបានគ្រប់ៗគ្នា។

ការចុះបញ្ជីអត្រានុកូលដ្ឋាន គឺជាការផ្តល់ឯកសារគតិយុត្តដ៏សំខាន់ចាំបាច់ ជូនប្រជាពលរដ្ឋទាក់ទងនឹងកំណើត អាពាហ៍ពិពាហ៍ និងមរណភាព ដែលជាភស្តុតាងដ៏មានតម្លៃបំផុតក្នុងជីវិតរបស់មនុស្សម្នាក់ៗ សម្រាប់បញ្ជាក់ពីអត្តសញ្ញាណ និងស្ថានភាពស៊ីវិលរបស់ខ្លួនក្នុងគោលបំណងលើកស្ទួយសិទ្ធិ ករណីយកិច្ចរបស់ប្រជាពលរដ្ឋម្នាក់ៗ នៅក្នុងត្រកូលគ្រួសារ និងសង្គមជាតិ ព្រមទាំងប្រើប្រាស់ឯកសារអត្រានុកូលដ្ឋានសម្រាប់ការពារសិទ្ធិ សេរីភាព ផលប្រយោជន៍ និងកាតព្វកិច្ចនានា។

ទន្ទឹមនឹងនេះប្រជាពលរដ្ឋខ្មែរគ្រប់រូប មានតួនាទីទៅស្នើសុំចុះបញ្ជីអត្រានុកូលដ្ឋាន នៅក្នុងសៀវភៅអត្រានុកូលដ្ឋានឱ្យបានគ្រប់ៗគ្នា ប៉ុន្តែដោយសារការវិវត្តនៃលិខិតបទដ្ឋានគតិយុត្តទាក់ទងនឹងអត្រានុកូលដ្ឋានមានការផ្លាស់ប្តូរ កែប្រែ និងណែនាំបន្ថែមជាច្រើន ដែលជាហេតុធ្វើឱ្យការអនុវត្តនៅមានភាពខ្វះចន្លោះនៅឡើយ។

## ចំណោទបញ្ហានៃការស្រាវជ្រាវ

ដោយសារតែប្រជាពលរដ្ឋខ្មែរ មិនទាន់បានយល់ច្បាស់ពីលក្ខខណ្ឌ និងបែបបទនៃការស្នើសុំសំបុត្រអត្រានុកូលដ្ឋាន ដែលបញ្ហាទាំងនេះ អាចបណ្តាលមកពីការផ្សព្វផ្សាយនៅមានកម្រិត ប្រជាជនខ្វះការយល់ដឹង និងមានភាពចន្លោះប្រហោងក្នុងការអនុវត្តច្បាប់ជាដើម។

អាស្រ័យហេតុនេះ ទើបមានបញ្ហាចោទឡើងថា តើអត្រានុកូលដ្ឋានមានអត្ថន័យយ៉ាងដូចម្តេច? តើត្រូវឆ្លងកាត់ដំណាក់កាលអ្វីខ្លះ ដើម្បីទទួលបានសំបុត្រអត្រានុកូលដ្ឋាន? តើអត្រានុកូលដ្ឋានមានសារៈសំខាន់យ៉ាងដូចម្តេចខ្លះ ចំពោះប្រទេសជាតិ និងប្រជាពលរដ្ឋ? តើដំណើរការនីតិវិធីស្នើសុំសំបុត្រអត្រានុកូលដ្ឋាននេះជួបនឹងបញ្ហាប្រឈមអ្វីខ្លះ?

## គោលបំណងនៃការស្រាវជ្រាវ

ការស្រាវជ្រាវនេះ មានគោលបំណង ស្វែងយល់ពីលក្ខខណ្ឌដើម្បីទទួលបានសំបុត្រអត្រានុកូលដ្ឋាន បែបបទ និងដំណើរការនីតិវិធីនៃការចុះបញ្ជីអត្រានុកូលដ្ឋាន ព្រមទាំងទទួលបានចំណេះដឹងពាក់ព័ន្ធនឹងការងារអត្រានុកូលដ្ឋាន អត្ថប្រយោជន៍នៃអត្រានុកូលដ្ឋាន និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗទៀតដែលពាក់ព័ន្ធនឹងអត្រានុកូលដ្ឋាន។

## ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ប្រធានបទមួយនេះ មានដែនកំណត់ស្ថិតក្រោមលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងការចុះបញ្ជីអត្រានុកូលដ្ឋានរួមមាន អនុក្រឹត្យស្ដីពីអត្រានុកូលដ្ឋានឆ្នាំ២០០០ សេចក្ដីណែនាំនានារបស់ក្រសួងមហាផ្ទៃ និងកម្រងឯកសារផ្សេងៗ ហើយការស្រាវជ្រាវមួយនេះ គឺផ្ដោតសំខាន់ទៅលើការចុះបញ្ជីអត្រានុកូលដ្ឋានទាក់ទងនឹងការដាក់ពាក្យស្នើសុំចុះអត្រានុកូលដ្ឋាន រហូតទទួលបានសំបុត្រអត្រានុកូលដ្ឋាន។

## សារៈសំខាន់នៃការស្រាវជ្រាវ

ប្រធានបទសារណាមួយនេះ មានសារៈសំខាន់ជាច្រើនដល់សាធារណជន និងអ្នកសិក្សាគ្រប់មជ្ឈដ្ឋានទាំងអស់ ឱ្យកាន់តែយល់ច្បាស់ និងស៊ីជម្រៅទាក់ទងនឹងប្រភេទអត្រានុកូលដ្ឋាន លក្ខខណ្ឌផ្សេងៗ និងដំណើរការនីតិវិធីនៃការស្នើសុំសំបុត្រអត្រានុកូលដ្ឋាន។

## វិធីសាស្ត្រនៃការស្រាវជ្រាវ

វិធីសាស្ត្រក្នុងការស្រាវជ្រាវប្រធានបទនេះ គឺតាមរយៈការប្រមូលទិន្នន័យពីឯកសាបទដ្ឋានគតិយុត្តដែលមានស្រាប់ដូចជា ច្បាប់ អនុក្រឹត្យ សេចក្ដីណែនាំផ្សេងៗ និងកម្រងឯកសារចងក្រងរបស់ស្ថាប័ន។

## រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ដើម្បីឆ្លើយតបនឹងប្រធានបទ "នីតិវិធីនៃការចុះបញ្ជីអត្រានុកូលដ្ឋាន" សូមបែងចែកការស្រាវជ្រាវនេះជា៣(បី)ជំពូក។ ជំពូកទី១ បកស្រាយពី សញ្ញាណទូទៅនៃអត្រានុកូលដ្ឋាន។ រីឯជំពូកទី២ បកស្រាយពី នីតិវិធីនៃការស្នើសុំសំបុត្រអត្រានុកូលដ្ឋានទាំង៣(បី)ប្រភេទ។ ចុងក្រោយជំពូកទី៣ បកស្រាយពី សារៈប្រយោជន៍ បញ្ហាប្រឈម និងដំណោះស្រាយនៃអត្រានុកូលដ្ឋាន។

# ជំពូកទី១

# សញ្ញាណទូទៅនៃអត្រានុកូលដ្ឋាន

# ជំពូកទី១
# សញ្ញាណទូទៅនៃអត្រានុកូលដ្ឋាន

## ១.១. និយមន័យនៃអត្រានុកូលដ្ឋាន

អត្រានុកូលដ្ឋាន គឺជាចំណងរួមភ្ជាប់សញ្ជាតិទៅនឹងរដ្ឋ និងស្ថានភាពជាក់ស្តែង ដែលជននោះមាននៅក្នុងត្រកូលគ្រួសារខ្លួន និងសង្គមជាតិ និងដែលបង្កើតឱ្យជននោះមានសិទ្ធិ និងករណីយកិច្ច ដោយយោងតាមមាត្រា ២ នៃអនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន។[1] មានន័យថា មនុស្សគ្រប់រូបដែលមានលក្ខណៈសម្បត្តិអាចទទួលបានសិទ្ធិ និងកាតព្វកិច្ចតាមផ្លូវច្បាប់ ចាប់តាំងពីពេលចាប់កំណើតរហូតដល់ទទួលមរណភាពបាន គឺតាមរយៈការសុំចុះអត្រានុកូលដ្ឋាន។

## ១.២. សៀវភៅអត្រានុកូលដ្ឋាន

ប្រជាពលរដ្ឋខ្មែរគ្រប់រូបមានកាតព្វកិច្ចក្នុងការសុំចុះអត្រានុកូលដ្ឋានក្នុងសៀវភៅអត្រានុកូលដ្ឋាន។[2] នៅក្នុងឃុំ ឬសង្កាត់នីមួយៗត្រូវមានសៀវភៅអត្រានុកូលដ្ឋានសម្រាប់កត់ត្រាពីព្រឹត្តិការណ៍គតិយុត្តសំខាន់ៗ ដូចជាកំណើត អាពាហ៍ពិពាហ៍ និងមរណភាព។ ក្នុងនោះដែរសៀវភៅអត្រានុកូលដ្ឋានមានដូចជា សៀវភៅអត្រានុកូលដ្ឋានកំណើត សៀវភៅអត្រានុកូលដ្ឋានបញ្ជាក់កំណើត សៀវភៅអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍ សៀវភៅអត្រានុកូលដ្ឋានបញ្ជាក់អាពាហ៍ពិពាហ៍ សៀវភៅអត្រានុកូលដ្ឋានមរណភាព សៀវភៅអត្រានុកូលដ្ឋានបញ្ជាក់មរណភាព សៀវភៅអត្រានុកូលដ្ឋានកំណើតជនបរទេស និងជនអន្តោប្រវេសន៍ស្របច្បាប់ សៀវភៅអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍ជនបរទេស និងជនអន្តោប្រវេសន៍ស្របច្បាប់ និងសៀវភៅអត្រានុកូលដ្ឋានមរណភាពជនបរទេស និងជនអន្តោប្រវេសន្តស្របច្បាប់ ដែលសៀវភៅទាំងអស់នេះត្រូវសរសេរជា០២(ពីរ)ក្បាល(សៀវភៅភ្លោះ) មានខ្លឹមសារដូចគ្នាទាំងស្រុងទៅតាមប្រភេទនីមួយៗ។[3] ចំពោះសៀវភៅអត្រានុកូលដ្ឋានបញ្ជាក់អាពាហ៍ពិពាហ៍ និងសៀវភៅអត្រានុកូលដ្ឋានបញ្ជាក់មរណភាព អនុវត្តតែក្នុងចន្លោះឆ្នាំ២០០២ ដល់ឆ្នាំ ២០០៦ តែប៉ុណ្ណោះ។

## ១.៣. សំបុត្រ និងសំបុត្របញ្ជាក់អត្រានុកូលដ្ឋាន

សំបុត្រអត្រានុកូលដ្ឋាន គឺជាសំបុត្រសម្រាប់កត់ត្រាភាពជាស៊ីវិលនៃពលរដ្ឋខ្មែរ និងជនបរទេសដែលរស់នៅស្របច្បាប់ ក្នុងដែនសមត្ថកិច្ចកំណត់ នៃច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា។[4] ក្រោយពេលដែលបុគ្គល

[1] អនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន, លេខ១០៣ អនក្រ.បក, ២៩ ធ្នូ ២០០០, មាត្រា២(តទៅហៅថា អនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន)។
[2] អនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន, មាត្រា៣។
[3] កម្រងឯកសារស្តីពីរបៀបកត់ត្រាការងារអត្រានុកូលដ្ឋាននៃជំពូកទី១ ស្តីពីទិដ្ឋភាពទូទៅនៃអត្រានុកូលដ្ឋាន, កក្កដា ២០០៥, ទំព័រ២៥។
[4] អនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន, មាត្រា២(២)។

ណាម្នាក់បានបំពេញលក្ខខណ្ឌទៅតាមការសុំចុះបញ្ជីអត្រានុកូលដ្ឋានប្រភេទណាមួយ ក្នុងសៀវភៅអត្រានុកូលដ្ឋានរួចហើយ មន្ត្រីអត្រានុកូលដ្ឋាននឹងផ្តល់សំបុត្រអត្រានុកូលដ្ឋានច្បាប់ដើមចំនួន ០១(មួយ)សន្លឹក ជូនទៅបុគ្គលនោះ ទុកជាការសម្គាល់។ សំបុត្រអត្រានុកូលដ្ឋានមានដូចជា សំបុត្រកំណើត សំបុត្រអាពាហ៍ពិពាហ៍ និងសំបុត្រមរណភាព។[5]

ចំពោះប្រជាពលរដ្ឋខ្មែរដែលបាន កើត ឬរៀបអាពាហ៍ពិពាហ៍ ឬទទួលមរណភាព ហើយមិនទាន់មានសំបុត្រអត្រានុកូលដ្ឋានប្រើប្រាស់ មុនពេលដែលអនុក្រឹត្យស្តីពីអត្រានុកូលដ្ឋានឆ្នាំ២០០០ ចូលជាធរមាន នោះពួកគាត់មិនអាចស្នើសុំចុះក្នុងសៀវភៅអត្រានុកូលដ្ឋានទេ តែអាចសុំចុះសៀវភៅបញ្ជាក់អត្រានុកូលដ្ឋាននៃប្រភេទណាមួយបានដែលអនុវត្តចំពោះតែពលរដ្ឋខ្មែរ ចាប់ពីឆ្នាំ២០០២ ដល់ ឆ្នាំ២០០៦តែប៉ុណ្ណោះ។[6]

## ១.៤. សេចក្តីចម្លង ឬសម្រង់អត្រានុកូលដ្ឋាន

សេចក្តីចម្លង ឬសម្រង់អត្រានុកូលដ្ឋាន គឺជាក្រដាសដែលមានខ្លឹមសារ និងអានុភាពអនុវត្តដូចទៅនឹងសំបុត្រអត្រានុកូលដ្ឋាន ហើយបុគ្គលគ្រប់រូប អាចស្នើសុំសេចក្តីចម្លង ឬសម្រង់អត្រានុកូលដ្ឋាន តាមតម្រូវការរបស់ខ្លួនបាន។[7]

សេចក្តីចម្លង ឬសម្រង់អត្រានុកូលដ្ឋានមានដូចជា សេចក្តីចម្លង ឬសម្រង់សំបុត្រកំណើត សេចក្តីចម្លង ឬសម្រង់សំបុត្របញ្ជាក់កំណើត សេចក្តីចម្លង ឬសម្រង់សំបុត្រអាពាហ៍ពិពាហ៍ សេចក្តីចម្លង ឬសម្រង់សំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ សេចក្តីចម្លង ឬសម្រង់សំបុត្រមរណភាព និងសេចក្តីចម្លង ឬសម្រង់សំបុត្របញ្ជាក់មរណភាព។[8]

## ១.៥. សមត្ថកិច្ចនៃមន្ត្រីអត្រានុកូលដ្ឋាន

ដើម្បីធានាដល់ការបម្រើសេវាមូលដ្ឋានលើការងារអត្រានុកូលដ្ឋាន រាជរដ្ឋាភិបាលបានរៀបចំយន្តការដោយបែងចែកសមត្ថកិច្ច និងការទទួលខុសត្រូវតាមឋានានុក្រមដូចជា ថ្នាក់ជាតិ(១.៥.១) ថ្នាក់រាជធានី ខេត្ត(១.៥.២) ថ្នាក់ក្រុង ស្រុក ខណ្ឌ(១.៥.៣) ថ្នាក់ឃុំ សង្កាត់(១.៥.៤) និងថ្នាក់ភូមិ(១.៥.៥)។

[5] អនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន, មាត្រា២(៣)។

[6] អនុក្រឹត្យស្តីពីការកែសម្រួល អនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន, លេខ១០៦ អនក្រ.បក, ២៣ សីហា ២០០៥, មាត្រា៥៩។

[7] អនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន, មាត្រា៤៩(២)។

[8] អនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន, មាត្រា៤៩(១)។

### ១.៥.១. ថ្នាក់ជាតិ

អគ្គនាយកនៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្មនៃក្រសួងមហាផ្ទៃ ជាមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ[9] ដែលមានភារកិច្ចដូចជា ដាក់ចេញគោលការណ៍ណែនាំ បែបបទនិងនីតិវិធីនានា ដើម្បីធានាដល់ការអនុវត្តច្បាប់ និងបទប្បញ្ញត្តិនានាស្តីពីអត្រានុកូលដ្ឋាន។[10]

ក្នុងករណីមានការស្នើសុំកែតម្រូវទិន្នន័យ ឬមោឃភាពបញ្ជីអត្រានុកូលដ្ឋាន មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិត្រូវពិនិត្យសម្រេច និងអនុញ្ញាតឱ្យកែតម្រូវ ឬមោឃភាពបញ្ជីអត្រានុកូលដ្ឋាន ឬចុះបញ្ជីអត្រានុកូលដ្ឋានឡើងវិញស្របតាមប្បញ្ញត្តិនៃច្បាប់។ ប្រសិនបើមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ក្រោមជាតិ មិនអាចសម្រេចបានបញ្ហាណាមួយ មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិត្រូវពិនិត្យ និងសម្រេចលើបញ្ហាដែលមិនអាចដោះស្រាយបាន។[11]

មិនតែប៉ុណ្ណោះ មន្ត្រីអត្រានុកូលដ្ឋានត្រូវចេញសេចក្តីចម្លងនិងសម្រង់អត្រានុកូលតាមការស្នើសុំ ហើយត្រូវដាក់ឱ្យប្រើប្រាស់សៀវភៅអត្រានុកូលដ្ឋានតាមឆ្នាំនីមួយៗជាផ្លូវការ ដោយបញ្ជា និងណែនាំដល់មន្ត្រីអត្រានុកូលដ្ឋានឱ្យអនុវត្តការងារអត្រានុកូលដ្ឋានឱ្យបានល្អបំផុត ប្រសិនបើមន្ត្រីអត្រានុកូលដ្ឋានបានប្រព្រឹត្តអំពើដែលរំលោភបទប្បញ្ញត្តិច្បាប់ មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ ត្រូវរាយការណ៍ទៅរដ្ឋមន្ត្រីក្រសួងមហាផ្ទៃដើម្បីចាត់វិធានការតាមផ្លូវច្បាប់។[12]

### ១.៥.២. ថ្នាក់រាជធានី ខេត្ត

អភិបាលរាជធានី ខេត្ត ទទួលខុសត្រូវក្នុងការត្រួតពិនិត្យការអនុវត្តការងារស្ថិតិ និងអត្រានុកូលដ្ឋាននៅរាជធានី ខេត្ត របស់ខ្លួន ដោយមានការិយាល័យស្ថិតិ និងអត្រានុកូលដ្ឋាននៃសាលារាជធានី ខេត្ត ជាសេនាធិការ និងមានភារកិច្ចដូចជា ពិនិត្យ និងបូកសរុបស្ថិតិប្រជាពលរដ្ឋទូទាំងរាជធានី ខេត្ត និងប្រជាពលរដ្ឋដែលបានចុះសៀវភៅអត្រានុកូលដ្ឋានគ្រប់ប្រភេទប្រចាំខែ និងផ្ញើរបាយការណ៍ទៅអគ្គនាយកនៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្មនៃក្រសួងមហាផ្ទៃ រៀងរាល់ថ្ងៃទី១៥ នៃខែបន្ទាប់នីមួយៗ។[13]

---

[9] អនុក្រឹត្យស្តីពីមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ, លេខ១៣៨ អនក្រ.បក, ០៤ កក្កដា ២០១៦, មាត្រា៤ (តទៅហៅថា អនុក្រឹត្យស្តីពីអត្រានុកូលដ្ឋានថ្នាក់ជាតិ)។

[10] អនុក្រឹត្យស្តីពីមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ, មាត្រា៥(១,២)។

[11] អនុក្រឹត្យស្តីពីមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ, មាត្រា៥(៥-៧)។

[12] អនុក្រឹត្យស្តីពីមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ, មាត្រា៥(៣,៤,៨,៩)។

[13] កម្រងឯកសារស្តីពីរបៀបកត់ត្រាការងារអត្រានុកូលដ្ឋាននៃជំពូកទី១ ស្តីពីទិដ្ឋភាពទូទៅនៃអត្រានុកូលដ្ឋាន, កក្កដា ២០០៥, ទំព័រ១៤ (ឧ១,ឧ៣)។

លើសពីនេះទៅទៀត មន្ត្រីអត្រានុកូលដ្ឋានរាជធានី ខេត្ត ត្រូវលើកគម្រោងទៅក្រសួងមហាផ្ទៃ ដើម្បីស្នើសុំសៀវភៅ និងក្រដាសអត្រានុកូលដ្ឋានគ្រប់ប្រភេទ សម្រាប់ផ្តល់ឱ្យក្រុង ស្រុក ខណ្ឌ ធ្វើការបែងចែកដល់ឃុំ សង្កាត់ និងធ្វើរបាយការណ៍បូកសរុបការប្រើប្រាស់សៀវភៅ និងក្រដាសអត្រានុកូលដ្ឋានឱ្យទាន់ពេលកំណត់។[14]

ជាពិសេស មន្ត្រីអត្រានុកូលដ្ឋានរាជធានី ខេត្ត ត្រូវចូលរួមផ្សព្វផ្សាយលិខិតបទដ្ឋាន សេចក្តីណែនាំ ផែនការណែនាំអំពីការងារអត្រានុកូលដ្ឋានដល់ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ចំណុះ ព្រមទាំងសហការរៀបចំការបណ្តុះបណ្តាល ការកសាងសមត្ថភាព និងការអប់រំសាធារណជនអំពីការងារអត្រានុកូលដ្ឋាន។[15]

### ១.៥.៣. ថ្នាក់ក្រុង ស្រុក ខណ្ឌ

អភិបាលក្រុង ស្រុក ខណ្ឌទទួលខុសត្រូវក្នុងការត្រួតពិនិត្យ និងអនុវត្តការងារស្ថិតិ និងអត្រានុកូលដ្ឋាននៅក្រុង ស្រុក ខណ្ឌរបស់ខ្លួន ដោយមានការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុនៃសាលាក្រុង ស្រុក ខណ្ឌ ជាសេនាធិការ មានភារកិច្ចដូចជា ត្រួតពិនិត្យ និងបូកសរុបស្ថិតិប្រជាពលរដ្ឋទូទាំងក្រុង ស្រុក ខណ្ឌ និងប្រជាពលរដ្ឋដែលបានចុះសៀវភៅអត្រានុកូលដ្ឋានគ្រប់ប្រភេទប្រចាំខែនីមួយៗ តាមឃុំ សង្កាត់ចំណុះ និងផ្ញើទៅការិយាល័យស្ថិតិ និងអត្រានុកូលដ្ឋាន នៃទីចាត់ការរដ្ឋបាលសាលារាជធានី ខេត្ត រៀងរាល់ថ្ងៃទី១០ នៃខែបន្ទាប់នីមួយៗ។[16]

លើកគម្រោងទៅសាលារាជធានី ខេត្ត ដើម្បីស្នើសុំសៀវភៅ និងក្រដាសអត្រានុកូលដ្ឋានគ្រប់ប្រភេទសម្រាប់បែងចែកជូនឃុំ សង្កាត់ ដោយត្រូវបំពេញសន្លឹកដើមដំបូងបំផុត ហើយចុះលេខរៀងសន្លឹកនៃសៀវភៅអត្រានុកូលដ្ឋាន រួចដាក់ជូនអភិបាលក្រុង ស្រុក ខណ្ឌ ដើម្បីចុះហត្ថលេខា (ហត្ថលេខាពេញ និងសង្ខេប) និងបោះត្រា មុននឹងបញ្ជូនសៀវភៅអត្រានុកូលដ្ឋានទៅឱ្យឃុំ សង្កាត់ទៅប្រើប្រាស់ ហើយត្រូវបូកសរុបការប្រើប្រាស់សៀវភៅ និងក្រដាសអត្រានុកូលដ្ឋាន ផ្ញើមករាជធានី ខេត្ត តាមការកំណត់។[17]

ជាងនេះទៅទៀត ត្រូវចូលរួមផ្សព្វផ្សាយលិខិតបទដ្ឋាន សេចក្តីណែនាំ ផែនការណែនាំអំពីការងារអត្រានុកូលដ្ឋានដល់ឃុំ សង្កាត់ចំណុះ និងត្រួតពិនិត្យជាប្រចាំ ការអនុវត្តការចុះសៀវភៅអត្រានុកូលដ្ឋានគ្រប់

---

[14] កម្រងឯកសារស្តីពីរបៀបកត់ត្រាការងារអត្រានុកូលដ្ឋាននៃជំពូកទី១ ស្តីពីទិដ្ឋភាពទូទៅនៃអត្រានុកូលដ្ឋាន, កក្កដា ២០០៥, ទំព័រ១៤ (ខ៤)។

[15] កម្រងឯកសារស្តីពីរបៀបកត់ត្រាការងារអត្រានុកូលដ្ឋាននៃជំពូកទី១ ស្តីពីទិដ្ឋភាពទូទៅនៃអត្រានុកូលដ្ឋាន, កក្កដា ២០០៥, ទំព័រ១៤ (ខ៥-ខ៧)។

[16] កម្រងឯកសារស្តីពីរបៀបកត់ត្រាការងារអត្រានុកូលដ្ឋាននៃជំពូកទី១ ស្តីពីទិដ្ឋភាពទូទៅនៃអត្រានុកូលដ្ឋាន, កក្កដា ២០០៥, ទំព័រ១៥ (គ១,គ២)។

[17] កម្រងឯកសារស្តីពីរបៀបកត់ត្រាការងារអត្រានុកូលដ្ឋាននៃជំពូកទី១ ស្តីពីទិដ្ឋភាពទូទៅនៃអត្រានុកូលដ្ឋាន, កក្កដា ២០០៥, ទំព័រ១៥ (គ៣,គ៤)។

ប្រភេទនៅតាមឃុំ សង្កាត់ និងពិនិត្យរាល់បញ្ជីក្នុងសៀវភៅអត្រានុកូលដ្ឋានគ្រប់ប្រភេទដែលឃុំ សង្កាត់ផ្ញើមកក្រុង ស្រុក ខណ្ឌពេលដាច់ឆ្នាំនីមួយៗឱ្យបានត្រឹមត្រូវតាមការណែនាំរបស់ក្រសួងមហាផ្ទៃ។ [18]

ក្នុងករណីមានការស្នើសុំ មន្ត្រីអត្រានុកូលដ្ឋានចេញសេចក្តីចម្លង ឬសម្រង់នៃអត្រានុកូលដ្ឋានគ្រប់ប្រភេទ ជូនដល់ប្រជាពលរដ្ឋដែលមកសុំចម្លងនៅឆ្នាំដែលកន្លងផុត។

### ១.៥.៤. ថ្នាក់ឃុំ សង្កាត់

ក្រុមប្រឹក្សាឃុំ សង្កាត់ទទួលខុសត្រូវអំពីការងារអត្រានុកូលដ្ឋានក្នុងដែនដីឃុំ សង្កាត់ដែលខ្លួនគ្រប់គ្រង។ មេឃុំ ចៅសង្កាត់ជាមន្ត្រីអត្រានុកូលដ្ឋាន មានភារកិច្ចដូចជា ទទួលពិនិត្យ អនុញ្ញាតឱ្យរៀបអាពាហ៍ពិពាហ៍ និងធ្វើបុណ្យបូជា ឬបញ្ចុះសពនិងកត់ត្រារឿងហេតុ សំខាន់ៗទាក់ទងនឹងកំណើត អាពាហ៍ពិពាហ៍ និងមរណភាពនៃជនទាំងឡាយ ចុះនៅក្នុងសៀវភៅអត្រានុកូលដ្ឋាន ដោយចុះហត្ថលេខា និងបោះត្រាលើបញ្ជី និងសំបុត្រអត្រានុកូលដ្ឋាន និងចេញសេចក្តីចម្លង ឬសម្រង់នៃអត្រានុកូលដ្ឋាន ទៅតាមការស្នើសុំរបស់ប្រជាពលរដ្ឋ នៅឆ្នាំដែលមិនទាន់ដាច់។[19]

បន្ទាប់មក ធ្វើរបាយការណ៍អំពីកំណើត អាពាហ៍ពិពាហ៍ មរណភាព ចំនួនគ្រួសារ ចំនួនប្រជាពលរដ្ឋក្នុងឃុំ សង្កាត់ ជារៀងរាល់ខែនាថ្ងៃទី០៥នៃខែបន្ទាប់ និងរាល់ដំណាច់ឆ្នាំនីមួយៗផ្ញើទៅសាលាក្រុង ស្រុក ខណ្ឌសាមី លើកគម្រោងស្នើសុំសៀវភៅ និងក្រដាសអត្រានុកូលដ្ឋាន ដើម្បីយកមកសម្រាប់ប្រើប្រាស់នៅក្នុងឃុំ សង្កាត់របស់ខ្លួន ព្រមទាំងថែរក្សាទុកដាក់សៀវភៅអត្រានុកូលដ្ឋានតាមប្រភេទឱ្យបានល្អ និងបិទសៀវភៅអត្រានុកូលដ្ឋាននៅពេលប្រើប្រាស់អស់បញ្ជី ហើយនៅដំណាច់ឆ្នាំនីមួយៗ ក្រោយពីបានពិនិត្យត្រឹមត្រូវរួចរាល់អស់ហើយ ត្រូវបញ្ជូនសៀវភៅអត្រានុកូលដ្ឋានដែលបានបិទបញ្ជីទៅសាលាក្រុង ស្រុក ខណ្ឌ នៅដើមខែមករានៃឆ្នាំបន្ទាប់ ដើម្បីយកទៅតម្កល់ទុកនៅសាលាក្រុង ស្រុក ខណ្ឌផ្ទាល់មួយច្បាប់ និងនៅសាលារាជធានី ខេត្តសាមីមួយច្បាប់។[20]

លើសពីនេះទៅទៀត ជួយផ្សព្វផ្សាយដល់ប្រជាពលរដ្ឋក្នុងឃុំ សង្កាត់ឱ្យបានយល់ដឹងពីកាតព្វកិច្ចរបស់ខ្លួនចំពោះអត្រានុកូលដ្ឋាន និងបង្កលក្ខណៈងាយស្រួលដល់ប្រជាពលរដ្ឋដែលមកទំនាក់ទំនងពីការងារ

[18] កម្រងឯកសារស្តីពីរបៀបកត់ត្រាការងារអត្រានុកូលដ្ឋាននៃជំពូកទី១ ស្តីពីទិដ្ឋភាពទូទៅនៃអត្រានុកូលដ្ឋាន, កក្កដា ២០០៥, ទំព័រ១៥ (គ៨-គ១១)។

[19] កម្រងឯកសារស្តីពីរបៀបកត់ត្រាការងារអត្រានុកូលដ្ឋាននៃជំពូកទី១ ស្តីពីទិដ្ឋភាពទូទៅនៃអត្រានុកូលដ្ឋាន, កក្កដា ២០០៥, ទំព័រ១៦ (ឃ៣-ឃ៧)។

[20] កម្រងឯកសារស្តីពីរបៀបកត់ត្រាការងារអត្រានុកូលដ្ឋាននៃជំពូកទី១ ស្តីពីទិដ្ឋភាពទូទៅនៃអត្រានុកូលដ្ឋាន, កក្កដា ២០០៥, ទំព័រ១៧ (ឃ៨-ឃ១១)។

អត្រានុកូលដ្ឋាន និងចលនាប្រជាពលរដ្ឋរស់នៅក្នុងឃុំ សង្កាត់របស់ខ្លួនឱ្យមកចុះសៀវភៅអត្រានុកូលដ្ឋានឱ្យបានគ្រប់ៗគ្នា និងទាន់ពេលវេលា។[21]

មិនតែប៉ុណ្ណោះ មន្ត្រីអត្រានុកូលដ្ឋាន មានសិទ្ធិមិនចុះអត្រានុកូលដ្ឋានឱ្យជនណាមួយដែលខ្លួនយល់ថាមិនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងមិនមែនជាពលរដ្ឋខ្មែរ។[22]

**១.៥.៥. ថ្នាក់ភូមិ**

មេភូមិ ត្រូវមានភារកិច្ចដូចជា ត្រូវចលនាឱ្យប្រជាពលរដ្ឋទៅចុះសៀវភៅអត្រានុកូលដ្ឋានកំណើត និងមរណភាព ឱ្យបានទាន់ពេលវេលា និងចលនាអ្នកដែលបានរៀបអាពាហ៍ពិពាហ៍តាមប្រពៃណីរួចហើយ តែមិនទាន់បានចុះបញ្ជីអាពាហ៍ពិពាហ៍ ត្រូវទៅសុំចុះសៀវភៅអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍ ដើម្បីស្របទៅតាមផ្លូវច្បាប់។ ក្នុងករណីមានទារកកើតនៅផ្ទះ មេភូមិត្រូវចេញលិខិតបញ្ជាក់ទទួលស្គាល់កំណើតទារក តាមការស្នើសុំឪពុកម្តាយទារក ដើម្បីឱ្យឪពុកម្តាយទារកមានឯកសារភស្តុតាងសម្រាប់ទៅសុំមន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់ នៅលំនៅឋានអចិន្ត្រៃយ៍របស់ខ្លួន ដើម្បីចុះសៀវភៅអត្រានុកូលដ្ឋានកំណើតឱ្យកូន។[23]

មិនតែប៉ុណ្ណោះមេភូមិត្រូវកត់ត្រាប្រចាំខែនីមួយៗ ឱ្យបានច្បាស់លាស់នូវស្ថិតិ ទារកដែលទើបកើត ទារកដែលទើបកើតហើយស្លាប់ អ្នកដែលបានរៀបអាពាហ៍ពិពាហ៍ អ្នកដែលរួមរស់ជាមួយគ្នាក្នុងស្ថានភាពប្តីប្រពន្ធ និងអ្នកដែលទទួលមរណភាព ដោយត្រូវស្រង់តាមលក្ខខណ្ឌដូចជា ទារកដែលបានសុំចុះសៀវភៅអត្រានុកូលដ្ឋានកំណើតទាន់ពេលកំណត់៣០ថ្ងៃរួចហើយ និងទារកដែលមិនទាន់បានសុំចុះសៀវភៅអត្រានុកូលដ្ឋានកំណើតហួសពេលកំណត់៣០ថ្ងៃ អ្នកទទួលមរណភាពដែលបានចុះសៀវភៅអត្រានុកូលដ្ឋានមរណភាពទាន់ពេលកំណត់១៥ថ្ងៃ និងអ្នកទទួលមរណភាពទុកឱ្យហួស១៥ថ្ងៃ ពុំបានចុះសៀវភៅអត្រានុកូលដ្ឋានមរណភាព និងអ្នកដែលបានសុំចុះសៀវភៅអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍រួច និងអ្នកដែលបានរៀបអាពាហ៍ពិពាហ៍តាមប្រពៃណី តែពុំទាន់សុំចុះសៀវភៅអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍ ហើយត្រូវផ្ញើស្ថិតិទៅសាលាឃុំ សង្កាត់ នៅថ្ងៃទី០៣នៃខែបន្ទាប់ដើម្បីធ្វើការបូកសរុប។[24]

[21] កម្រងឯកសារស្តីពីរបៀបកត់ត្រាការងារអត្រានុកូលដ្ឋាននៃជំពូកទី១ ស្តីពីទិដ្ឋភាពទូទៅនៃអត្រានុកូលដ្ឋាន, កក្កដា ២០០៥, ទំព័រ១៧ (ឃ២,ឃ១២)។

[22] កម្រងឯកសារស្តីពីរបៀបកត់ត្រាការងារអត្រានុកូលដ្ឋាននៃជំពូកទី១ ស្តីពីទិដ្ឋភាពទូទៅនៃអត្រានុកូលដ្ឋាន, កក្កដា ២០០៥, ទំព័រ១៨។

[23] កម្រងឯកសារស្តីពីរបៀបកត់ត្រាការងារអត្រានុកូលដ្ឋាននៃជំពូកទី១ ស្តីពីទិដ្ឋភាពទូទៅនៃអត្រានុកូលដ្ឋាន, កក្កដា ២០០៥, ទំព័រ១៩ (ង១-ង៣)។

[24] កម្រងឯកសារស្តីពីរបៀបកត់ត្រាការងារអត្រានុកូលដ្ឋាននៃជំពូកទី១ ស្តីពីទិដ្ឋភាពទូទៅនៃអត្រានុកូលដ្ឋាន, កក្កដា ២០០៥, ទំព័រ១៩ (ង៤)។

# ជំពូកទី២

# នីតិវិធីនៃការស្នើសុំសំបុត្រអគ្រានុកូលដ្ឋាន

# ទាំង០៣ (បី)ប្រភេទ

# ជំពូកទី២
# នីតិវិធីនៃការស្នើសុំសំបុត្រអត្រានុកូលដ្ឋានទាំង០៣ (បី) ប្រភេទ

## ២.១. អត្រានុកូលដ្ឋានកំណើត

### ២.១.១. សញ្ញាណទូទៅនៃអត្រានុកូលដ្ឋានកំណើត

កំណើត ជាព្រឹត្តិការណ៍គតិយុត្តដែលនាំឱ្យកើតមាននូវរូបវន្តបុគ្គល ដោយចាប់ផ្តើមកើតមានសិទ្ធិ និងកាតព្វកិច្ចរបស់បុគ្គលគ្រប់រូប។ ដើម្បីឱ្យក្លាយជារូបវន្តបុគ្គលបាន គឺត្រូវកើតមកជាមនុស្ស និងកើតមករស់ ហើយនឹងអាចរស់បាន។[25] យោងតាមអនុសញ្ញាសកល ស្តីពីសិទ្ធិកុមារបានចែងថា កុមារត្រូវបានចុះបញ្ជីអត្រានុកូលដ្ឋានកំណើតភ្លាម ក្រោយពេលប្រសូត។[26] ដូច្នេះហើយ ឪពុកឬ ម្តាយ មានកាតព្វកិច្ចត្រូវទៅរាយការណ៍ ពីកំណើតកូនរបស់ខ្លួន ដោយសុំចុះក្នុងសៀវភៅអត្រានុកូលដ្ឋានកំណើត នៅសាលាឃុំ សង្កាត់នៃលំនៅដ្ឋានអចិន្ត្រៃយ៍របស់ខ្លួន។

ចំពោះសៀវភៅអត្រានុកូលដ្ឋានទាក់ទងនឹងកំណើតរួមមាន សៀវភៅអត្រានុកូលដ្ឋានកំណើត សៀវភៅអត្រានុកូលដ្ឋានបញ្ជាក់កំណើត និងសៀវភៅអត្រានុកូលដ្ឋានកំណើតសម្រាប់ជនបរទេស និងជនអន្តោប្រវេសន៍ស្របច្បាប់។[27] រីឯក្រដាសអត្រានុកូលដ្ឋានទាក់ទងនឹងកំណើតមានដូចជា សំបុត្រកំណើត សំបុត្របញ្ជាក់កំណើត សេចក្តីចម្លងសំបុត្រកំណើត និងសេចក្តីចម្លងសំបុត្របញ្ជាក់កំណើត។[28]

### ២.១.២. នីតិវិធីនៃការស្នើសុំសំបុត្រកំណើត និងសំបុត្របញ្ជាក់កំណើត

ឪពុក ឬម្តាយ មានកាតព្វកិច្ចត្រូវទៅរាយការណ៍ ចុះសៀវភៅអត្រានុកូលដ្ឋានកំណើតឱ្យកូនដែលទើបនឹងកើត មិនឱ្យហួស ៣០ (សាមសិប) ថ្ងៃ គិតចាប់ពីថ្ងៃកើត។[29] ក្នុងករណីដែលបានកើតហើយទុកហួសរយៈពេល ៣០ (សាមសិប) ថ្ងៃ ហើយពុំទាន់មានសំបុត្រកំណើតប្រើប្រាស់ សាមីខ្លួន ឬឪពុក ឬម្តាយ ឬអាណាព្យាបាល ត្រូវប្តឹងសុំចុះសៀវភៅអត្រានុកូលដ្ឋានបញ្ជាក់កំណើត នៅសាលាឃុំ សង្កាត់សាមី ដែលខ្លួនរស់នៅពិតប្រាកដបច្ចុប្បន្ន នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន។[30]

---

[25] កម្រងឯកសារស្តីពីរបៀបកត់ត្រាការងារអត្រានុកូលដ្ឋាននៃជំពូកទី១ ស្តីពីទិដ្ឋភាពទូទៅនៃអត្រានុកូលដ្ឋាន, កក្កដា ២០០៥, ទំព័រ១។
[26] អនុសញ្ញាស្តីពីសិទ្ធិកុមារ, ឆ្នាំ១៩៨៩, មាត្រា៦។
[27] កម្រងឯកសារស្តីពីរបៀបកត់ត្រាការងារអត្រានុកូលដ្ឋាននៃជំពូកទី១ ស្តីពីអត្រានុកូលដ្ឋានកំណើត, កក្កដា ២០០៥, ទំព័រ៤៧(២.១.១)។
[28] កម្រងឯកសារស្តីពីរបៀបកត់ត្រាការងារអត្រានុកូលដ្ឋាននៃជំពូកទី១ ស្តីពីអត្រានុកូលដ្ឋានកំណើត, កក្កដា ២០០៥, ទំព័រ៤៧(២.១.២)។
[29] អនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន, មាត្រា១៧(១)។
[30] អនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន, មាត្រា៤៣(១)។

## គ. លក្ខខណ្ឌ នៃការស្នើសុំចុះបញ្ជីកំណើត និងបញ្ជីបញ្ជាក់កំណើត

### គ.១. ទារកដែលមានឪពុកម្តាយមានចំណងអាពាហ៍ពិពាហ៍

បើមានកូនទើបកើត ឪពុក ឬម្តាយ មានកាតព្វកិច្ចត្រូវទៅរាយការណ៍ សុំចុះសៀវភៅអត្រានុកូលដ្ឋានកំណើតនៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាននៅសាលាឃុំ សង្កាត់នៃលំនៅដ្ឋានអចិន្ត្រៃយ៍របស់ឪពុក ម្តាយទារកនោះ មិនឱ្យហួស៣០ (សាមសិប) ថ្ងៃឡើយ ហើយអាចពឹងពាក់ញាតិជានីតិជនទៅជំនួសបាន ក្នុងករណីឪពុកម្តាយនៃទារកមានធុរៈ។[31]

### គ.២. ទារកដែលមានឪពុកម្តាយជាអនីតិសង្វាស

ទារកដែលកើតពីឪពុកម្តាយគ្មានចំណងអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ ក៏ត្រូវចុះក្នុងសៀវភៅកំណើតដែរ ដោយនៅពេលធ្វើសំបុត្រកំណើត បើឪពុកម្តាយគ្មានចំណងអាពាហ៍ពិពាហ៍នោះ បានឆ្លើយទទួលស្គាល់ដោយជាក់លាក់ ចំពោះមុខមន្ត្រីអត្រានុកូលដ្ឋានថា ទារកដែលកើតមកនោះជាកូនរបស់ខ្លួន មន្ត្រីអត្រានុកូលដ្ឋានត្រូវចាត់ទុកឪពុកម្តាយនោះថា ជាឪពុកម្តាយរបស់កូននោះ។[32]

ករណីមានតែឪពុក ឬមានតែម្តាយឆ្លើយទទួលស្គាល់តែម្នាក់ឯង ទារកនោះត្រូវចាត់ទុកថាជាកូនរបស់អ្នកដែលបានទទួលស្គាល់តែម្នាក់ឯងប៉ុណ្ណោះ។ ក្រោយពេលឪពុក ឬម្តាយបានប្តឹងចុះក្នុងសៀវភៅកំណើតរួចហើយ ឪពុកឬម្តាយណា ដែលមិនទាន់ទទួលស្គាល់ទារកនោះ អាចប្តឹងសុំទទួលស្គាល់កូនជាក្រោយបាន។

### គ.៣. ទារកដែលគ្មានឪពុកម្តាយ

#### គ.៣.១. ករណីគេបោះបង់ចោល

បើមានជនណារើសបានទារកដែលគេបោះបង់ចោល ត្រូវយកទៅប្រគល់ឱ្យមន្ត្រីអត្រានុកូលដ្ឋានក្នុងឃុំ ឬសង្កាត់នៃទីកន្លែងដែលបានរើសទារក។[33] មន្ត្រីអត្រានុកូលដ្ឋាន ត្រូវធ្វើកំណត់ហេតុ និងចុះក្នុងសៀវភៅកំណើត ដោយរកឈ្មោះដាក់ឱ្យ ហើយក្នុងករណីចាំបាច់ មន្ត្រីអត្រានុកូលដ្ឋានត្រូវពិគ្រោះយោបល់ជាមួយមន្ត្រីសុខាភិបាល ដើម្បីដាក់ថ្ងៃ ខែ ឆ្នាំ កំណើតទារកដែលរើសបាននោះ ដោយស្មាន និងឈ្មោះឪពុក ម្តាយថាមិនស្គាល់។

ក្នុងករណីគ្មានជនណាសុំទារកដែលរើសបាននោះ ធ្វើជាកូនចិញ្ចឹម មន្ត្រីអត្រានុកូលដ្ឋានត្រូវបញ្ជូនទារកដែលរើសបាននោះ ទៅមជ្ឈមណ្ឌលសង្គ្រោះទារក ឬមជ្ឈមណ្ឌលកុមារកំព្រាដែលនៅជិតបំផុត ដោយភ្ជាប់

[31] អនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន, មាត្រា១៧។

[32] អនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន, មាត្រា២៣។

[33] អនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន, មាត្រា១៩។

ជាមួយនូវសំបុត្រកំណើតរបស់ទារកនោះ និងកំណត់ហេតុស្តីពីការប្រគល់កូននោះ ជូនមជ្ឈមណ្ឌលសង្គ្រោះទារក ឬមជ្ឈមណ្ឌលកុមារកំព្រា។[34]

**ក.៣.២. ទារកស្ថិតក្នុងមជ្ឈមណ្ឌល**

ចំពោះទារក ឬកុមារ ដែលកំពុងចិញ្ចឹមបីបាច់ថែរក្សា ក្នុងមជ្ឈមណ្ឌលសង្គ្រោះទារក ឬមជ្ឈមណ្ឌលកុមារកំព្រា ហើយពុំទាន់មានសំបុត្រកំណើត ឬសំបុត្របញ្ជាក់កំណើត អ្នកទទួលខុសត្រូវនៃមជ្ឈមណ្ឌលទាំងនោះត្រូវធ្វើសេចក្តីរាយការណ៍ និងនាំទារក ឬកុមារនោះ ទៅជូនមន្ត្រីអត្រានុកូលដ្ឋាននៃឃុំ សង្កាត់ដែលមជ្ឈមណ្ឌលនោះតាំងនៅ ដើម្បីឱ្យមន្ត្រីអត្រានុកូលដ្ឋានផ្តល់សំបុត្រកំណើត ឬសំបុត្របញ្ជាក់កំណើត។[35]

**ក.៤. កូនសុំ**

ក្នុងករណីមានការសុំទារក ឬកុមារ ពីមជ្ឈមណ្ឌលសង្គ្រោះទារក ឬមជ្ឈមណ្ឌលកុមារកំព្រា ការសុំទារកដែលរើសបាន និងការសុំទារក ឬកូនពីឪពុក ម្តាយធ្វើជាកូនចិញ្ចឹម ត្រូវអនុវត្តតាមនីតិវិធីដែលច្បាប់បានកំណត់ ហើយត្រូវចុះក្នុងសៀវភៅអត្រានុកូលដ្ឋាន។[36]

**ក.៥. ទារកដែលកើតក្នុងមណ្ឌលអប់រំកែប្រែ ឬពន្ធនាគារ**

ពេលមានពិរុទ្ធជន ឬទណ្ឌិតណាម្នាក់បានសម្រាលកូនក្នុងមណ្ឌលអប់រំកែប្រែ ពេលនោះអ្នកទទួលខុសត្រូវនៃមណ្ឌលអប់រំកែប្រែត្រូវធ្វើកំណត់ហេតុអំពីទារកឱ្យបានត្រឹមត្រូវ ដោយទីកន្លែងកំណើតទារក ត្រូវយកតាមលំនៅដ្ឋានរបស់ឪពុក ឬរបស់ម្តាយទារកមុនពេលក្លាយជាទណ្ឌិត។[37]

បើទារកនោះមានឪពុកត្រឹមត្រូវនៅរស់ អ្នកទទួលខុសត្រូវនៃពន្ធនាគារត្រូវប្រគល់កំណត់ហេតុនោះឱ្យឪពុកទារកយកទៅចុះសៀវភៅអត្រានុកូលដ្ឋានកំណើតនៅឃុំ ឬសង្កាត់ ដែលខ្លួនកំពុងរស់នៅជាប់លាប់ឱ្យទាន់ក្នុងអំឡុងពេល ៣០ (សាមសិប) ថ្ងៃបន្ទាប់ពីទារកនោះកើត។[38]

ក្នុងករណីទារកពុំមានឪពុកច្បាស់លាស់ទេ អ្នកទទួលខុសត្រូវនៃពន្ធនាគារ ត្រូវបញ្ជូនកំណត់ហេតុទារកកើតទៅប្រគល់ឱ្យមន្ត្រីអត្រានុកូលដ្ឋាននៃលំនៅដ្ឋានដែលម្តាយទារកនោះរស់នៅជាប់លាប់ មុនពេលក្លាយជា ទណ្ឌិត ដើម្បីចុះសៀវភៅអត្រានុកូលដ្ឋានកំណើត។[39]

---

[34] អនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន, មាត្រា១៩(២)។

[35] អនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន, មាត្រា២០។

[36] អនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន, មាត្រា២១។

[37] អនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន, មាត្រា២១។

[38] កម្រងឯកសារស្តីពីរបៀបកត់ត្រាការងារអត្រានុកូលដ្ឋាននៃជំពូកទី១ ស្តីពីអត្រានុកូលដ្ឋានកំណើត, កក្កដា ២០០៥, ទំព័រ៤៨។

[39] កម្រងឯកសារស្តីពីរបៀបកត់ត្រាការងារអត្រានុកូលដ្ឋាននៃជំពូកទី១ ស្តីពីអត្រានុកូលដ្ឋានកំណើត, កក្កដា ២០០៥, ទំព័រ៤៩។

**ក.៦. ទារកដែលមានឪពុកម្ដាយជាពលរដ្ឋខ្មែរ រស់នៅឯបរទេស**

ទារកដែលកើតពីម្ដាយ ឪពុកជាពលរដ្ឋខ្មែរ រស់នៅស្របច្បាប់ឯបរទេស ឬពីឪពុកជាពលរដ្ឋខ្មែរ ម្ដាយជាជនបរទេស ឬពីឪពុកជាជនបរទេស ម្ដាយជាពលរដ្ឋខ្មែរ ឪពុកម្ដាយនៃទារកនោះ អាចសុំចុះសៀវភៅកំណើតនៅឯប្រទេសនោះតាមបញ្ញត្តិច្បាប់របស់ប្រទេសនោះ។ ពេលវិលត្រឡប់មកប្រទេសកម្ពុជាវិញ ត្រូវទៅចុះសៀវភៅកំណើតនៅឃុំ សង្កាត់ដែលខ្លួនរស់នៅតាមសំបុត្រកំណើតដែលប្រទេសនោះចេញឱ្យ ដោយយកសញ្ជាតិតាមច្បាប់សញ្ជាតិនៃព្រះរាជាណាចក្រកម្ពុជា។ មន្ត្រីអត្រានុកូលដ្ឋានត្រូវយកសំបុត្រកំណើតថតចម្លងផ្លូវការនោះទុក ហើយចម្លងចេញពីសៀវភៅ នូវសំបុត្រកំណើតថ្មី ឱ្យយកទៅប្រើប្រាស់។[40]

បើឪពុកម្ដាយនៃទារកនោះ បានទៅរាយការណ៍ចុះសៀវភៅកំណើតនៅឯស្ថានទូត ស្ថានអគ្គកុងស៊ុល ឬស្ថានកុងស៊ុល នៃព្រះរាជាណាចក្រកម្ពុជាប្រចាំនៅប្រទេសនោះ ពេលត្រឡប់មកប្រទេសកម្ពុជាវិញ អាចយកសំបុត្រកំណើតដែលប្រគល់ឱ្យនោះមកប្រើប្រាស់ជាផ្លូវការបាន។[41]

**ក.៧. ទារកដែលមានឪពុកម្ដាយជាជនអន្តោប្រវេសន៍រស់នៅកម្ពុជា**

ជនអន្តោប្រវេសន៍ និងជនបរទេស ដែលបានរស់នៅស្របច្បាប់លើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា បានកើតទារកនៅទឹកដីនៃប្រទេសកម្ពុជា ឪពុកម្ដាយទារកនោះ អាចទៅចុះសៀវភៅកំណើតនៅសាលាឃុំ សង្កាត់ដែលខ្លួនរស់នៅជាប់លាប់ ឬអាចទៅចុះសៀវភៅកំណើតនៅស្ថានទូត ស្ថានអគ្គកុងស៊ុល ឬស្ថានកុងស៊ុល នៃប្រទេសរបស់ខ្លួនប្រចាំនៅប្រទេសកម្ពុជា។[42]

**ខ. លិខិតស្នាមនានាក្នុងការស្នើសុំចុះបញ្ជីកំណើត និងបញ្ជីបញ្ជាក់កំណើត**

**ខ.១. លិខិតស្នាមនានាក្នុងការស្នើសុំចុះបញ្ជីកំណើត**

**ខ.១.១. ចំពោះទារកទើបនឹងកើត**

អ្នកទៅរាយការណ៍សុំចុះសៀវភៅអត្រានុកូលដ្ឋានកំណើត និងសំបុត្រកំណើតត្រូវបង្ហាញចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន នូវលិខិតស្នាមមួយចំនួនដូចជា លិខិតបញ្ជាក់ទទួលស្គាល់កំណើត សៀវភៅគ្រួសារ និង អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរដែលមានឈ្មោះឪពុកម្ដាយរបស់ទារក(ប្រសិនបើមាន) និង សេចក្ដីចម្លងសំបុត្រកំណើត ឬ សេចក្ដីចម្លងសំបុត្របញ្ជាក់កំណើត និងសេចក្ដីចម្លងសំបុត្រអាពាហ៍ពិពាហ៍ ឬ សេចក្ដីចម្លងសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ (ប្រសិនបើមាន)។[43]

---

[40] អនុក្រឹត្យស្ដីពីអត្រានុកូលដ្ឋាន, មាត្រា ២៦(១)។

[41] អនុក្រឹត្យស្ដីពីអត្រានុកូលដ្ឋាន, មាត្រា ២៦(២)។

[42] អនុក្រឹត្យស្ដីពីអត្រានុកូលដ្ឋាន, មាត្រា ២៧។

[43] កម្រងឯកសារស្ដីពីរបៀបកត់ត្រាការងារអត្រានុកូលដ្ឋាននៃជំពូកទី២ ស្ដីពីអត្រានុកូលដ្ឋានកំណើត, កក្កដា ២០០៥, ទំព័រ៤៩។

ចំពោះលិខិតបញ្ជាក់ទទួលស្គាល់កំណើត ត្រូវបានបែងចែកករណីផ្សេងៗទៀត ដោយយោងទៅតាមទីកន្លែងនៃកំណើត។ លិខិតទាំងនោះមានដូចជា៖[44]

- ករណីទារកកើតនៅមន្ទីរពេទ្យ ត្រូវមានលិខិតទទួលស្គាល់កំណើតរបស់មន្ទីរពេទ្យ
- ករណីទារកកើតនៅផ្ទះ ត្រូវមានលិខិតទទួលស្គាល់កំណើតរបស់មេភូមិ
- ករណីទារកកើតនៅក្នុងមណ្ឌលអប់រំកែប្រែ ឬពន្ធនាគារ ត្រូវមានកំណត់ហេតុអំពីកំណើតទារករបស់អ្នកទទួលខុសត្រូវមណ្ឌលអប់រំកែប្រែ ឬពន្ធនាគារ ឬលិខិតបញ្ជាក់ចេញដោយប៉ុស្តិ៍សុខភាពមណ្ឌលអប់រំកែប្រែ ឬពន្ធនាគារ។

ក្នុងករណីឪពុកម្តាយនៃទារកមានធុរៈ ហើយពឹងពាក់សាច់ញាតិជានីតិជនទៅជំនួស គឺត្រូវមានលិខិតបញ្ជាក់របស់ឪពុកម្តាយទារកអំពីនាមត្រកូល នាមខ្លួន និងថ្ងៃ ខែ ឆ្នាំកំណើតបន្ថែមទៀត។

**ខ.១.២. ចំពោះទារកដែលមានឪពុកម្តាយជាជនបរទេស រស់នៅក្នុងប្រទេសកម្ពុជា**

អ្នកទៅរាយការណ៍សុំចុះសៀវភៅអត្រានុកូលដ្ឋានកំណើត និងសំបុត្រកំណើតត្រូវបង្ហាញចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន នូវលិខិតស្នាមមួយចំនួនដូចជា លិខិតស្នើសុំចុះសៀវភៅអត្រានុកូលដ្ឋានកំណើត លិខិតទទួលស្គាល់កំណើតរបស់មន្ទីរពេទ្យបើទារកកើតនៅមន្ទីរពេទ្យ លិខិតឆ្លងដែននៃប្រទេសសាមីរបស់ឪពុកម្តាយទារក ទិដ្ឋាការដែលនៅមានសុពលភាព ឬបង្កាប់ដៃអនុញ្ញាតឱ្យស្នាក់នៅប្រទេសកម្ពុជាដែលនៅមានសុពលភាព និង សំបុត្រអាពាហ៍ពិពាហ៍ ឬ សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍ (ប្រសិនបើមាន)។[45]

**ខ.២. លិខិតស្នាមនានាក្នុងការស្នើសុំចុះបញ្ជីបញ្ជាក់កំណើត**

អ្នកដែលបានកើតហើយទុកហួសរយៈពេល ៣០ (សាមសិប) ថ្ងៃ ហើយពុំទាន់មានសំបុត្រកំណើតប្រើប្រាស់ សាមីខ្លួន ឬឪពុក ឬម្តាយ ឬអាណាព្យាបាល ត្រូវប្ដឹងសុំចុះសៀវភៅអត្រានុកូលដ្ឋានបញ្ជាក់កំណើត នៅសាលាឃុំ សង្កាត់សាមី ដែលខ្លួនរស់នៅពិតប្រាកដបច្ចុប្បន្ន នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ដោយនាំទៅជាមួយនូវសាក្សីចំនួន ០២ (ពីរ) រូប ជានីតិជន ហើយត្រូវមានលំនៅដ្ឋានពិតប្រាកដ។[46]

សាមីខ្លួន និងសាក្សី ត្រូវយកជាប់ជាមួយលិខិតស្នាមចាំបាច់មួយចំនួនដូចជា សៀវភៅគ្រួសាររបស់សាមីខ្លួន និងរបស់សាក្សី ឬអត្តសញ្ញាណប័ណ្ណរបស់សាមីខ្លួន និងរបស់សាក្សី ។ ក្នុងករណីមន្ត្រីរាជការដែល

[44] កម្រងឯកសារស្តីពីរបៀបកត់ត្រាការងារអត្រានុកូលដ្ឋាននៃជំពូកទី២ ស្តីពីអត្រានុកូលដ្ឋានកំណើត, កក្កដា ២០០៥, ទំព័រ៤៩។

[45] កម្រងឯកសារស្តីពីរបៀបកត់ត្រាការងារអត្រានុកូលដ្ឋាននៃជំពូកទី២ ស្តីពីអត្រានុកូលដ្ឋានកំណើត, កក្កដា ២០០៥, ទំព័រ៥៩។

[46] អនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន, មាត្រា៤៣(១)។

បានទទួលបៀវត្ស ឬទទួលសោធននិវត្តន៍ ត្រូវយកឯកសារបៀវត្ស ឬសោធននិវត្តន៍ ឬសេចក្តីបញ្ជាក់ពីស្ថាប័នសាមី ដើម្បីសុំចុះបញ្ជីបញ្ជាក់កំណើត។[47]

**គ. ការចុះបញ្ជី និងការទទួលបានសំបុត្រកំណើត ឬសំបុត្របញ្ជាក់កំណើត**

នៅពេលមានអ្នកមករាយការណ៍អំពីកំណើត និងបន្ទាប់ពីពិនិត្យលិខិតស្នាមឃើញថាត្រឹមត្រូវទៅតាមការកំណត់សព្វគ្រប់ហើយ មន្ត្រីអត្រានុកូលដ្ឋានត្រូវសរសេរចុះបញ្ជីកំណើត ឬបញ្ជីបញ្ជាក់កំណើត ចំនួន០២ (ពីរ) ច្បាប់ មានខ្លឹមសារដូចគ្នាទាំងស្រុង នៅក្នុងសៀវភៅអត្រានុកូលដ្ឋានកំណើតភ្លាះ ឬសៀវភៅអត្រានុកូលដ្ឋានបញ្ជាក់កំណើតភ្លាះ។

បន្ទាប់មក មន្ត្រីអត្រានុកូលដ្ឋានត្រូវរក្សាលិខិតស្នាមចាំបាច់ដូចជា៖

- ចំពោះទារកទើបកើត ត្រូវរក្សាទុកលិខិតទទួលស្គាល់កំណើត[48]
- ចំពោះទារកទើបដែលមានឪពុកម្តាយជាជនបរទេស ត្រូវរក្សាទុកលិខិតទទួលស្គាល់កំណើត លិខិតស្នើសុំចុះសៀវភៅអត្រានុកូលដ្ឋានកំណើត និងច្បាប់ថតចម្លងលិខិតឆ្លងដែននៃប្រទេសសាមីរបស់ឪពុកម្តាយទារក ទិដ្ឋាការ ឬបង្កាន់ដៃអនុញ្ញាតឱ្យស្នាក់នៅប្រទេសកម្ពុជា[49]
- ចំពោះការចុះបញ្ជីបញ្ជាក់កំណើតត្រូវទទួលទុក ច្បាប់ថតចម្លងសៀវភៅគ្រួសាររបស់សាមីខ្លួន និងរបស់សាក្សី ឬច្បាប់ថតចម្លងអត្តសញ្ញាណប័ណ្ណរបស់សាមីខ្លួន និងរបស់សាក្សី ឬច្បាប់ថតចម្លងឯកសារបៀវត្ស ឬសោធននិវត្តន៍ ឬសេចក្តីបញ្ជាក់ពីស្ថាប័នសាមី។[50]

ជាចុងក្រោយ មន្ត្រីអត្រានុកូលដ្ឋានត្រូវប្រគល់ឱ្យអ្នករាយការណ៍នូវសំបុត្រកំណើត ឬសំបុត្របញ្ជាក់កំណើតច្បាប់ដើមចំនួន០១ (មួយ) សន្លឹក និងចេញសេចក្តីចម្លងតាមការស្នើសុំរបស់សាមីខ្លួន។[51] មន្ត្រីអត្រានុកូលដ្ឋានត្រូវជម្រាបអ្នកមករាយការណ៍ថា សំបុត្រកំណើត ឬសំបុត្របញ្ជាក់កំណើតច្បាប់ដើម គឺជាឯកសារផ្ទាល់ខ្លួនមានតែមួយច្បាប់ប៉ុណ្ណោះ ដូច្នេះហើយគប្បីធ្វើសេចក្តីចម្លងសំបុត្រកំណើត ឬសេចក្តីចម្លងសំបុត្របញ្ជាក់កំណើតដើម្បីយកទៅប្រើប្រាស់ជំនួសវិញ។

**២.១.៣. សេចក្តីចម្លង ឬសម្រង់សំបុត្រកំណើត និងសំបុត្របញ្ជាក់កំណើត**

ការសុំចម្លង ឬសម្រង់សំបុត្រកំណើត និងសំបុត្របញ្ជាក់កំណើត ក្នុងឆ្នាំមិនទាន់ដាច់ ត្រូវធ្វើឡើងនៅសាលាឃុំ សង្កាត់ ដោយត្រូវចុះហត្ថលេខា និងបោះត្រាដោយមន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់។ រីឯការសុំចម្លង

---

[47] អនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន, មាត្រា៤៣(២)។
[48] កម្រងឯកសារស្តីពីរបៀបកត់ត្រាការងារអត្រានុកូលដ្ឋាននៃជំពូកទី២ ស្តីពីអត្រានុកូលដ្ឋានកំណើត, កក្កដា ២០០៥, ទំព័រ៥០។
[49] កម្រងឯកសារស្តីពីរបៀបកត់ត្រាការងារអត្រានុកូលដ្ឋាននៃជំពូកទី២ ស្តីពីអត្រានុកូលដ្ឋានកំណើត, កក្កដា ២០០៥, ទំព័រ៥៩។
[50] កម្រងឯកសារស្តីពីរបៀបកត់ត្រាការងារអត្រានុកូលដ្ឋាននៃជំពូកទី២ ស្តីពីអត្រានុកូលដ្ឋានកំណើត, កក្កដា ២០០៥, ទំព័រ៦៦។
[51] អនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន, មាត្រា៤៤។

ឬសម្រង់សំបុត្រកំណើត និងសំបុត្របញ្ជាក់កំណើត ក្នុងឆ្នាំដែលកន្លងផុតទៅវិញ ត្រូវធ្វើឡើងនៅសាលាក្រុង ស្រុក ខណ្ឌសាមី ដោយត្រូវចុះហត្ថលេខាដោយមន្ត្រីរក្សាសៀវភៅអត្រានុកូលដ្ឋាន និងត្រូវបញ្ជាក់ហត្ថលេខានោះដោយអភិបាល ឬអភិបាលរងក្រុង ស្រុក ខណ្ឌប្រតិភូកម្ម និងបោះត្រាផង។ [52]

ក្នុងករណី ប្រជាពលរដ្ឋខ្មែររស់នៅស្របច្បាប់ឯបរទេស ដែលបានចុះសៀវភៅអត្រានុកូលដ្ឋានកំណើតនៅស្ថានទូត ស្ថានអគ្គកុងស៊ុល ឬស្ថានកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជាប្រចាំនៅប្រទេសនោះ ការសុំចម្លង ឬសម្រង់សំបុត្រកំណើត ក្នុងឆ្នាំមិនទាន់ដាច់ ត្រូវធ្វើឡើងនៅស្ថានទូត ស្ថានអគ្គកុងស៊ុល ឬស្ថានកុងស៊ុលនោះ ចុះហត្ថលេខាដោយមន្ត្រីអត្រានុកូលដ្ឋាននៅទីនោះ និងត្រូវបញ្ជាក់ហត្ថលេខានោះដោយឯកអគ្គរាជទូត អគ្គកុងស៊ុល ឬកុងស៊ុល និងបោះត្រាផង។ រីឯការសុំចម្លង ឬសម្រង់សំបុត្រកំណើត ក្នុងឆ្នាំដែលកន្លងផុតទៅវិញ ត្រូវធ្វើឡើងនៅក្រសួងមហាផ្ទៃ ដែលមានសៀវភៅអត្រានុកូលដ្ឋានឆ្នាំចាស់តម្កល់ទុក។ [53]

សម្រង់សំបុត្រកំណើត និងសម្រង់សំបុត្របញ្ជាក់កំណើត ត្រូវស្រង់ចេញពីសៀវភៅអត្រានុកូលដ្ឋានកំណើត និងសៀវភៅអត្រានុកូលដ្ឋានកំណើតដែលតម្កល់ទុក ដោយស្រង់យកតែខ្លឹមសារ តាមសំណើរបស់អ្នកមកសុំស្រង់តែប៉ុណ្ណោះ។[54]

ចំពោះការសុំចម្លង ឬសម្រង់សំបុត្រកំណើត និងសំបុត្របញ្ជាក់កំណើត អ្នកស្នើសុំត្រូវយកសំបុត្រកំណើត ឬសំបុត្របញ្ជាក់កំណើតច្បាប់ដើមមកជាមួយ។ ក្នុងករណីបាត់បង់សំបុត្រអត្រានុកូលដ្ឋានច្បាប់ដើម អ្នកមកសុំអាចសុំចម្លងបាន ត្រូវមានលក្ខខណ្ឌដូចជា រាយការណ៍ជាលាយលក្ខណ៍អក្សរឱ្យបានច្បាស់លាស់អំពីមូលហេតុនៃបានបាត់បង់ និងត្រូវបញ្ជាក់ពីឃុំ ឬសង្កាត់ លេខសៀវភៅ ឬលេខបញ្ជី និងឆ្នាំដែលបានចុះសៀវភៅអត្រានុកូលដ្ឋាន។[55]

## ២.២. អត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍

### ២.២.១. សញ្ញាណទូទៅនៃអាពាហ៍ពិពាហ៍

អាពាហ៍ពិពាហ៍ គឺជាកិច្ចសន្យាដ៏ឱឡារិកដែលធ្វើឡើងដោយបុរសម្នាក់ និងស្ត្រីម្នាក់ ដែលប្ដេជ្ញាថាខ្លួននឹងរួមសមគ្គសង្វាសជាមួយគ្នាតាមបញ្ញត្តិច្បាប់ ហើយមិនអាចរំលាយទៅវិញបានតាមទំនើងចិត្តរបស់ខ្លួន

[52] កម្រងឯកសារស្ដីពីរបៀបកត់ត្រាការងារអត្រានុកូលដ្ឋាននៃជំពូកទី២ ស្ដីពីអត្រានុកូលដ្ឋានកំណើត, កក្កដា ២០០៥, ទំព័រ៧៤(១,២)។

[53] កម្រងឯកសារស្ដីពីរបៀបកត់ត្រាការងារអត្រានុកូលដ្ឋាននៃជំពូកទី២ ស្ដីពីអត្រានុកូលដ្ឋានកំណើត, កក្កដា ២០០៥, ទំព័រ៧៤(៣)។

[54] កម្រងឯកសារស្ដីពីរបៀបកត់ត្រាការងារអត្រានុកូលដ្ឋាននៃជំពូកទី២ ស្ដីពីអត្រានុកូលដ្ឋានកំណើត, កក្កដា ២០០៥, ទំព័រ៨៣។

[55] កម្រងឯកសារស្ដីពីរបៀបកត់ត្រាការងារអត្រានុកូលដ្ឋាននៃជំពូកទី២ ស្ដីពីអត្រានុកូលដ្ឋានកំណើត, កក្កដា ២០០៥, ទំព័រ៧៤(៤,៥)។

ឡើយ។[56] ដើម្បីឱ្យអាពាហ៍ពិពាហ៍មួយមានអានុភាពតាមផ្លូវច្បាប់បាន ភាគីទាំងពីរ ត្រូវតែអនុវត្ត និងគោរពតាមលក្ខខណ្ឌដែលក្រមរដ្ឋប្បវេណី និងបទប្បញ្ញត្តិច្បាប់ដទៃទៀតដែលចូលជាធរមាន។

## ២.២.២. លក្ខខណ្ឌនៃការបង្កើត និងការហាមឃាត់ក្នុងការរៀបអាពាហ៍ពិពាហ៍

### ក. លក្ខខណ្ឌនៃការបង្កើតអាពាហ៍ពិពាហ៍

#### ក.១. ភេទរបស់ភាគី

ការរៀបអាពាហ៍ពិពាហ៍ គឺត្រូវធ្វើឡើងរវាងបុរស និងនារី។[57] ហើយនៅក្នុងមាត្រា ៩៤៨ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ បានចែងពាក់ព័ន្ធអំពីការដល់នីតិភាពដែលអាចរៀបអាពាហ៍ពិពាហ៍បានរវាងភាគីដែលជាបុរស និងស្ត្រី។[58] ទោះបីជាបណ្តាប្រទេសជាច្រើននៅលើពិភពលោក ទទួលស្គាល់ និងផ្តល់សិទ្ធិដល់បុគ្គលដែលមានភេទដូចគ្នា អាចរៀបអាពាហ៍ពាហ៍ជាមួយគ្នាដោយស្របច្បាប់បានក៏ដោយ ប៉ុន្តែច្បាប់នៅក្នុងប្រទេសកម្ពុជា ពុំទទួលស្គាល់ការរៀបអាពាហ៍ពិពាហ៍របស់បុគ្គលដែលមានភេទដូចគ្នានោះឡើយ។

ជាក់ស្តែង ក្នុងករណីមួយចំនួន យើងឃើញមានការចុះផ្សាយអំពីការរៀបអាពាហ៍ពិពាហ៍របស់បុគ្គលដែលមានភេទដូចគ្នានៅក្នុងប្រទេសកម្ពុជា ប៉ុន្តែចំណងអាពាហ៍ពិពាហ៍ទាំងនោះមិនត្រូវបានអនុញ្ញាត ឬទទួលស្គាល់ដោយច្បាប់ឡើយ ។ ដូច្នេះ ការរៀបអាពាហ៍ពិពាហ៍ គឺចាំបាច់ត្រូវធ្វើឡើងរវាងបុគ្គលដែលមានភេទផ្ទុយគ្នា ពោលគឺ បុរសម្នាក់ និងស្ត្រីម្នាក់។

#### ក.២. លក្ខខណ្ឌអាយុ

ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ បានកំណត់នូវលក្ខខណ្ឌអាយុយ៉ាងជាក់លាក់  ដោយភាគីទាំងពីរដែលបានដល់នីតិភាពគឺត្រូវបានអនុញ្ញាតឱ្យរៀបអាពាហ៍ពិពាហ៍បាន។[59] ជាគោលការណ៍ នីតិភាពនៃរូបវន្តបុគ្គល គឺអាយុចាប់ពី ១៨ឆ្នាំឡើងទៅ។[60] ក្នុងករណីដែលភាគីម្ខាងបានដល់នីតិភាព ហើយភាគីម្ខាងទៀតជាអនីតិជនដែលមានអាយុមិនតិចជាង១៦ឆ្នាំ ត្រូវមានការយល់ព្រមពីអ្នកដែលមានអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជននោះ ទើបអាចរៀបអាពាហ៍ពិពាហ៍បាន។[61] ប៉ុន្តែអនីតិជនដែលទទួលបានអត្តាធីនភាព ត្រូវបានចាត់ទុកថា បានដល់នីតិជន[62] អាចរៀបអាពាហ៍ពិពាហ៍បានដោយមិនចាំបាច់មានការយល់ព្រមពីអ្នកដែល

---

[56] ច្បាប់ស្តីពីអាពាហ៍ពិពាហ៍និងគ្រួសារ, លេខ ៥៦ ក្រ, ២៦ កក្កដា ១៩៨៩, មាត្រា ៣ (តទៅហៅថា ច្បាប់ស្តីពីអាពាហ៍ពិពាហ៍និងគ្រួសារ)។

[57] ច្បាប់ស្តីពីឯកពន្ធភាព, នស/រកម/១០០៦/០២៦, ២១ តុលា ២០០៦, មាត្រា២ (តទៅហៅថា ច្បាប់ស្តីពីឯកពន្ធភាព)។

[58] ក្រមរដ្ឋប្បវេណី, មាត្រា៩៤៨។

[59] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៤៨ (តទៅហៅថា ក្រមរដ្ឋប្បវេណី)។

[60] ក្រមរដ្ឋប្បវេណី, មាត្រា១៧។

[61] ក្រមរដ្ឋប្បវេណី, មាត្រា៩៤៨។

[62] ក្រមរដ្ឋប្បវេណី, មាត្រា២២។

មានអំណាចមេបាឡើយ។ អនីតិជននឹងទទួលបានអត្តាធីនភាពក្នុងករណីពីរយ៉ាងគឺ តាមរយៈដីកាសម្រេច របស់តុលាការតាមពាក្យសុំរបស់អនីតិជនដែលបានដល់អាយុ ១៦(ដប់ប្រាំមួយ) ឆ្នាំ និងតាមរយៈការរៀប អាពាហ៍ពិពាហ៍របស់អនីតិជននោះ។[63]

**គ.៣. លក្ខខណ្ឌទាក់ទងនឹងសមត្ថភាពក្នុងការបង្ហាញឆន្ទៈ**

ភាគីនៃចំណងអាពាហ៍ពិពាហ៍ គឺត្រូវតែមានសមត្ថភាពក្នុងការបង្ហាញឆន្ទៈ។ ប៉ុន្តែក្នុងករណីដែលជន នៅក្រោមអាណាព្យាបាលទូទៅ អាចមានសមត្ថភាពក្នុងការបង្ហាញឆន្ទៈក្នុងការរៀបអាពាហ៍ពិពាហ៍ ក្នុងកម្រិត អប្បបរមា ដែលចាំបាច់ដើម្បីរៀបអាពាហ៍ពិពាហ៍ នោះសកម្មភាពទាំងនោះនឹងអាចប្រព្រឹត្តទៅបាន ដោយមិនចាំ បាច់មានការយល់ព្រមពីអ្នកអាណាព្យាបាលទូទៅឡើយ។[64] សូមបញ្ជាក់ផងដែរ ជននៅក្រោមអាណាព្យាបាល ទូទៅ គឺជាជនដែលស្ថិតនៅក្នុងស្ថានភាពជានិរន្តរ៍ដែលខ្វះសមត្ថភាពក្នុងការយល់ដឹង និងវិនិច្ឆ័យអំពីលទ្ធភាព តាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួនដោយសារមានវិបត្តិផ្នែកបញ្ញាស្មារតី ដូចជាជនវិកលចរិតជាដើម។[65]

ចំពោះការបង្ហាញឆន្ទៈក្នុងការរៀបអាពាហ៍ពិពាហ៍របស់ជននៅក្រោមហិតូបត្ថម្ភវិញគឺអាចអនុវត្តទៅបាន ដោយមិនចាំបាច់មានការយល់ព្រមពីហិតូបត្ថម្ភកៈឡើយ។ [66] ជននៅក្រោមហិតូបត្ថម្ភ គឺជាជនដែលមានសមត្ថ ភាពតិចតួចក្នុងការយល់ដឹង និងវិនិច្ឆ័យអំពីលលទ្ធផលតាមផ្លូវច្បាប់អំពីសកម្មភាពរបស់ខ្លួន ដោយសារមាន វិបត្តិផ្នែកស្មារតី។[67]

**គ.៤. លក្ខខណ្ឌនៃការព្រមព្រៀង**

អាពាហ៍ពិពាហ៍ ត្រូវធ្វើឡើងតាមលក្ខខណ្ឌដែលមានចែងនៅក្នុងច្បាប់ និងតាមគោលការណ៍ស្ម័គ្រចិត្ត ប្ដីមួយប្រពន្ធមួយ។[68] ដូច្នេះភាគីទាំងសងខាងត្រូវតែមានការស្ម័គ្រចិត្ត ចេញពីឆន្ទៈពិតប្រាកដរបស់ខ្លួន ដោយ មិនមានការបង្ខំ ការគំរាមកំហែង និងការឆបោកពីភាគីណាមួយឡើយ។

**ខ. លក្ខខណ្ឌនៃការហាត់ឃាត់ក្នុងការរៀបអាពាហ៍ពិពាហ៍**

**ខ.១. ការហាមឃាត់មិនឱ្យមានទ្វេពន្ធភាព**

បុគ្គលដែលមានប្ដី ឬប្រពន្ធហើយ ពុំអាចរៀបអាពាហ៍ពិពាហ៍ទៀតបានឡើយ។[69] មិនតែប៉ុណ្ណោះ បុគ្គលដែលមានប្ដីពីរ ឬប្រពន្ធពីរនៅក្នុងចំណងអាពាហ៍ពិពាហ៍ ត្រូវចាត់ទុកថាមានពិរុទ្ធភាពក្នុងបទទ្វេពន្ធភាព

---

[63] ក្រមរដ្ឋប្បវេណី, មាត្រា២១។
[64] ក្រមរដ្ឋប្បវេណី, មាត្រា៩៥៤។
[65] ក្រមរដ្ឋប្បវេណី, មាត្រា២៤។
[66] ក្រមរដ្ឋប្បវេណី, មាត្រា៣០។
[67] ក្រមរដ្ឋប្បវេណី, មាត្រា២៨។
[68] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ឆ្នាំ១៩៩៣, មាត្រា៤៥(៤)។
[69] ក្រមរដ្ឋប្បវេណី, មាត្រា៩៤៩។

មានន័យថា បុរស ឬស្ត្រីណាដែលមានចំណងអាពាហ៍ពិពាហ៍ពីមុនមិនទាន់រលាយនៅឡើយ ហើយទៅចុះបញ្ជីអាពាហ៍ពិពាហ៍ថ្មីមួយទៀត[70] នឹងត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ)ខែ ដល់ ១ (មួយ) ឆ្នាំ និងផ្តន្ទាទោសពិន័យជាប្រាក់ពី ២០០.០០០ (ពីររយពាន់) រៀល ដល់ ១.០០០.០០០ (មួយលាន) រៀល ឬផ្តន្ទាទោសណាមួយនៃទោសទាំងពីរ។[71]

**ខ.២. អំឡុងពេលហាមឃាត់មិនឱ្យរៀបអាពាហ៍ពិពាហ៍ថ្មីមួយទៀត**

ការរៀបអាពាហ៍ពិពាហ៍ថ្មីម្តងទៀត របស់ភាគីខាងបុរសអាចកើតឡើងនៅពេលណាក៏បាន ក្រោយបញ្ចប់អាពាហ៍ពិពាហ៍មុន ប៉ុន្តែចំពោះស្ត្រីដែលមានបំណងចង់រៀបអាពាហ៍ពិពាហ៍ម្តងទៀត ត្រូវរង់ចាំ១២០ (មួយរយម្ភៃ) ថ្ងៃ គិតចាប់ពីថ្ងៃដែលអាពាហ៍ពិពាហ៍មុន ត្រូវបានរំលាយ ឬលុបចោល។[72] ទោះជាយ៉ាងនេះក្តី ក៏មានករណីលើកលែងផងដែរ ចំពោះស្ត្រីដែលមានផ្ទៃពោះនៅមុនពេលដែលអាពាហ៍ពិពាហ៍ចាស់ត្រូវបានរំលាយ ឬលុបចោល ហើយបានសម្រាលកូន និងស្ត្រីដែលមានលិខិតបញ្ជាក់ពីវេជ្ជបណ្ឌិតថាគ្មានផ្ទៃពោះ គឺអាចរៀបអាពាហ៍ពិពាហ៍ថ្មីបាន ដោយពុំចាំបាច់រង់ចាំដល់រយៈពេល ១២០(មួយរយម្ភៃ) ថ្ងៃនោះទេ។[73]

**ខ.៣. ការហាមឃាត់ទាក់ទិននឹងទំនាក់ទំនងញាតិ**

ហាមឃាត់ការរៀបអាពាហ៍ពិពាហ៍រវាងញាតិលោហិតផ្ទាល់ ឬសាខាញាតិលោហិតក្នុងបីថ្នាក់ ទោះបីជាក្រោយពេលដែលទំនាក់ទំនងញាតិត្រូវបានបញ្ចប់ដោយការបញ្ចប់ញាតិ ជាមួយឪពុកម្តាយបង្កើតដោយការសុំកូនពេញលេញ ឬដោយសារការកាត់កាល់សុំកូនពេញលេញ ឬដោយសារការកាត់កាល់សុំកូនធម្មតា។[74]

ហាមឃាត់ការរៀបអាពាហ៍ពិពាហ៍រវាងញាតិពន្ធនៃខ្សែផ្ទាល់ (គ្រប់ថ្នាក់ទាំងអស់) ទោះបីជាក្រោយពេលដែលទំនាក់ទំនងញាតិពន្ធត្រូវបានបញ្ចប់ ដោយសារការលែងលះ មរណភាពរបស់សហព័ទ្ធម្ខាង ឬការកាត់កាល់សុំកូនពេញលេញក៏ដោយ។[75] ហាមឃាត់ការរៀបអាពាហ៍ពិពាហ៍រវាងសាខាញាតិពន្ធ នៅក្នុង៣ (បី) ថ្នាក់ រាប់ទាំងថ្នាក់ទី៣ (បី) ផង ទោះបីបានបញ្ចប់ញាតិពន្ធដោយសារការលែងលះក៏ដោយ។ ក៏ប៉ុន្តែ បើសហព័ទ្ធណាម្ខាងបានទទួលមរណភាព សហព័ទ្ធដែលនៅរស់អាចរៀបអាពាហ៍ពិពាហ៍ជាមួយបុគ្គលដែលធ្លាប់ជាសាខាញាតិនៅក្នុង ៣ (បី) ថ្នាក់បាន។[76]

---

[70] ច្បាប់ស្តីពីឯកពន្ធភាព, មាត្រា៥។
[71] ច្បាប់ស្តីពីឯកពន្ធភាព, មាត្រា៩។
[72] ក្រមរដ្ឋប្បវេណី, មាត្រា៩៥០(១)។
[73] ក្រមរដ្ឋប្បវេណី, មាត្រា៩៥០(២)។
[74] ក្រមរដ្ឋប្បវេណី, មាត្រា៩៥១។
[75] ក្រមរដ្ឋប្បវេណី, មាត្រា៩៥២(១)។
[76] ក្រមរដ្ឋប្បវេណី, មាត្រា៩៥២(២)។

### ២.២.៣. នីតិវិធីនៃការស្នើសុំសំបុត្រអាពាហ៍ពិពាហ៍

អាពាហ៍ពិពាហ៍នឹងមានអានុភាព ដោយការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ការជូនដំណឹងជាសាធារណៈ ការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ និងការចុះបញ្ជីអាពាហ៍ពិពាហ៍នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ដែលត្រូវធ្វើដោយផ្អែកតាមនីតិវិធី ដែលបានកំណត់នៅក្នុងបទប្បញ្ញត្តិស្តីពីការចុះបញ្ជីអត្រានុកូលដ្ឋាន។

**ក.ការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងពលរដ្ឋខ្មែរ**

**ក.១. ការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍**

បុរស និងនារីដែលមានបំណងរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ត្រូវដាក់ពាក្យសុំច្បាប់អាពាហ៍ពិពាហ៍ទៅមន្ត្រីអត្រានុកូលដ្ឋាននៃឃុំ សង្កាត់ នៃលំនៅដ្ឋានសាមីខ្លួនខាងនារី ។[77]

នៅពេលដែលមកសុំច្បាប់រៀបអាពាហ៍ពិពាហ៍ បុរស និងនារីត្រូវភ្ជាប់មកជាមួយនូវលិខិតស្នាមមួយចំនួនដូចជា សេចក្តីចម្លងសំបុត្រកំណើត ឬសេចក្តីចម្លងសំបុត្របញ្ជាក់កំណើត លិខិតបញ្ជាក់ភាពនៅលីវ ឬមេម៉ាយ ឬពោះម៉ាយរបស់សាមីខ្លួនទាំងពីរ ដែលចេញដោយមេឃុំ ឬចៅសង្កាត់សាមី និងសៀវភៅគ្រួសារដែលមានទិន្នន័យរបស់សាមីខ្លួនទាំងពីរនាក់ច្បាស់លាស់ និងត្រឹមត្រូវ។ ក្នុងករណីមេម៉ាយ ឬពោះម៉ាយ ត្រូវបង្ហាញពីភស្តុតាងនៃការបញ្ចប់អាពាហ៍ពាហ៍ដូចជា សាលក្រមលែងលះ ឬសេចក្តីចម្លងសំបុត្រមរណភាព ឬមោឃភាពនៃអាពាហ៍ពិពាហ៍។

នៅពេលទទួលបានពាក្យសុំច្បាប់រៀបអាពាហ៍ពិពាហ៍ មន្ត្រីអត្រានុកូលដ្ឋាននឹងពិនិត្យពាក្យសុំឱ្យបានហ្មត់ចត់ ប្រសិនបើមានលក្ខណៈត្រឹមត្រូវទៅតាមលក្ខខណ្ឌនៃក្រមរដ្ឋប្បវេណី និងបទប្បញ្ញត្តិនៃអត្រានុកូលដ្ឋាន ហើយ មន្ត្រីអត្រានុកូលដ្ឋានត្រូវចេញប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ឱ្យទៅភាគីទាំងពីរដើម្បីយកទៅបិទផ្សាយជាសាធារណៈ។

**ក.២ ការជូនដំណឹងជាសាធារណៈ**

មន្ត្រីអត្រានុកូលដ្ឋានត្រូវចេញប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ជាចំនួន ០៥ (ប្រាំ) ច្បាប់ ដោយ ០១(មួយ) ច្បាប់ ត្រូវបិទផ្សាយជាសាធារណៈ នៅលំនៅឋានរបស់ខាងនារី ០២(ពីរ) ច្បាប់ បិទផ្សាយជាសាធារណៈ និងរក្សាទុកជាឯកសារ នៅសាលាឃុំ ឬសង្កាត់របស់ខាងនារី និង ០២(ច្បាប់) ច្បាប់ទៀត ត្រូវផ្ញើទៅជូនមន្ត្រីអត្រានុកូលដ្ឋានខាងបុរស ដើម្បីយកទៅបិទផ្សាយជាសាធារណៈនៅលំនៅឋានខាងបុរសមួយច្បាប់ និងរក្សាទុកនៅសាលាឃុំ ឬសង្កាត់ខាងបុរសមួយច្បាប់។[78]

[77] អនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន, មាត្រា២៨។

[78] អនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន, មាត្រា២៩(១)។

ប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ត្រូវចុះព័ត៌មានដូចជា នាមត្រកូល នាមខ្លួន អាយុ មុខរបរ និងលំនៅឋាន នៃអនាគត ប្ដីប្រពន្ធ នាមត្រកូល នាមខ្លួន អាយុ មុខរបរ និងទីលំនៅរបស់ឪពុកម្ដាយរបស់អនាគត ប្ដីប្រពន្ធ(បើឪពុក ឬម្ដាយស្លាប់ ត្រូវដាក់ថាស្លាប់) និងរយៈពេលដែលភាគីពាក់ព័ន្ធអាចប្ដឹងជំទាស់បាន។[79]

ប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ ត្រូវបិទផ្សាយជាសាធារណៈក្នុងរយៈពេល ១០ (ដប់) ថ្ងៃ មុនថ្ងៃរៀបអាពាហ៍ពិពាហ៍តាមប្រពៃណី ឬថ្ងៃចុះបញ្ជីអាពាហ៍ពិពាហ៍ ដើម្បីឱ្យជនដែលមានផលប្រយោជន៍ក្នុងរឿងនោះ អាចប្ដឹងជំទាស់នឹងអាពាហ៍ពិពាហ៍នោះបាន ហើយប្រសិនបើគ្មានការប្ដឹងក្នុងរយៈពេលដែលបានកំណត់នេះទេ អាពាហ៍ពិពាហ៍នោះគឺអាចប្រព្រឹត្តទៅបាន។[80]

ក្នុងករណីមានបណ្ដឹងជំទាស់កើតឡើង អាពាហ៍ពិពាហ៍ប្រព្រឹត្តទៅបាន លុះត្រាតែមន្ត្រីអត្រានុកូលដ្ឋាន បានដោះស្រាយនូវបណ្ដឹងនោះចប់សព្វគ្រប់។ បណ្ដឹងជំទាស់ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ និងបញ្ជាក់ពីមូលហេតុនៃបណ្ដឹងឱ្យបានច្បាស់លាស់ ដោយត្រូវដាក់ជូននៅសាលាឃុំ ឬសង្កាត់ខាងលំនៅឋានរបស់អនាគតភរិយា។ នៅក្នុងច្បាប់ស្ដីពីអាពាហ៍ពិពាហ៍ និងគ្រួសារ បានកំណត់នូវនីតិវិធីមួយចំនួនដូចជា សាលាឃុំសង្កាត់ត្រូវធ្វើការដោះស្រាយ និងសម្រេចក្នុងរយៈពេល ០៣ (បី) ថ្ងៃ ប្រសិនបើអ្នកដាក់ពាក្យប្ដឹង ឬអនាគតប្ដីប្រពន្ធ មិនសុខចិត្តនឹងសេចក្ដីសម្រេចនោះទេ អាចប្ដឹងជំទាស់បាន ដោយសាលាឃុំសង្កាត់ត្រូវបញ្ជូនសំណុំរឿងទៅតុលាការ ក្នុងរយៈពេល ០៥ (ប្រាំ) ថ្ងៃ គិតចាប់ពីថ្ងៃប្ដឹងជំទាស់។[81] បន្ទាប់មក តុលាការត្រូវចេញសេចក្ដីសម្រេចក្នុងរយៈពេល ០៧ (ប្រាំពីរ) ថ្ងៃ យ៉ាងយូរគិតចាប់ពីថ្ងៃទទួលសំណុំរឿង ហើយភាគីដែលពាក់ព័ន្ធមិនអាចប្ដឹងតវ៉ានឹងសេចក្ដីសម្រេចរបស់តុលាការបានឡើយ។[82]

**ក.៣. ការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ និងការទទួលបានសំបុត្រអាពាហ៍ពិពាហ៍**

បុរស និងនារីដែលបានរៀបអាពាហ៍ពិពាហ៍រួចរាល់ហើយ ត្រូវបំពេញកាតព្វកិច្ចរបស់ខ្លួនចុងក្រោយគឺការទៅចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ ដើម្បីទទួលបានសំបុត្រអាពាហ៍ពិពាហ៍ដែលមានលក្ខណៈត្រឹមត្រូវ និងទទួលស្គាល់ដោយច្បាប់។ បុរស និងនារី ដែលស្ម័គ្រចិត្តទទួលគ្នាជាប្ដីប្រពន្ធ ត្រូវទៅចុះកិច្ចសន្យាអាពាហ៍ពិពាហ៍នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ខាងលំនៅដ្ឋានរបស់នារី។[83]

---

[79] អនុក្រឹត្យស្ដីពីអត្រានុកូលដ្ឋាន, មាត្រា២៩(២)។

[80] អនុក្រឹត្យស្ដីពីអត្រានុកូលដ្ឋាន, មាត្រា២៩(៣)។

[81] ច្បាប់ស្ដីពីអាពាហ៍ពិពាហ៍ និងគ្រួសារ, មាត្រា១៧។

[82] ច្បាប់ស្ដីពីអាពាហ៍ពិពាហ៍ និងគ្រួសារ, មាត្រា១៨។

[83] អនុក្រឹត្យស្ដីពីអត្រានុកូលដ្ឋាន, មាត្រា៣០(១)។

កិច្ចសន្យានេះ ត្រូវចុះក្នុងសៀវភៅអាពាហ៍ពិពាហ៍ ហើយត្រូវចុះហត្ថលេខា ដោយមន្ត្រីអត្រានុកូលដ្ឋាន និងផ្តិតមេដៃ ប្តី ប្រពន្ធ និងសាក្សីចំនួនពីរនាក់ដែលដល់នីតិភាព[84] ហើយមន្ត្រីអត្រានុកូលដ្ឋាន ត្រូវសរសេរចុះបញ្ជីអាពាហ៍ពិពាហ៍ចំនួន ០២ (ពីរ) ច្បាប់ មានខ្លឹមសារដូចគ្នាទាំងស្រុងនៅក្នុងសៀវភៅអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍នោះ។

ក្រោយពេលសរសេរចុះបញ្ជីទាំងពីរ នៃសៀវភៅអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍រួចហើយ មន្ត្រីអត្រានុកូលដ្ឋាន ត្រូវសរសេរចូលទៅក្នុងសំបុត្រអាពាហ៍ពិពាហ៍ច្បាប់ដើមមួយសន្លឹក ដោយប្រុងប្រយ័ត្នកុំឱ្យខុសពីខ្លឹមសារក្នុងបញ្ជីអាពាហ៍ពិពាហ៍ បន្ទាប់មកមន្ត្រីអត្រានុកូលដ្ឋាន ត្រូវប្រគល់ឱ្យសាមីខ្លួនប្តីប្រពន្ធនូវសំបុត្រអាពាហ៍ពិពាហ៍ច្បាប់ដើមនោះ[85] និងណែនាំឱ្យរក្សាទុកឱ្យបានគង់វង្ស ដើម្បីជៀសវាងការបាត់បង់ ព្រោះពុំអាចធ្វើសំបុត្រអាពាហ៍ពិពាហ៍ច្បាប់ដើមជូនជាលើកទីពីរបានទេ។

## ខ. ការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស

អាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស ដែលរស់នៅស្របច្បាប់នៅប្រទេសកម្ពុជា ត្រូវប្រព្រឹត្តទៅតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា[86] ហើយជនបរទេសនោះទៀតសោត ចាំបាច់ត្រូវតែមានវត្តមាននៅព្រះរាជាណាចក្រកម្ពុជាដើម្បីបំពេញបែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍។[87]

ការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេសត្រូវផ្អែកលើគោលការណ៍ស្ម័គ្រចិត្ត និងឆន្ទៈផ្ទាល់របស់សាមីភាគី និងត្រូវបានហាមឃាត់ដាច់ខាតចំពោះករណីមួយចំនួនដូចជា អាពាហ៍ពិពាហ៍ធ្វើឡើងតាមរយៈភ្នាក់ងាររើសគូរស្រករ ឈ្មួញកណ្តាល ឬក្រុមហ៊ុនអាជីវកម្ម និងការរៀបអាពាហ៍ពិពាហ៍ក្លែងក្លាយ បោកបញ្ឆោត ក្នុងគោលបំណងកេងប្រវ័ញ្ចពលកម្ម ជួញដូរមនុស្ស ឬធ្វើអាជីវកម្មផ្លូវភេទ។[88]

### ខ.១. ការបំពេញបែបបទរបស់ជនបរទេស

ដើម្បីរៀបអាពាហ៍ពិពាហ៍បានជាមួយពលរដ្ឋខ្មែរ សាមីខ្លួនជាជនបរទេសត្រូវបំពេញបែបបទទៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដោយភ្ជាប់នូវសំណុំឯកសារដូចជា ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ឯកសារថតចម្លងនៃ លិខិតឆ្លងដែនរបស់សាមីខ្លួនជនបរទេសមានទិដ្ឋាការចូលប្រទេសកម្ពុជា ដែលនៅមានសុពលភាព លិខិតថ្កោលទោស លិខិតបញ្ជាក់ភាពនៅលីវ ឬពោះម៉ាយ ឬមេម៉ាយ និងលិខិតបញ្ជាក់អំពីមុខរបរពិត

[84] អនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន, មាត្រា៣០(២)។

[85] អនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន, មាត្រា៣១។

[86] អនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន, មាត្រា៣៣។

[87] អនុក្រឹត្យស្តីពីការកំណត់បែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស, លេខ ១៨៣ អនក្រ.បក, ២៣ វិច្ឆិកា ២០០៨, មាត្រា៥ (តទៅហៅថា អនុក្រឹត្យស្តីពីបែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស) ។

[88] អនុក្រឹត្យស្តីពីបែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស, មាត្រា២ មាត្រា៣ និងមាត្រា៤។

ប្រាកដរបស់សាមីខ្លួនជនបរទេសដែលធានាដល់ជីវភាពរស់នៅ ចេញដោយសមត្ថកិច្ចនៃប្រទេសសាមីខ្លួនជនបរទេស លិខិតបញ្ជាក់សុខភាពចេញដោយសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជា ចំពោះឯកសារថតចម្លងនៃលិខិតឆ្លងដែន និងលិខិតបញ្ជាក់ភាពនៅលីវ ឬពោះម៉ាយ ឬមេម៉ាយ ត្រូវមានបញ្ជាក់នីត្យានុកូលភាពពីស្ថានទូត ឬស្ថានតំណាងនៃប្រទេសរបស់សាមីខ្លួនជនបរទេស ប្រចាំប្រទេសកម្ពុជា។[89]

បន្ទាប់មក ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិមានភារកិច្ចពិនិត្យ និងផ្តល់យោបល់លើសំណុំឯកសាររបស់ជនបរទេសក្នុងរយៈពេល ០៥ (ប្រាំ) ថ្ងៃយ៉ាងយូរ[90] ហើយបញ្ជូនសំណុំឯកសារទាំងនោះទៅក្រសួងមហាផ្ទៃ ដើម្បីបន្តនីតិវិធីដូចជា ចុះបញ្ជីសំណុំឯកសាររបស់ជនបរទេសនោះ និងត្រូវជូនដំណឹងទៅសាមីខ្លួនវិញក្នុងរយៈពេលយ៉ាងយូរ ០៥ (ប្រាំ) ថ្ងៃ ហើយត្រូវជូនដំណឹងអំពីការសុំរៀបអាពាហ៍ពិពាហ៍ទៅមន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់នៃលំនៅដ្ឋានអចិន្ត្រៃយ៍របស់សាមីខ្លួនពលរដ្ឋខ្មែរ និងពិនិត្យនីត្យានុកូលភាពលើសំណុំឯកសារដែលចេញដោយមន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់នៃលំនៅដ្ឋានអចិន្ត្រៃយ៍របស់សាមីខ្លួនពលរដ្ឋខ្មែរ។[91]

**ខ.២. ការបំពេញបែបបទរបស់ពលរដ្ឋខ្មែរ**

ចំពោះសាមីខ្លួនជាពលរដ្ឋខ្មែរ ត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយជនបរទេសនោះ ក៏ត្រូវដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ទៅមន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់នៃលំនៅដ្ឋានអចិន្ត្រៃយ៍ដែលខ្លួនរស់នៅដោយភ្ជាប់ជាមួយឯកសារដូចជា ពាក្យសុំរៀបអាពាហ៍ពិពាហ៍ សេចក្តីចម្លងសំបុត្រកំណើត ឬសេចក្តីចម្លងសំបុត្របញ្ជាក់កំណើតរបស់សាមីខ្លួនពលរដ្ឋខ្មែរ លិខិតបញ្ជាក់ភាពនៅលីវ ឬពោះម៉ាយ ឬមេម៉ាយ ចេញដោយមេឃុំ ឬចៅសង្កាត់នៃលំនៅដ្ឋានអចិន្ត្រៃយ៍របស់សាមីខ្លួនពលរដ្ឋខ្មែរ និងលិខិតបញ្ជាក់សុខភាពចេញដោយមន្ទីរពេទ្យ ដែលទទួលស្គាល់ជាផ្លូវការពីក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។[92]

**ខ.៣ ការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍**

ពាក្យសុំរៀបអាពាហ៍ពិពាហ៍ និងសំណុំឯកសារទាំងអស់របស់សាមីខ្លួនជាពលរដ្ឋខ្មែរ និងជនបរទេសត្រូវដាក់ស្របពេលជាមួយគ្នា នៅមន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់នៃលំនៅដ្ឋានអចិន្ត្រៃយ៍របស់ពលរដ្ឋខ្មែរ។[93]

នៅពេលទទួលបានពាក្យសុំរៀបអាពាហ៍ពិពាហ៍ និងសំណុំឯកសារភ្ជាប់របស់សាមីខ្លួនបុរស និងនារី មន្ត្រីអត្រានុកូលដ្ឋាននឹងពិនិត្យ និងសម្រេចលើពាក្យសុំ ក្នុងរយៈពេលយ៉ាងយូរ ០៣ថ្ងៃ ប្រសិនបើមានលក្ខណៈ

[89] អនុក្រឹត្យស្តីពីបែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស, មាត្រា៦។

[90] អនុក្រឹត្យស្តីពីបែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស, មាត្រា៧។

[91] អនុក្រឹត្យស្តីពីបែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស, មាត្រា៨។

[92] អនុក្រឹត្យស្តីពីបែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស, មាត្រា៩(២)។

[93] អនុក្រឹត្យស្តីពីបែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស, មាត្រា៩(៣)។

ត្រឹមត្រូវទៅតាមគោលការណ៍ច្បាប់រួចហើយ មន្ត្រីអត្រានុកូលដ្ឋានត្រូវរៀបចំចេញប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ ដោយមានវត្តមានផ្ទាល់របស់សាមីខ្លួនបុរស និងនារី។[94]

**ខ.៤ ការជូនដំណឹងជាសាធារណៈ**

មន្ត្រីអត្រានុកូលដ្ឋានត្រូវចេញប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ជាចំនួន ០៥ (ប្រាំ) ច្បាប់ ដោយ ០១(មួយ) ច្បាប់ ត្រូវបិទផ្សាយជាសាធារណៈនៅស្ថានទូត ឬស្ថានតំណាង នៃប្រទេសសាមីខ្លួនជនបរទេសប្រចាំនៅប្រទេសកម្ពុជា ០១(មួយ) ច្បាប់ ត្រូវបិទផ្សាយជាសាធារណៈ នៅលំនៅដ្ឋានអចិន្ត្រៃយ៍របស់សាមីខ្លួនជាពលរដ្ឋខ្មែរ ០២ (ពីរ) ច្បាប់ បិទផ្សាយជាសាធារណៈ និងរក្សាទុកជាឯកសារ នៅសាលាឃុំ ឬសង្កាត់របស់សាមីខ្លួនជាពលរដ្ឋខ្មែរ និង ០១(មួយ) ច្បាប់ទៀត ត្រូវបិទផ្សាយជាសាធារណៈនៅលំនៅដ្ឋាន ឬទីកន្លែងស្នាក់នៅនៃសាមីខ្លួនជនបរទេស។[95]

ប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ ត្រូវបិទផ្សាយជាសាធារណៈក្នុងរយៈពេល ១០ (ដប់) ថ្ងៃ ដើម្បីឱ្យជនដែលមានផលប្រយោជន៍ក្នុងរឿងនោះ អាចប្តឹងជំទាស់នឹងអាពាហ៍ពិពាហ៍នោះបាន ហើយប្រសិនបើគ្មានការប្តឹងក្នុងរយៈពេលដែលបានកំណត់នេះទេ អាពាហ៍ពិពាហ៍នោះគឺអាចប្រព្រឹត្តទៅបាន។[96]

**ខ.៥. ការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ និងការទទួលបានសំបុត្រអាពាហ៍ពិពាហ៍**

អាពាហ៍ពិពាហ៍នឹងមានអានុភាពពេញលក្ខណៈតាមច្បាប់បាន លុះត្រាតែសាមីខ្លួនពលរដ្ឋខ្មែរ និងជនបរទេស បានចុះកិច្ចសន្យាអាពាហ៍ពិពាហ៍នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន នៃឃុំ សង្កាត់ដែលសាមីខ្លួនទាំងពីរបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ស្របទៅតាមទម្រង់បែបបទ និងនីតិវិធីនៃការងារអត្រានុកូលដ្ឋាន។[97]

កិច្ចសន្យានេះ ត្រូវចុះក្នុងសៀវភៅអាពាហ៍ពិពាហ៍ ហើយត្រូវចុះហត្ថលេខា ដោយមន្ត្រីអត្រានុកូលដ្ឋាន និងផ្ដិតមេដៃ ប្តី ប្រពន្ធ និងសាក្សីចំនួនពីរនាក់ដែលដល់នីតិភាព[98] ហើយមន្ត្រីអត្រានុកូលដ្ឋាន ត្រូវសរសេរចុះបញ្ជីអាពាហ៍ពិពាហ៍ចំនួន ០២ (ពីរ) ច្បាប់ មានខ្លឹមសារដូចគ្នាទាំងស្រុងនៅក្នុងសៀវភៅអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍ភ្លោះ។

ក្រោយពេលសរសេរចុះបញ្ជីទាំងពីរ នៃសៀវភៅអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍រួចហើយ មន្ត្រីអត្រានុកូលដ្ឋាន ត្រូវសរសេរចូលទៅក្នុងសំបុត្រអាពាហ៍ពិពាហ៍ច្បាប់ដើមមួយសន្លឹក ដោយប្រុងប្រយ័ត្នកុំឱ្យ

---

[94] អនុក្រឹត្យស្តីពីបែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស, មាត្រា១០(១,២)។

[95] សេចក្តីណែនាំស្តីពី ការអនុវត្តអនុក្រឹត្យស្តីពីកំណត់បែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស, លេខ ០០១ សណន, ១២ មករា ២០០៩, ទំព័រ៣ និងទំព័រ៤។

[96] អនុក្រឹត្យស្តីពីបែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស, មាត្រា១០(៣)។

[97] អនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន, មាត្រា១១។

[98] អនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន, មាត្រា៣០(២)។

ខុសពីខ្លឹមសារក្នុងបញ្ជីអាពាហ៍ពិពាហ៍ បន្ទាប់មកមន្ត្រីអត្រានុកូលដ្ឋាន ត្រូវប្រគល់ឱ្យសាមីខ្លួនប្ដីប្រពន្ធនូវសំបុត្រអាពាហ៍ពិពាហ៍ច្បាប់ដើមនោះ[99] និងណែនាំឱ្យរក្សាទុកឱ្យបានគង់វង្ស ដើម្បីជៀសវាងការបាត់បង់ ព្រោះពុំអាចធ្វើសំបុត្រអាពាហ៍ពិពាហ៍ច្បាប់ដើមជូនជាលើកទីពីរបានទេ។

**គ. ការរៀបអាពាហ៍ពិពាហ៍រវាងជនបរទេស ដែលរស់នៅស្របច្បាប់នៅក្នុងប្រទេសកម្ពុជា**

ជនអន្តោប្រវេសន៍ និងជនបរទេស ដែលរស់នៅស្របច្បាប់នៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា អាចរៀបអាពាហ៍ពិពាហ៍ជាមួយជនបរទេស ឬជនអន្តោប្រវេសន៍នោះបាន ដោយអនុវត្តតាមច្បាប់ ស្ដីពីអាពាហ៍ពិពាហ៍ ដែលមានចែងក្នុងប្រទេសរបស់ខ្លួន តែត្រូវសុំអនុញ្ញាតច្បាប់ពីមន្ត្រីអត្រានុកូលដ្ឋានដោយប្រាប់ពីកន្លែង និងពេលវេលាដែលខ្លួនរៀបអាពាហ៍ពិពាហ៍ឱ្យច្បាស់លាស់។[100]

ពេលរៀបអាពាហ៍ពិពាហ៍ ប្ដីប្រពន្ធអាចទៅសុំចុះសៀវភៅអាពាហ៍ពិពាហ៍នៅ ស្ថានទូត ស្ថានអគ្គកុងស៊ុល ឬស្ថានកុងស៊ុលនៃប្រទេសរបស់ខ្លួនប្រចាំនៅក្នុងប្រទេសកម្ពុជា ឬនៅមន្ត្រីអត្រានុកូលដ្ឋាននៃឃុំ ឬសង្កាត់ដែលសាមីខ្លួនបានរៀបអាពាហ៍ពិពាហ៍ ស្របតាមច្បាប់នៃប្រទេសកម្ពុជា។[101]

**២.២.៤. សេចក្តីចម្លង ឬសម្រង់សំបុត្រអាពាហ៍ពិពាហ៍ និងសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍**

ការសុំចម្លង ឬសម្រង់សំបុត្រអាពាហ៍ពិពាហ៍ ក្នុងឆ្នាំមិនទាន់ដាច់ ត្រូវធ្វើឡើងនៅសាលាឃុំ សង្កាត់ ដោយត្រូវចុះហត្ថលេខា និងបោះត្រាដោយមន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់។ រីឯការសុំចម្លង ឬសម្រង់សំបុត្រអាពាហ៍ពិពាហ៍ ក្នុងឆ្នាំដែលកន្លងផុតទៅវិញ ត្រូវធ្វើឡើងនៅសាលាក្រុង ស្រុក ខណ្ឌសាមី ដោយត្រូវចុះហត្ថលេខាដោយមន្ត្រីរក្សាសៀវភៅអត្រានុកូលដ្ឋាន និងត្រូវបញ្ជាក់ហត្ថលេខានោះដោយអភិបាលក្រុង ស្រុក ខណ្ឌ និងបោះត្រាផង។ [102]

ក្នុងករណី ប្រជាពលរដ្ឋខ្មែររស់នៅស្របច្បាប់ឯបរទេស ដែលបានចុះសៀវភៅអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍ នៅស្ថានទូត ស្ថានអគ្គកុងស៊ុល ឬស្ថានកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជាប្រចាំនៅប្រទេសនោះ ការសុំចម្លង ឬសម្រង់សំបុត្រអាពាហ៍ពិពាហ៍ ក្នុងឆ្នាំមិនទាន់ដាច់ ត្រូវធ្វើឡើងនៅស្ថានទូត ស្ថានអគ្គកុងស៊ុល ឬស្ថានកុងស៊ុលនោះ ចុះហត្ថលេខាដោយមន្ត្រីអត្រានុកូលដ្ឋាននៅទីនោះ និងត្រូវបញ្ជាក់ហត្ថលេខានោះដោយឯកអគ្គរាជទូត អគ្គកុងស៊ុល ឬកុងស៊ុល និងបោះត្រាផង។ រីឯការសុំចម្លង ឬសម្រង់សំបុត្រ

[99] អនុក្រឹត្យស្ដីពីអត្រានុកូលដ្ឋាន, មាត្រា៣១។

[100] អនុក្រឹត្យស្ដីពីអត្រានុកូលដ្ឋាន, មាត្រា៣៤(១)។

[101] អនុក្រឹត្យស្ដីពីអត្រានុកូលដ្ឋាន, មាត្រា៣៤(២)។

[102] កម្រងឯកសារស្ដីពីរបៀបកត់ត្រាការងារអត្រានុកូលដ្ឋាននៃជំពូកទី៣ ស្ដីពីអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍, កក្កដា ២០០៥, ទំព័រ ១១៥(១,២)។

អាពាហ៍ពិពាហ៍ ក្នុងឆ្នាំដែលកន្លងផុតទៅវិញ ត្រូវធ្វើឡើងនៅក្រសួងមហាផ្ទៃ ដែលមានសៀវភៅអត្រានុកូលដ្ឋានឆ្នាំចាស់តម្កល់ទុក។ [103]

សម្រង់សំបុត្រអាពាហ៍ពិពាហ៍ និងសម្រង់សំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ ត្រូវស្រង់ចេញពីសៀវភៅអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍ និងសៀវភៅអត្រានុកូលដ្ឋានបញ្ជាក់អាពាហ៍ពិពាហ៍ដែលតម្កល់ទុក ដោយស្រង់យកតែខ្លឹមសារ តាមសំណើរបស់អ្នកមកសុំស្រង់តែប៉ុណ្ណោះ។[104]

ចំពោះការសុំចម្លង ឬសម្រង់សំបុត្រអាពាហ៍ពិពាហ៍ និងសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ អ្នកស្នើសុំត្រូវយកសំបុត្រអាពាហ៍ពិពាហ៍ ឬសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ច្បាប់ដើមមកជាមួយ។

## ២.៣. អត្រានុកូលដ្ឋានមរណភាព

### ២.៣.១. សញ្ញាណទូទៅនៃមរណភាព

មរណភាព គឺជាព្រឹត្តិការណ៍គតិយុត្ត ដែលនាំឱ្យបុគ្គលិកលក្ខណៈគតិយុត្តរបស់រូបវន្តបុគ្គលម្នាក់ត្រូវបានបញ្ចប់ ប៉ុន្តែច្បាប់បានកំណត់ទទួលស្គាល់ និងផ្តល់អានុភាពខាងផ្លូវច្បាប់មួយចំនួន ដូចជាមតកសាសន៍ជាដើម។

ក្នុងករណីមានបុគ្គលណាម្នាក់បានបាត់ខ្លួន ឬអវត្តមានក្នុងអំឡុងពេល៥ (ប្រាំ) ឆ្នាំ ឬបុគ្គលដែលចូលទៅតំបន់ដែលមានសង្គ្រាម បុគ្គលដែលមានវត្តមាននៅក្នុងនាវាបានលិច ឬបុគ្គលដែលបានជួបប្រទះនឹងគ្រោះថ្នាក់ផ្សេងទៀតដែលអាចនាំឱ្យទទួលមរណភាព ហើយពុំមានដំណឹងច្បាស់លាស់ថា អ្នកអវត្តមាននៅរស់ ឬទទួលមរណភាព ក្នុងអំឡុងពេល០១(មួយ) ឆ្នាំ តុលាការអាចប្រកាសថាបាត់ខ្លួន និងចាត់ទុកថាបានទទួលមរណភាព តាមពាក្យសុំរបស់ញាតិលោហិត ឬអ្នកមានផលប្រយោជន៍ពាក់ព័ន្ធ។[105] មិនតែប៉ុណ្ណោះ ប្រសិនបើក្នុងចំណោមបុគ្គលដែលបានទទួលមរណភាពជាច្រើននាក់ ហើយមិនច្បាស់លាស់ថា មានបុគ្គលណាម្នាក់នៅរស់ក្រោយពេលបុគ្គលផ្សេងទៀតបានទទួលមរណភាពទេ បុគ្គលទាំងនោះត្រូវបានចាត់ទុកថា បានទទួលមរណភាពព្រមពេលជាមួយគ្នា។[106]

### ២.៣.២. នីតិវិធីនៃការស្នើសុំសំបុត្រមរណភាព

ពេលមានអ្នកស្លាប់ភ្លាម ក្រុមគ្រួសារ ឬសាច់ញាតិសន្តាន ឬអ្នកជិតខាង ឬអ្នកមានភារកិច្ចនៅក្រសួងស្ថាប័ន អង្គភាពរបស់អ្នកស្លាប់ ត្រូវរាយការណ៍ជូនដល់មន្ត្រីអត្រានុកូលដ្ឋានសាលាឃុំ ឬសង្កាត់ នៃទីកន្លែងរស់

[103] កម្រងឯកសារស្តីពីរបៀបកត់ត្រាការងារអត្រានុកូលដ្ឋាននៃជំពូកទី៣ ស្តីពីអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍, កក្កដា ២០០៥, ទំព័រ ១១៥(៣)។

[104] កម្រងឯកសារស្តីពីរបៀបកត់ត្រាការងារអត្រានុកូលដ្ឋាននៃជំពូកទី៣ ស្តីពីអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍, កក្កដា ២០០៥, ទំព័រ១២៤។

[105] ក្រមរដ្ឋប្បវេណី, មាត្រា៤១ និងមាត្រា៤៣។

[106] ក្រមរដ្ឋប្បវេណី, មាត្រា៤៥។

នៅជាប់លាប់ របស់អ្នកស្លាប់។[107] បន្ទាប់មកមន្ត្រីអត្រានុកូលដ្ឋាន នឹងធ្វើលិខិតអនុញ្ញាតឱ្យធ្វើបុណ្យបូជា ឬបញ្ចុះសព ចុះបញ្ជីមរណភាពក្នុងសៀវភៅអត្រានុកូលដ្ឋានមរណភាព និងចេញសំបុត្រមរណភាព តាមការស្នើសុំរបស់អ្នកដែលបានរាយការណ៍។

**គ. លក្ខខណ្ឌ នៃការស្នើសុំលិខិតអនុញ្ញាតធ្វើបុណ្យបូជា ឬបញ្ចុះសព និងចុះបញ្ជីមរណភាព**

**គ.១. ប្រជាពលរដ្ឋខ្មែរ**

ក្នុងករណីមានអ្នកស្លាប់ដោយជំងឺឆ្លងរាតត្បាតដែលអាចបង្កឱ្យគ្រោះថ្នាក់ដល់សង្គម មន្ត្រីអត្រានុកូលដ្ឋានត្រូវរាយការណ៍ទៅមន្ទីរពេទ្យ ឬផ្នែកអនាម័យភ្លាម ហើយបើពេទ្យ ឬផ្នែកអនាម័យសម្រេចយ៉ាងណា មន្ត្រីអត្រានុកូលដ្ឋានត្រូវអនុញ្ញាតឱ្យធ្វើបុណ្យបូជា ឬបញ្ចុះសពតាមការសម្រេចនោះ។[108]

បើអ្នកស្លាប់ដោយមូលហេតុណាមួយ ដែលពាក់ព័ន្ធដល់ការមន្ទិលសង្ស័យពីអំពើឃាតកម្មនៃបទល្មើសឧក្រិដ្ឋ មន្ត្រីអត្រានុកូលដ្ឋាន ឬជនទាំងឡាយដែលបានឃើញ ឬដឹងឮហេតុការណ៍នោះ ត្រូវរាយការណ៍ដល់អាជ្ញាធរមានសមត្ថកិច្ចនៅកន្លែងអ្នកស្លាប់នោះភ្លាម ដើម្បីឱ្យសមត្ថកិច្ចជំនាញនានា ពិនិត្យស្រាវជ្រាវ និងដោះស្រាយ បន្ទាប់មកមន្ត្រីអត្រានុកូលដ្ឋានអាចអនុញ្ញាតឱ្យធ្វើបុណ្យបូជា ឬបញ្ចុះសពបាន ក្រោយពីមានការសម្រេចពីភ្នាក់ងារមានសមត្ថកិច្ច។[109]

ដោយឡែក បើមានពលរដ្ឋខ្មែររស់នៅឃុំ សង្កាត់ណាមួយ បានទៅស្លាប់នៅឃុំ ឬសង្កាត់ផ្សេង មន្ត្រីអត្រានុកូលដ្ឋាន នៃឃុំ សង្កាត់ដែលមានអ្នកស្លាប់ ត្រូវជូនដំណឹងទៅមន្ត្រីអត្រានុកូលដ្ឋាននៃឃុំ សង្កាត់ដែលអ្នកស្លាប់បានរស់នៅ ដើម្បីជូនដំណឹងដល់ក្រុមគ្រួសារនៃអ្នកស្លាប់នោះ ឱ្យទៅយកសពមកធ្វើបុណ្យ និងចុះសៀវភៅអត្រានុកូលដ្ឋានមរណភាពនៅឃុំ សង្កាត់ដែលអ្នកស្លាប់នោះបានរស់នៅជាប់លាប់មុនពេលស្លាប់ ក៏ប៉ុន្តែបើអ្នកស្លាប់នោះ គ្មានអ្នកស្គាល់ទេ នោះមន្ត្រីអត្រានុកូលដ្ឋានត្រូវចាត់ចែងបូជា ឬបញ្ចុះ និងចុះសៀវភៅអត្រានុកូលដ្ឋានមរណភាព នៅឯឃុំ សង្កាត់ដែលបានស្លាប់នោះតែម្តង។[110]

**គ.២. ពិរុទ្ធជនទទួលមរណភាព**

បើមានអ្នកទោសណាម្នាក់ស្លាប់ក្នុងពន្ធនាគារ អ្នកទទួលខុសត្រូវនៃពន្ធនាគារនោះ ត្រូវធ្វើសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរទៅស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ និងទៅមន្ត្រីអត្រានុកូលដ្ឋាននៃលំនៅអចិន្ត្រៃយ៍របស់អ្នកទោសនោះដើម្បីមន្ត្រីអត្រានុកូលដ្ឋានចុះក្នុងសៀវភៅមរណភាព។[111]

[107] អនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន, មាត្រា៣៥(១)។

[108] អនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន, មាត្រា៣៥(៤)។

[109] អនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន, មាត្រា៣៦។

[110] អនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន, មាត្រា៣៧។

[111] អនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន, មាត្រា៣៨។

**ក.៣. ពលរដ្ឋខ្មែររស់នៅឯបរទេស**

ក្នុងករណីពលរដ្ឋខ្មែរដែលរស់នៅស្របច្បាប់ឯបរទេសបានស្លាប់ ក្រុមគ្រួសារ ឬសាច់ញាតិសន្តាន ឬអ្នកជិតខាង ឬអ្នកដែលបានឃើញអ្នកស្លាប់នោះផ្ទាល់ អាចទៅចុះសៀវភៅមរណភាពនៅប្រទេសនោះ តាមច្បាប់នៃប្រទេសនោះ ហើយនៅពេលត្រឡប់មកប្រទេសកម្ពុជាវិញ ត្រូវយកសំបុត្រមរណភាពដែលធ្វើនៅប្រទេសនោះ ទៅចុះសៀវភៅអត្រានុកូលដ្ឋាននៅឃុំ ឬសង្កាត់ ដែលសាមីខ្លួនអ្នកស្លាប់ ធ្លាប់ស្នាក់នៅជាប់លាប់មុនពេលចេញទៅបរទេស ឬអាចទៅរាយការណ៍ចុះសៀវភៅមរណភាពនៅ ស្ថានទូត ស្ថានអគ្គកុងស៊ុល ឬស្ថានកុងស៊ុល នៃព្រះរាជាណាចក្រកម្ពុជាប្រចាំនៅប្រទេសនោះ រួចហើយពេលត្រឡប់មកប្រទេសកម្ពុជាវិញអាចយកសំបុត្រកំណើតនោះមកប្រើប្រាស់ជាផ្លូវការបាន។[112]

**ក.៤. ជនបរទេសរស់នៅប្រទេសកម្ពុជា**

ជនអន្តោប្រវេសន៍ និងជនបរទេសរស់នៅស្របច្បាប់លើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានស្លាប់នៅលើទឹកដីប្រទេសកម្ពុជា ក្រុមគ្រួសារសាច់ញាតិ ឬអ្នកទទួលខុសត្រូវ អាចទៅចុះសៀវភៅមរណភាពនៅសាលាឃុំ សង្កាត់ ដែលអ្នកស្លាប់ធ្លាប់រស់នៅជាប់លាប់ មុនពេលខ្លួនស្លាប់ ឬអាចទៅចុះសៀវភៅមរណភាព នៅស្ថានទូត ស្ថានអគ្គកុងស៊ុល ឬស្ថានកុងស៊ុលនៃប្រទេសរបស់អ្នកស្លាប់ ប្រចាំនៅប្រទេសកម្ពុជាបាន (ប្រសិនបើមាន)។[113]

**ខ. រយៈពេលនៃការរាយការណ៍អំពីមរណភាព**

ពេលមានអ្នកស្លាប់ភ្លាម ក្រុមគ្រួសារ ឬសាច់ញាតិសន្តាន ឬអ្នកជិតខាង ឬអ្នកមានភារកិច្ចនៅក្រសួង ស្ថាប័ន អង្គភាពរបស់អ្នកស្លាប់ ត្រូវរាយការណ៍ជូនដល់មន្ត្រីអត្រានុកូលដ្ឋានសាលាឃុំ ឬសង្កាត់ នៃទីកន្លែងរស់នៅជាប់លាប់ របស់អ្នកស្លាប់ឱ្យទាន់ក្នុងរយៈពេល១៥ (ដប់ប្រាំ) ថ្ងៃ ក្រោយពីទទួលមរណភាព។

ក្នុងករណីបើមានអ្នកស្លាប់ទុកឱ្យហួសរយៈពេល១៥ (ដប់ប្រាំ) ថ្ងៃ នៅក្នុងឆ្នាំពុំបានទៅរាយការណ៍ចុះសៀវភៅអត្រានុកូលដ្ឋានមរណភាពនោះទេ ក្រុមគ្រួសារនៃអ្នកស្លាប់ត្រូវប្តឹងសុំសំបុត្រមរណភាពពីមេឃុំ ឬចៅសង្កាត់សាមីនៃលំនៅឋានពិតប្រាកដរបស់អ្នកស្លាប់។[114]

[112] អនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន, មាត្រា៤១។

[113] អនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន, មាត្រា៤២។

[114] អនុក្រឹត្យស្តីពីការកែសម្រួល អនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន, លេខ ១៧ អនក្រ.បក, ១៤ មិថុនា ២០០០, មាត្រា៤០។

ដោយឡែក បើមានអ្នកស្លាប់ទុកឱ្យហួសឆ្នាំ ហើយពុំបានទៅរាយការណ៍ទេ ក្រុមគ្រួសារនៃអ្នកស្លាប់ត្រូវប្តឹងសុំសាលក្រមពីសាលាដំបូងរាជធានី ខេត្តសាមី រួចយកសាលក្រមនោះមកសុំមន្ត្រីអត្រានុកូលដ្ឋានឃុំ ឬសង្កាត់នៃអ្នកស្លាប់ ដើម្បីចុះសៀវភៅអត្រានុកូលដ្ឋានមរណភាព។[115]

### គ. លិខិតស្នាមនានាដែលពាក់ព័ន្ធនឹងសព

### គ.១. ករណីចុះអត្រានុកូលដ្ឋានមរណភាព ក្នុងរយៈពេល១៥ថ្ងៃ

អ្នកទៅរាយការណ៍អំពីមរណភាព ដើម្បីសុំចុះសៀវភៅអត្រានុកូលដ្ឋានមរណភាព ត្រូវបង្ហាញចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន នូវលិខិតស្នាមមួយចំនួនដូចជា លិខិតជូនដំណឹងមរណភាព សៀវភៅគ្រួសារដែលមានឈ្មោះអ្នកស្លាប់នៅក្នុងនោះ(ប្រសិនបើមាន) និងសេចក្តីចម្លងសំបុត្រកំណើត ឬសេចក្តីចម្លងសំបុត្របញ្ជាក់កំណើតរបស់អ្នកស្លាប់។

ចំពោះលិខិតជូនដំណឹងមរណភាពត្រូវបានបែងចែកករណីផ្សេងៗទៀត ដោយយោងទៅតាមមូលហេតុនៃមរណភាព។ លិខិតទាំងនោះមានដូចជា៖

- ករណីស្លាប់ក្នុងមន្ទីរពេទ្យ ត្រូវមានលិខិតជូនដំណឹងមរណភាពបញ្ជាក់ដោយមន្ទីរពេទ្យ
- ករណីស្លាប់ដោយរោគឆ្លង ត្រូវមានលិខិតជូនដំណឹងមរណភាពបញ្ជាក់ដោយផ្នែកអនាម័យ
- ករណីស្លាប់ទាក់ទងនឹងឃាតកម្ម ត្រូវមានលិខិតជូនដំណឹងមរណភាពបញ្ជាក់ដោយសមត្ថកិច្ចជំនាញ
- ករណីស្លាប់នៅនឹងផ្ទះក្នុងភូមិរបស់សព ត្រូវមានលិខិតជូនដំណឹងមរណភាពបញ្ជាក់ដោយមេភូមិ
- ករណីស្លាប់នៅក្រៅឃុំរបស់ខ្លួន ត្រូវមានលិខិតជូនដំណឹងមរណភាពពីមន្ត្រីអត្រានុកូលដ្ឋាននៃឃុំនោះ
- ករណីអ្នកទោសស្លាប់ក្នុងមណ្ឌលអប់រំ ឬពន្ធនាគារ លិខិតជូនដំណឹងមរណភាពរបស់អ្នកទទួលខុសត្រូវមណ្ឌលអប់រំកែប្រែ ឬពន្ធនាគារ
- ករណីស្លាប់នៅក្នុងក្រសួង ស្ថាប័ន ឬអង្គភាព ត្រូវមានលិខិតជូនដំណឹងមរណភាពរបស់អ្នកទទួលខុសត្រូវតាមក្រសួង ស្ថាប័ន ឬអង្គភាព។

ចំពោះជនបរទេស និងជនអន្តោប្រវេសន៍ ត្រូវមានឯកសារបន្ថែមដូចជា លិខិតឆ្លងដែននៅមានសុពលភាពរបស់អ្នកស្លាប់ ទិដ្ឋាការ ឬប័ណ្ណស្នាក់នៅក្នុងប្រទេសកម្ពុជា ដែលនៅមានសុពលភាព ក្នុងករណីបាត់បង់ឯកសារណាមួយ ត្រូវមានលិខិតស្នាមនានាដែលបញ្ជាក់ពីអត្តសញ្ញាណទាក់ទងនឹងអ្នកស្លាប់។

[115] សៀវភៅណែនាំស្តីពីការចុះសៀវភៅអត្រានុកូលដ្ឋានឱ្យមាននិរន្តរភាពក្រោយបញ្ចប់យុទ្ធនាការចុះសៀវភៅអត្រានុកូលដ្ឋានចល័ត, លេខ០០៨/សណន, ១៨ ឧសភា ២០០៧, ទំព័រ៤០១១។

**គ.២. ករណីចុះអត្រានុកូលដ្ឋានមរណភាព ហួសរយៈពេល១៥ថ្ងៃ ក្នុងឆ្នាំ**

ក្នុងករណីសុំចុះសៀវភៅអត្រានុកូលដ្ឋានមរណភាព ហួសរយៈពេល១៥ (ដប់ប្រាំ) ថ្ងៃ ក្នុងឆ្នាំ លិខិតស្នាមដែលត្រូវភ្ជាប់ទៅជាមួយ គឺដូចគ្នាទៅនឹងទៅការចុះសៀវភៅអត្រានុកូលដ្ឋានមរណភាព ក្នុងរយៈពេល១៥ (ដប់ប្រាំ) ថ្ងៃ ដោយគ្រាន់តែបន្ថែមសៀវភៅគ្រួសារ ឬសេចក្តីចម្លងសំបុត្រកំណើត ឬសេចក្តីចម្លងសំបុត្របញ្ជាក់កំណើតរបស់អ្នកមកប្តឹងសុំចុះសៀវភៅអត្រានុកូលដ្ឋានមរណភាពតែប៉ុណ្ណោះ។

**គ.៣. ករណីចុះអត្រានុកូលដ្ឋានមរណភាព ទុកឱ្យហួសឆ្នាំ**

អ្នកប្តឹងសុំត្រូវមានលិខិតស្នាមមួយចំនួនដូចខាងក្រោម៖

- សៀវភៅគ្រួសារ ឬសេចក្តីចម្លងសំបុត្រកំណើត ឬសេចក្តីចម្លងសំបុត្របញ្ជាក់កំណលតរបស់អ្នកប្តឹងសុំ
- សាលក្រមបញ្ជាក់ពីមរណភាពរបស់តុលាការរាជធានី ខេត្តសាមី
- សៀវភៅគ្រួសារដែលមានឈ្មោះអ្នកស្លាប់ ឬ
- សេចក្តីចម្លងសំបុត្រកំណើត ឬសេចក្តីចម្លងសំបុត្របញ្ជាក់កំណើត ឬ
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ របស់អ្នកសុំប្តឹង។

**ឃ. ការចុះបញ្ជី និងការទទួលបានសំបុត្រមរណភាព**

នៅពេលមានអ្នកមករាយការណ៍ពីមរណភាព និងបន្ទាប់ពីពិនិត្យលិខិតស្នាមឃើញថាត្រឹមត្រូវទៅតាមការកំណត់សព្វគ្រប់ហើយ មន្ត្រីអត្រានុកូលដ្ឋានត្រូវសរសេរចុះបញ្ជីមរណភាពចំនួន០២ (ពីរ) ច្បាប់ មានខ្លឹមសារដូចគ្នាទាំងស្រុង នៅក្នុងសៀវភៅអត្រានុកូលដ្ឋានមរណភាពភ្លោះ។ មន្ត្រីអត្រានុកូលដ្ឋានត្រូវរក្សាលិខិតស្នាមចាំបាច់ ដែលពាក់ព័ន្ធនឹងសពដូចជា លិខិតជូនដំណឹងមរណភាព ឬ សាលក្រមបញ្ជាក់ពីមរណភាពរបស់តុលាការរាជធានី ខេត្តសាមី ដោយក្រៅពីនោះ លិខិតស្នាមផ្សេងៗទៀត ត្រូវប្រគល់ជូនអ្នករាយការណ៍វិញ។

បន្ទាប់មកមន្ត្រីអត្រានុកូលដ្ឋានត្រូវប្រគល់ឱ្យអ្នករាយការណ៍នូវសំបុត្រមរណភាពច្បាប់ដើមចំនួន ០១ (មួយ) សន្លឹក និងចេញសេចក្តីចម្លងតាមការស្នើសុំរបស់សាមីខ្លួន។[116] ការចុះសៀវភៅមរណភាព និងចេញសំបុត្រមរណភាព ត្រូវធ្វើក្នុងរយៈពេលយ៉ាងយូរបំផុត ១៥ (ដប់ប្រាំ) ថ្ងៃ ក្រោយពីថ្ងៃទទួលមរណភាព។[117]

**២.២.៣. សេចក្តីចម្លង ឬសម្រង់សំបុត្រមរណភាព និងសំបុត្របញ្ជាក់មរណភាព**

ការសុំចម្លង ឬសម្រង់សំបុត្រមរណភាព ក្នុងឆ្នាំមិនទាន់ដាច់ ត្រូវធ្វើឡើងនៅសាលាឃុំ សង្កាត់ ដោយត្រូវចុះហត្ថលេខា និងបោះត្រាដោយមន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់។ រីឯការសុំចម្លង ឬសម្រង់សំបុត្រមរណភាព

[116] អនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន, មាត្រា៣៩។

[117] អនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន, មាត្រា៣៥(៣)។

ក្នុងឆ្នាំដែលកន្លងផុតទៅវិញ ត្រូវធ្វើឡើងនៅសាលាក្រុង ស្រុក ខណ្ឌសាមី ដោយត្រូវចុះហត្ថលេខាដោយមន្ត្រីរក្សាសៀវភៅអត្រានុកូលដ្ឋាន និងត្រូវបញ្ជាក់ហត្ថលេខានោះដោយអភិបាលក្រុង ស្រុក ខណ្ឌ និងបោះត្រាផង។[118]

ក្នុងករណី ប្រជាពលរដ្ឋខ្មែររស់នៅស្របច្បាប់ឯបរទេស ដែលបានចុះសៀវភៅអត្រានុកូលដ្ឋានមរណភាព នៅស្ថានទូត ស្ថានអគ្គកុងស៊ុល ឬស្ថានកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជាប្រចាំនៅប្រទេសនោះ ការសុំចម្លង ឬសម្រង់សំបុត្រមរណភាព ក្នុងឆ្នាំមិនទាន់ដាច់ ត្រូវធ្វើឡើងនៅស្ថានទូត ស្ថានអគ្គកុងស៊ុល ឬស្ថានកុងស៊ុលនោះ ចុះហត្ថលេខាដោយមន្ត្រីអត្រានុកូលដ្ឋាននៅទីនោះ និងត្រូវបញ្ជាក់ហត្ថលេខានោះដោយឯកអគ្គរាជទូត អគ្គកុងស៊ុល ឬកុងស៊ុល និងបោះត្រាផង។ រីឯការសុំចម្លង ឬសម្រង់សំបុត្រមរណភាព ក្នុងឆ្នាំដែលកន្លងផុតទៅវិញ ត្រូវធ្វើឡើងនៅក្រសួងមហាផ្ទៃ ដែលមានសៀវភៅអត្រានុកូលដ្ឋានឆ្នាំចាស់តម្កល់ទុក។[119]

សម្រង់សំបុត្រមរណភាព និងសម្រង់សំបុត្របញ្ជាក់មរណភាព ត្រូវស្រង់ចេញពីសៀវភៅអត្រានុកូលដ្ឋានមរណភាព និងសៀវភៅអត្រានុកូលដ្ឋានបញ្ជាក់មរណភាពដែលតម្កល់ទុក ដោយស្រង់យកតែខ្លឹមសារ តាមសំណើរបស់អ្នកមកសុំស្រង់តែប៉ុណ្ណោះ។[120]

ចំពោះការសុំចម្លង ឬសម្រង់សំបុត្រមរណភាព និងសំបុត្របញ្ជាក់មរណភាព អ្នកស្នើសុំត្រូវយកសំបុត្រមរណភាព ឬសំបុត្របញ្ជាក់មរណភាពច្បាប់ដើមមកជាមួយ។ ក្នុងករណីបាត់បង់សំបុត្រអត្រានុកូលដ្ឋានច្បាប់ដើម អ្នកមកសុំអាចសុំចម្លងបាន ត្រូវមានលក្ខខណ្ឌដូចជា រាយការណ៍ជាលាយលក្ខណ៍អក្សរឱ្យបានច្បាស់លាស់ អំពីមូលហេតុនៃបានបាត់បង់ និងត្រូវបញ្ជាក់ពីឃុំ ឬសង្កាត់ លេខសៀវភៅ ឬលេខបញ្ជី និងឆ្នាំដែលបានចុះសៀវភៅអត្រានុកូលដ្ឋាន។[121]

[118] កម្រងឯកសារស្តីពីរបៀបកត់ត្រាការងារអត្រានុកូលដ្ឋាននៃជំពូកទី៤ ស្តីពីអត្រានុកូលដ្ឋានមរណភាព, កក្កដា ២០០៥, ទំព័រ១៤៧(១,២)។

[119] កម្រងឯកសារស្តីពីរបៀបកត់ត្រាការងារអត្រានុកូលដ្ឋាននៃជំពូកទី៤ ស្តីពីអត្រានុកូលដ្ឋានមរណភាព, កក្កដា ២០០៥, ទំព័រ១៤៧(៣)។

[120] កម្រងឯកសារស្តីពីរបៀបកត់ត្រាការងារអត្រានុកូលដ្ឋាននៃជំពូកទី៤ ស្តីពីអត្រានុកូលដ្ឋានមរណភាព, កក្កដា ២០០៥, ទំព័រ១៥៦។

[121] កម្រងឯកសារស្តីពីរបៀបកត់ត្រាការងារអត្រានុកូលដ្ឋាននៃជំពូកទី៤ ស្តីពីអត្រានុកូលដ្ឋានមរណភាព, កក្កដា ២០០៥, ទំព័រ១៤៧(៤,៥)។

# ជំពូកទី៣

# សារៈប្រយោជន៍ បញ្ហាប្រឈម និង ដំណោះស្រាយនៃអគ្រោនុក្កូលដ្ឋាន

# ជំពូកទី៣
# សារៈប្រយោជន៍ បញ្ហាប្រឈម និងដំណោះស្រាយនៃអត្រានុកូលដ្ឋាន

## ៣.១ សារៈប្រយោជន៍នៃអត្រានុកូលដ្ឋាន

អត្រានុកូលដ្ឋាន ជាសេវាមូលដ្ឋានរបស់រដ្ឋដែលផ្តល់ប្រយោជន៍ចំពោះសង្គមជាតិផង និងប្រជាពលរដ្ឋផង ដែលចូលរួមចំណែកក្នុងការអភិវឌ្ឍវិស័យសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីសង្គមមានភាពសុខសាន្ត និងសុវត្ថិភាពដ៏រឹងមាំ។ សៀវភៅអត្រានុកូលដ្ឋានបានតម្កល់ទុកជាសក្ខីកម្មដែលមានប្រយោជន៍សម្រាប់ទិន្នន័យវិភាគនូវឯកសារសុខភាព អប់រំ និងសេវាសង្គមគ្រប់ប្រភេទ ដូចជា សម្រាប់ធ្វើបញ្ជីបោះឆ្នោត ទិញលក់អលចនវត្ថុ និងចលនវត្ថុ ជាដើម។[122] អត្រានុកូលដ្ឋានផ្តល់នូវសារៈប្រយោជន៍សំខាន់ពីរ គឺចំពោះសង្គមជាតិ និងចំពោះពលរដ្ឋ។

### ៣.១.១ សម្រាប់សង្គមជាតិ

ការចុះសៀវភៅអត្រានុកូលដ្ឋាន បានជួយពង្រឹងនីតិរដ្ឋ និងអភិវឌ្ឍប្រទេសជាតិ មានន័យថា អត្រានុកូលដ្ឋានជាយុទ្ធសាស្ត្ររួមក្នុងការធានានូវការអនុវត្តច្បាប់ ព្រោះថាប្រសិនបើប្រជាពលរដ្ឋមានឯកសារអត្រានុកូលដ្ឋានគ្រប់ៗគ្នានោះ ការប្រតិបត្តិច្បាប់ និងដំណើរការស្ថាប័ននានា អាចប្រព្រឹត្តបានទៅយ៉ាងរលូន និងមានប្រសិទ្ធភាពខ្ពស់។[123]

មិនតែប៉ុណ្ណោះ ការចុះសៀវភៅអត្រានុកូលដ្ឋាននេះ ក៏បានជួយលើកម្ពស់កិត្យានុភាពជាតិ សំដៅលើបើប្រជាពលរដ្ឋមានសំណុំឯកសារផ្ទាល់ខ្លួនគ្រប់ៗគ្នា នោះពលរដ្ឋបានបំពេញកាតព្វកិច្ចរបស់ខ្លួន ហើយតម្រូវឱ្យខ្លួនមានកាតព្វកិច្ចក្នុងសង្គម ដែលជាហេតុធ្វើឱ្យសង្គមមានការអភិវឌ្ឍតាមគោលការណ៍នីតិរដ្ឋ និងលទ្ធិប្រជាធិបតេយ្យ ដែលទាំងនេះហើយ ជាភាពថ្លៃថ្នូរ និងកិត្តិយសរបស់ប្រទេសជាតិ។[124]

ម៉្យាងទៀត ឯកសារអត្រានុកូលដ្ឋានគឺជាភស្តុតាងក៏មានតម្លៃបំផុតក្នុងជីវិតរបស់មនុស្សម្នាក់ៗសម្រាប់បញ្ជាក់ពីអត្តសញ្ញាណនៃរូបវន្តបុគ្គល និងស្ថានភាពស៊ីវិលរបស់ខ្លួនក្នុងគោលដៅលើកស្ទួយ ករណីយកិច្ចរបស់ប្រជាពលរដ្ឋម្នាក់ៗ ដែលជួយពង្រឹងសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ។[125]

---

[122] កម្រងឯកសារស្តីពីរបៀបកត់ត្រាការងារអត្រានុកូលដ្ឋាននៃជំពូកទី១ ស្តីពីទិដ្ឋភាពទូទៅនៃអត្រានុកូលដ្ឋាន, កក្កដា ឆ្នាំ២០០៥, ទំព័រ ១២, ចំណុច១.៣។

[123] កម្រងឯកសារស្តីពីរបៀបកត់ត្រាការងារអត្រានុកូលដ្ឋាននៃជំពូកទី១ ស្តីពីទិដ្ឋភាពទូទៅនៃអត្រានុកូលដ្ឋាន, កក្កដា ឆ្នាំ២០០៥, ទំព័រ ១២, ចំណុច១.៣.១(១)។

[124] កម្រងឯកសារស្តីពីរបៀបកត់ត្រាការងារអត្រានុកូលដ្ឋាននៃជំពូកទី១ ស្តីពីទិដ្ឋភាពទូទៅនៃអត្រានុកូលដ្ឋាន, កក្កដា ឆ្នាំ២០០៥, ទំព័រ ១២, ចំណុច១.៣(២)។

[125] កម្រងឯកសារស្តីពីរបៀបកត់ត្រាការងារអត្រានុកូលដ្ឋាននៃជំពូកទី១ ស្តីពីទិដ្ឋភាពទូទៅនៃអត្រានុកូលដ្ឋាន, កក្កដា ឆ្នាំ២០០៥, ទំព័រ ១២, ចំណុច១.៣(៣)។

### ៣.១.២ សម្រាប់ពលរដ្ឋ

ការចុះសៀវភៅអត្រានុកូលដ្ឋាន មានសារៈប្រយោជន៍ដល់ពលរដ្ឋដូចខាងក្រោម៖[126]

- សម្រាប់បញ្ជាក់ពីឋានៈ និងសិទ្ធិក្នុងរង្វង់គ្រួសារ
- សម្រាប់សុំលិខិតឆ្លងដែន
- សម្រាប់សុំអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងចេញសៀវភៅគ្រួសារ និងប័ណ្ណស្នាក់នៅ
- សម្រាប់សុំចូលបម្រើការងារផ្សេងៗ ដើម្បីបញ្ជាក់ថា បុគ្គលម្នាក់គ្រប់លក្ខខណ្ឌអាយុបំពេញការងារបាន
- សម្រាប់ចុះឈ្មោះចូលរៀនតាមគ្រឹះស្ថានសិក្សានានា
- សម្រាប់ចុះឈ្មោះបោះឆ្នោត និងឈរឈ្មោះបោះឆ្នោត
- សម្រាប់ការពារសិទ្ធិរបស់បុគ្គលម្នាក់ ជាពិសេសស្ត្រី និងកុមារ
- សម្រាប់ពេលសវនាការ ឬពេលដោះស្រាយវិវាទ។

## ៣.២. បញ្ហាប្រឈមនៃអត្រានុកូលដ្ឋាន

### ៣.២.១. ការគ្រប់គ្រងទិន្នន័យ

ការចុះបញ្ជីអត្រានុកូលដ្ឋាននៅក្នុងប្រទេសកម្ពុជា នៅមិនទាន់មានលក្ខណៈបច្ចេកទេសទំនើប ដែលអាចចុះបញ្ជី និងរក្សាទិន្នន័យតាមប្រព័ន្ធឌីជីថលនៅឡើយនោះទេ។ ការចុះបញ្ជីអត្រានុកូលដ្ឋានគឺធ្វើឡើងតែនៅក្នុងសៀវភៅ និងសំបុត្រអត្រានុកូលដ្ឋានតែប៉ុណ្ណោះ ដែលអាចប្រឈមមុខនឹងហានិភ័យជាច្រើនដូចជា គ្រោះទឹកជំនន់ អគ្គិភ័យ ការធ្វេសប្រហែសក្នុងការទុកដាក់សៀវភៅរបស់មន្ត្រីអត្រានុកូលដ្ឋាន ការសឹករេចរិលនៃក្រដាស និងករណីប្រធានសក្តិផ្សេងៗទៀតដែលធ្វើឱ្យបាត់បង់នូវទិន្នន័យដើមដែលបង្កជាផលលំបាកជាច្រើនដល់អាជ្ញាធរមានសមត្ថកិច្ច និងប្រជាពលរដ្ឋផ្ទាល់ ព្រោះថាសំបុត្រកំណើតច្បាប់ដើមគឺចេញជូនសាមីខ្លួនតែមួយសន្លឹកប៉ុណ្ណោះ ក្នុងករណីបាត់បង់សៀវភៅ ឬសំបុត្រអត្រានុកូលដ្ឋានរបស់បុគ្គលម្នាក់ដោយសារមូលហេតុណាមួយដែលរៀបរាប់ខាងលើ ធ្វើឲ្យបាត់បង់ប្រភពទិន្នន័យ ឬអត្តសញ្ញាណពិតប្រាកដ ដូច្នេះតើបុគ្គលនោះត្រូវស្នើសុំសំបុត្រអត្រានុកូលដ្ឋានថ្មីម្តងទៀតឬយ៉ាងណា?

ទោះបីជាមានការគាំទ្រគម្រោងវាយបញ្ចូលទិន្នន័យអត្រានុកូលដ្ឋានកំណើត និងបញ្ជាក់កំណើតទៅក្នុងព័ត៌មានវិទ្យាសម្រាប់សំបុត្រអត្រានុកូលដ្ឋានទាំងអស់ដែលបានអនុវត្តនៅអំឡុងឆ្នាំ២០០២ ដល់ ឆ្នាំ២០០៦ ដោយស្កេន និងតម្កល់ទុកជាមួយនឹងទិន្នន័យទាំងអស់ក្នុងប្រព័ន្ធទិន្នន័យអត្រានុកូលដ្ឋានថ្មី ប៉ុន្តែជាក់ស្តែងប្រព័ន្ធនេះដំណើរការតែចំពោះអត្រានុកូលដ្ឋានកំណើតតែប៉ុណ្ណោះ ចំពោះអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍ និង

[126] កម្រងឯកសារស្តីពីរបៀបកត់ត្រាការងារអត្រានុកូលដ្ឋាននៃជំពូកទី១ ស្តីពីទិដ្ឋភាពទូទៅនៃអត្រានុកូលដ្ឋាន, កក្កដា ឆ្នាំ២០០៥, ទំព័រ ១៣, ចំណុច១.៣.២។

មរណភាពពុំមាននោះទេ។ ម្យ៉ាងទៀតនាពេលបច្ចុប្បន្នគម្រោងមួយនេះត្រូវបានផ្អាក ដែលធ្វើឱ្យមជ្ឈមណ្ឌលទិន្នន័យអត្រានុកូលដ្ឋានបានដំណើរការតិចតួចបំផុត រីឯការស្រាវជ្រាវរបស់នាយកដ្ឋានអត្រានុកូលដ្ឋាននៅមានកម្រិតនៅឡើយ។

### ៣.២.២. កត្តាមន្ត្រីអត្រានុកូលដ្ឋាន

ការចុះបញ្ជីអត្រានុកូលដ្ឋាន តាមរយៈការសិក្សាផ្ទៀងផ្ទាត់ទិន្នន័យទៅលើប្រជាពលរដ្ឋនាពេលកន្លងមក ក្រសួងមហាផ្ទៃបានកត់សម្គាល់ឃើញថា ប្រជាពលរដ្ឋដែលកំពុងជួបប្រទះបញ្ហាខុសទិន្នន័យ អត្តសញ្ញាណរបស់ខ្លួននៃអត្រានុកូលដ្ឋានប្រភេទតែមួយលើសពីមួយដង ជាពិសេសការចុះបញ្ជីក្នុងអំឡុងពេលយុទ្ធនាការចុះបញ្ជីអត្រានុកូលដ្ឋានចល័ត។ មិនតែប៉ុណ្ណោះ ការបំពេញមុខងារចុះបញ្ជីអត្រានុកូលដ្ឋាន គឺជាជាសមត្ថកិច្ចរបស់មន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់ដែលជាបញ្ហាចោទចម្បង ព្រោះថាមន្ត្រីអត្រានុកូលដ្ឋានមួយចំនួនរងការរិះគន់ថាបានបំពេញការងារចុះបញ្ជីអត្រានុកូលដ្ឋានដោយខ្វះការប្រុងប្រយ័ត្ន ការយល់ដឹងរបស់មន្ត្រីនោះនៅមានកម្រិត និងការផ្លាស់ប្តូរមន្ត្រីអត្រានុកូលដ្ឋានជាញឹកញាប់ ជាហេតុនាំឱ្យមានការយឺតយ៉ាវ និងកំហុសឆ្គងពេលចុះបញ្ជីអត្រានុកូលដ្ឋានជូនប្រជាពលរដ្ឋ។

### ៣.២.៣. កត្តាប្រជាពលរដ្ឋ

ការផ្សព្វផ្សាយអំពីសារៈប្រយោជន៍នៃអត្រានុកូលដ្ឋាននៅមិនទាន់លក្ខណៈទូលំទូលាយ ជាពិសេសនៅតំបន់ដាច់ស្រយាល និងប្រជាពលរដ្ឋដែលមានជីវភាពខ្វះខាត ជាហេតុធ្វើឱ្យប្រជាពលរដ្ឋភាគច្រើនយល់ថាដំណើរការនីតិវិធីមានលក្ខណៈស្មុគស្មាញ ចំណាយពេលវេលា និងមិនមានប្រយោជន៍ចំពោះខ្លួនឡើយ។ ម្យ៉ាងទៀត ការយល់ដឹងរបស់ប្រជាពលរដ្ឋមួយចំនួននៅមានកម្រិត ពុំយល់ដឹងពីបែបបទនៃការស្នើសុំសំបុត្រអត្រានុកូលដ្ឋាន នាំឱ្យសាមីខ្លួនជួបការលំបាកយ៉ាងខ្លាំងក្នុងការស្នើសុំ ព្រមទាំងចំណាយពេលវេលាជាច្រើន ចំណែកឯប្រជាពលរដ្ឋមួយចំនួនធំ ធ្វេសប្រហែស មិនយកចិត្តទុកដាក់លើការផ្ទៀតផ្ទាត់ព័ត៌មានរបស់ខ្លួនដោយពឹងផ្អែកលើមន្ត្រីអត្រានុកូលដ្ឋានទាំងស្រុង ជាហេតុធ្វើឱ្យមានបញ្ហាកើតឡើងជាពិសេសការខុសទិន្នន័យអត្រានុកូលដ្ឋាន។

## ៣.៣. ដំណោះស្រាយ

រាល់បញ្ហាសុទ្ធតែមានដំណោះស្រាយ ក្នុងនោះបញ្ហាដែលប្រជាពលរដ្ឋជួបប្រទះញឹកញាប់ជាងគេ គឺការខុសទិន្នន័យរវាងបញ្ជី និងសំបុត្រអត្រានុកូលដ្ឋានដូចជាឈ្មោះ អាយុ ថ្ងៃខែឆ្នាំកំណើតជាអាទិ៍ ដូច្នេះហើយក្រសួងមហាផ្ទៃបានចេញសេចក្តីណែនាំការកែតម្រូវ និងមោឃភាពទិន្នន័យនៃបញ្ជីអត្រានុកូលដ្ឋានក្នុងឆ្នាំ២០១៧ និងឆ្នាំ២០១៩ បានចេញសេចក្តីណែនាំឲ្យបន្តការអនុវត្តសេចក្តីណែនាំហូតដល់បច្ចុប្បន្ន។ ការដោះស្រាយត្រូវបែងចែកជាពីរគឺ ការកែតម្រូវទិន្នន័យអត្រានុកូលដ្ឋាន(៣.៣.១) និងមោឃភាពទិន្នន័យអត្រានុកូលដ្ឋាន (៣.៣.២)។

### ៣.៣.១. ការកែតម្រូវទិន្នន័យអត្រានុកូលដ្ឋាន

#### ក. ទិន្នន័យនៃបញ្ជីអត្រានុកូលដ្ឋានដែលអាចកែតម្រូវបាន

ទិន្នន័យនៃបញ្ជីអត្រានុកូលដ្ឋានអាចកែតម្រូវបាន គឺជាទិន្នន័យដែលសរសេរខុស ឬភាន់ច្រឡំព័ត៌មានដោយមន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់មានដូចខាងក្រោម៖[127]

- ការខុសឆ្គងអក្ខរាវិរុទ្ធ នាមត្រកូល និង/ឬនាមខ្លួន ជាអក្សរខ្មែរ និងអក្សរឡាតាំង របស់សាមីខ្លួន ឬរបស់ឪពុក ឬរបស់ម្ដាយ មានន័យថាសូរសំឡេងដូចគ្នា ឬប្រហាក់ប្រហែលគ្នា ប៉ុន្តែការសរសេរខុសគ្នា ។
- ការសរសេរខុស ភេទ នៅពេលចុះបញ្ជីដូចជា ភេទ ប្រុស តែសរសេរដាក់ថា ភេទ ស្រី ឬ ភេទស្រី តែសរសេរដាក់ថា ភេទ ប្រុស។
- ការចុះបញ្ជីដោយភាន់ច្រឡំលើថ្ងៃខែកំណើតរបស់សាមីខ្លួន ឬរបស់ឪពុក ឬរបស់ម្ដាយ។
- ខុសថ្ងៃកំណើតសុរិយគតិ (ដូចជាថ្ងៃទី៣០ ខែកុម្ភៈ ឬថ្ងៃទី៣១ ខែមេសា)។
- ខុសថ្ងៃកំណើតចន្ទគតិ ដូចជាសរសេរចុះដាក់ថ្ងៃចន្ទ ទី១៣ ខែមេសា ឆ្នាំ១៩៧២ ប៉ុន្តែជាក់ស្តែងថ្ងៃទី១៣ ខែមេសា ឆ្នាំ១៩៧២ ជាថ្ងៃព្រហស្បតិ៍។
- ការភាន់ច្រឡំទីតាំងភូមិសាស្ត្ររដ្ឋបាល ដូចជាសរសេរដាក់ថា ស្រុកកំពង់សៀម ខេត្តកំពង់ស្ពឺ ប៉ុន្តែជាក់ស្តែង ស្រុកកំពង់សៀម ស្ថិតក្នុងខេត្តកំពង់ចាម។
- ខ្ទង់ទីកន្លែងកំណើត បានសរសេរខុសពីទីកន្លែងកំណើតដែលសាមីខ្លួនបានកើតជាក់ស្តែងសរសេរខុសទីតាំងភូមិសាស្ត្ររដ្ឋបាលនាសម័យដែលបុគ្គលនោះកើត ឧទាហរណ៍បញ្ជីកំណើតរបស់បុគ្គលម្នាក់បានចុះថា កើតឆ្នាំ១៩៨៥ នៅស្រុកមង្គលបុរី ខេត្តបន្ទាយមានជ័យ ប៉ុន្តែក្នុងអំឡុងឆ្នាំ ១៩៨៥ ស្រុកមង្គលបុរី ស្ថិតនៅក្នុងខេត្តបាត់ដំបង ពីព្រោះមិនទាន់បង្កើតខេត្តបន្ទាយមានជ័យនៅឡើយ។
- ការខកខានមិនបានចុះព័ត៌មាននៅក្នុងបញ្ជីអត្រានុកូលដ្ឋាន លើកលែងតែការបន្ថែមទិន្នន័យព័ត៌មានណាដែលធ្វើឱ្យសាមីខ្លួនរួចផុតពីការទទួលខុសផ្លូវច្បាប់។
- សម្រេចមោឃភាពលើបញ្ជីអត្រានុកូលដ្ឋាន និងដកហូតសំបុត្រអត្រានុកូលដ្ឋានទាំងឡាយណាដែលបានចុះជាន់គ្នា ឬចុះខុសពីបែបបទនីតិវិធីនៃការងារអត្រានុកូលដ្ឋាន។
- កែតម្រូវទិន្នន័យអត្រានុកូលដ្ឋានតាមសេចក្តីសម្រេចរបស់តុលាការ។

[127] សេចក្តីណែនាំរបស់ក្រសួងមហាផ្ទៃស្តីពីការបន្តដំណើរការកែតម្រូវនិងការធ្វើមោឃភាពទិន្នន័យនៃបញ្ជីអត្រានុកូលដ្ឋាន, លេខ០៤៥/សណន, ២៣ ធ្នូ ២០១៩, ទំព័រ១, ចំណុច(I)។

**ខ. សមត្ថកិច្ច និងទីកន្លែងដាក់ពាក្យ**

ក្នុងឆ្នាំកំពុងអនុវត្ត ការកែតម្រូវទិន្នន័យ និងការធ្វើមោឃភាពបញ្ជីអត្រានុកូលដ្ឋាន ជាសមត្ថកិច្ចរបស់មន្ត្រីអត្រានុកូលដ្ឋាន ឃុំ សង្កាត់ ។[128] សាមីខ្លួន ឬអាណាព្យាបាល ឬញាតិជានីតិជនដែលនៅក្នុងផ្ទះជាមួយ អាចដាក់ពាក្យសុំកែតម្រូវនៅឃុំ សង្កាត់។

ក្នុងឆ្នាំកន្លងផុត ការកែតម្រូវទិន្នន័យ និងការធ្វើមោឃភាពបញ្ជីអត្រានុកូលដ្ឋាន ជាសមត្ថកិច្ចរបស់មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ។[129] សាមីខ្លួន ឬអាណាព្យាបាល ឬញាតិជានីតិជនដែលនៅក្នុងផ្ទះជាមួយ អាចដាក់ពាក្យសុំកែតម្រូវនៅនាយកដ្ឋានអត្រានុកូលដ្ឋាន នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ឬនៅសាលាក្រុង ស្រុក ខណ្ឌ នៃទីតាំងដែលបញ្ជីអត្រានុកូលដ្ឋានរបស់សាមីខ្លួនបាននឹងកំពុងរក្សាទុក។

ករណីដែលមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិមិនអាចកែតម្រូវទិន្នន័យព័ត៌មានដូចមានក្នុងចំណុច"ក" ជាសមត្ថកិច្ចរបស់តុលាការ។[130] សាមីខ្លួន ឬអាណាព្យាបាល ឬញាតិជានីតិជនដែលនៅក្នុងផ្ទះជាមួយ អាចដាក់ពាក្យសុំទៅសាលាដំបូងរាជធានី ខេត្ត ដើម្បីចេញសេចក្តីសម្រេច បង្គាប់មកមន្ត្រីអត្រានុកូលដ្ឋានឱ្យកែតម្រូវ។

**គ. ឯកសារយោងសម្រាប់ស្នើសុំកែតម្រូវ**

ឯកសារភ្ជាប់ក្នុងការស្នើសុំកែតម្រូវ មានដូចខាងក្រោម៖[131]

– បញ្ជី ឬសេចក្តីចម្លងអត្រានុកូលដ្ឋានដែលមានកាលបរិច្ឆេទក្នុងឆ្នាំប្រតិទិន ដែលត្រូវកែតម្រូវ ឬត្រូវមោឃភាព
– សំបុត្រអត្រានុកូលដ្ឋានច្បាប់ដើម (ករណីបាត់សំបុត្រអត្រានុកូលដ្ឋានច្បាប់ដើម សាមីខ្លួន ឬអាណាព្យាបាលត្រូវភ្ជាប់មកជាមួយនូវពាក្យបណ្តឹងពីប៉ុស្តិ៍នគរបាលរដ្ឋបាល)
– សៀវភៅស្នាក់នៅ និង/ឬសៀវភៅគ្រួសារ
– អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែន(បើមាន)
– ឯកសារពាក់ព័ន្ធផ្សេងៗទៀតដូចជា អត្តសញ្ញាណប័ណ្ណមន្ត្រីរាជការ សញ្ញាបត្រ។ល។

[128] សេចក្តីណែនាំរបស់ក្រសួងមហាផ្ទៃស្តីពីការបន្តដំណើរការកែតម្រូវនិងការធ្វើមោឃភាពទិន្នន័យនៃបញ្ជីអត្រានុកូលដ្ឋាន, លេខ០៤៥/សណន, ២៣ ធ្នូ ២០១៩, ទំព័រ២, ចំណុច II (១)។

[129] សេចក្តីណែនាំរបស់ក្រសួងមហាផ្ទៃស្តីពីការបន្តដំណើរការកែតម្រូវនិងការធ្វើមោឃភាពទិន្នន័យនៃបញ្ជីអត្រានុកូលដ្ឋាន, លេខ០៤៥/សណន, ២៣ ធ្នូ ២០១៩, ទំព័រ២, ចំណុច II (២)។

[130] សេចក្តីណែនាំរបស់ក្រសួងមហាផ្ទៃស្តីពីការបន្តដំណើរការកែតម្រូវនិងការធ្វើមោឃភាពទិន្នន័យនៃបញ្ជីអត្រានុកូលដ្ឋាន, លេខ០៤៥/សណន, ២៣ ធ្នូ ២០១៩, ទំព័រ២, ចំណុច II (៣)។

[131] សេចក្តីណែនាំរបស់ក្រសួងមហាផ្ទៃស្តីពីការបន្តដំណើរការកែតម្រូវនិងការធ្វើមោឃភាពទិន្នន័យនៃបញ្ជីអត្រានុកូលដ្ឋាន, លេខ០៤៥/សណន, ២៣ ធ្នូ ២០១៩, ទំព័រ២, ចំណុច III (២.២)។

រាល់ឯកសារភ្ជាប់ត្រូវថតចម្លងដោយមានបញ្ជាក់នីត្យានុកូលភាពត្រឹមត្រូវ លើកលែងសំបុត្រអត្រានុកូលដ្ឋានច្បាប់ដើម និងសេចក្តីចម្លងអត្រានុកូលដ្ឋានទាំងអស់។

### ៣.៣.២. មោឃភាពទិន្នន័យអត្រានុកូលដ្ឋាន

ក្នុងករណី ការចុះបញ្ជីអត្រានុកូលដ្ឋានណាមួយ មានភាពផ្ទុយនឹងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តដែលមានជាធរមាន ឬចុះបញ្ជីអត្រានុកូលដ្ឋានលើសពី០១ (មួយ) ដងនៅកន្លែងដដែល ឬកន្លែងផ្សេងទៀត នោះនាយកដ្ឋានត្រូវជូនដំណឹងដល់សាមីខ្លួន ឬអាណាព្យាបាល តាមរយៈអាជ្ញាធរមូលដ្ឋានពាក់ព័ន្ធ ដើម្បីឱ្យដាក់ពាក្យសុំធ្វើមោឃភាពបញ្ជីអត្រានុកូលដ្ឋានដែលបានចុះលើសពី០១ (មួយ) ដងនោះ ដើម្បីធ្វើការជ្រើសរើសយកបញ្ជីណាមួយដែលជាទិន្នន័យត្រឹមត្រូវសម្រាប់ប្រើប្រាស់ជាផ្លូវការ។[132]

ប្រសិនបើសាមីខ្លួន ឬអាណាព្យាបាលមិនព្រមដាក់ពាក្យសុំធ្វើមោឃភាពបញ្ជីណាមួយក្នុងអំឡុងពេល ៦០ (ហុកសិប) ថ្ងៃ ចាប់ពីថ្ងៃទទួលបានលិខិតជូនដំណឹង មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិមានសិទ្ធិចេញសេចក្តីសម្រេចធ្វើមោឃភាពសំបុត្រអត្រានុកូលដ្ឋាន និងបញ្ជីអត្រានុកូលដ្ឋានដែលបានចុះកាលបរិច្ឆេទមុន ដោយរក្សាទុកសំបុត្រអត្រានុកូលដ្ឋាន និងបញ្ជីអត្រានុកូលដ្ឋានដែលបានចុះកាលបរិច្ឆេទក្រោយ។[133]

[132] សេចក្តីណែនាំរបស់ក្រសួងមហាផ្ទៃស្តីពីការបន្តដំណើរការកែតម្រូវនិងការធ្វើមោឃភាពទិន្នន័យនៃបញ្ជីអត្រានុកូលដ្ឋាន, លេខ០៤៥/សណន, ២៣ ធ្នូ ២០១៩, ទំព័រ២, ចំណុច ខ(៣)។

[133] សេចក្តីណែនាំរបស់ក្រសួងមហាផ្ទៃស្តីពីការបន្តដំណើរការកែតម្រូវនិងការធ្វើមោឃភាពទិន្នន័យនៃបញ្ជីអត្រានុកូលដ្ឋាន, លេខ០៤៥/សណន, ២៣ ធ្នូ ២០១៩, ទំព័រ៥, ចំណុច ខ(៤)។

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

អត្រានុកូលដ្ឋាន គឺជាចំណងរួមភ្ជាប់សញ្ជាតិទៅនឹងរដ្ឋ និងស្ថានភាពជាក់ស្តែង ដែលបង្កើតឱ្យជនណាម្នាក់ មានលក្ខណៈសម្បត្តិអាចទទួលបានសិទ្ធិ និងករណីយកិច្ចតាមផ្លូវច្បាប់ ចាប់តាំងពីពេលចាប់កំណើតរហូតដល់ទទួលមរណភាពបាន គឺតាមរយៈការសុំចុះអត្រានុកូលដ្ឋាន។ ប្រជាពលរដ្ឋខ្មែរគ្រប់រូបមានកាតព្វកិច្ចទៅស្នើសុំចុះបញ្ជីអត្រានុកូលដ្ឋាន នៅក្នុងសៀវភៅអត្រានុកូលដ្ឋាន ដើម្បីទទួលបានសំបុត្រអត្រានុកូលដ្ឋានមួយច្បាប់ ធ្វើជាភស្តុតាងបញ្ជាក់ពីអត្តសញ្ញាណ និងបុគ្គលភាពគតិយុត្ត។ ក្នុងនោះដែរ ការចុះបញ្ជីអត្រានុកូលត្រូវបានបែងចែកតាមព្រឹត្តិការណ៍គតិយុត្តសំខាន់ៗបីគឺ កំណើត អាពាហ៍ពិពាហ៍ និងមរណភាព។

ដើម្បីធ្វើការស្នើសុំសំបុត្រអត្រានុកូលដ្ឋានច្បាប់ដើមមួយសន្លឹកនៃប្រភេទណាមួយ គឺត្រូវឆ្លងកាត់បែបបទ នីតិវិធីដែលកំណត់ដោយច្បាប់ជាធរមាន។ ម្យ៉ាងទៀត សំបុត្រអត្រានុកូលដ្ឋាន គឺជាសំបុត្រសម្រាប់កត់ត្រាភាពស៊ីវិលទាំងប្រជាពលរដ្ឋ និងជនបរទេសដែលរស់នៅស្របច្បាប់ក្នុងប្រទេសកម្ពុជា ដូច្នេះហើយទើបមានការកំណត់យ៉ាងច្បាស់ពីលក្ខខណ្ឌ ដើម្បីឱ្យពលរដ្ឋ និងជនបរទេសមានភាពងាយស្រួលក្នុងការអនុវត្ត។ ចំពោះការស្នើសុំអត្រានុកូលដ្ឋានកំណើត គឺចាំបាច់ទាមទារឱ្យមានការរាយការណ៍ពីកំណើតរបស់ទារកដែលទើបនឹងកើតក្នុងរយៈពេលកំណត់ ដើម្បីបញ្ជាក់ពីសញ្ជាតិ ទីកន្លែងរស់នៅ និងឪពុកម្តាយរបស់ទារក។ រីឯការស្នើសុំអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍ គឺធ្វើឡើងតាមការស្នើសុំដោយបុរសម្នាក់ និងស្ត្រីម្នាក់ ដែលប្តេជ្ញាថាខ្លួននឹងរួមរស់នៅជាមួយគ្នាជាប្តីប្រពន្ធដែលទទួលស្គាល់ដោយច្បាប់ ដោយត្រូវចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ និងចុះបញ្ជីអាពាហ៍ពិពាហ៍នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ដើម្បីបង្កើតបានចំណងគតិយុត្តរវាងគ្នា ដោយត្រូវសហការនិងសង្គ្រោះគ្នាទៅវិញទៅមក ជៀសវាងការរំលាយ និងបង្កើតអាពាហ៍ពាហ៍ថ្មីទៅតាមទំនើងចិត្តរបស់ខ្លួន។ ចំណែកឯការស្នើសុំអត្រានុកូលដ្ឋានមរណភាពវិញ ទោះបីជាមរណភាព បាននាំឱ្យបុគ្គលិកលក្ខណៈគតិយុត្តរបស់រូបវន្តបុគ្គលម្នាក់ត្រូវបានបញ្ចប់ ប៉ុន្តែច្បាប់បានកំណត់ទទួលស្គាល់ និងផ្តល់នូវអានុភាពខាងផ្លូវច្បាប់មួយចំនួនដែរ ដូច្នេះហើយទើបទាមទារឱ្យមានការចុះបញ្ជីមរណភាពឱ្យបានត្រឹមត្រូវនៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ដើម្បីបានជាប្រយោជន៍ដល់សាច់ញាតិដែលនៅរស់។

ការចុះបញ្ជីអត្រានុកូលដ្ឋាន ពិតជាមានសារៈសំខាន់ណាស់ គឺជាសេវាមូលដ្ឋានរបស់រដ្ឋដែលផ្តល់ប្រយោជន៍ចំពោះសង្គមជាតិផង និងប្រជាពលរដ្ឋផង កាលណាប្រជាពលរដ្ឋមានសំណុំឯកសារផ្ទាល់ខ្លួនគ្រប់ៗគ្នា នោះពលរដ្ឋបានបំពេញកាតព្វកិច្ចរបស់ខ្លួន ហើយតម្រូវឱ្យខ្លួនមានកាតព្វកិច្ចក្នុងសង្គម ដែលជាហេតុធ្វើឱ្យសង្គមមានការអភិវឌ្ឍតាមគោលការណ៍នីតិរដ្ឋ និងលទ្ធិប្រជាធិបតេយ្យ។ ទោះបីជាយ៉ាងណា ប្រជាពលរដ្ឋខ្មែរនៅពុំទាន់ទទួលបានព័ត៌មានទូលំទូលាយនៅឡើយពីអត្រានុកូលដ្ឋាន ដែលជាហេតុធ្វើឱ្យមានកំហុសកើតឡើងនៅពេលចុះបញ្ជីអត្រានុកូលដ្ឋាន ដូចជាព័ត៌មានក្នុងការចុះបញ្ជី ការធ្វើអត្រានុកូលដ្ឋានជាន់គ្នាជាដើម។

ដើម្បីធានាបានសំបុត្រអត្រានុកូលដ្ឋានមួយសន្លឹកជូនប្រជាពលរដ្ឋ មន្ត្រីអត្រានុកូលដ្ឋានដើរតួនាទីយ៉ាងសំខាន់ ដោយប្រឹងប្រែងកសាង និងពង្រឹងសមត្ថភាព យកចិត្តទុកដាក់ មានទំនួលខុសត្រូវខ្ពស់ក្នុងការបំពេញការងារ បញ្ចូលទិន្នន័យដោយប្រុងប្រយ័ត្នបំផុត ផ្ទៀងផ្ទាត់ទិន្នន័យរវាងសំបុត្រ និងគល់បញ្ជីអត្រានុកូលដ្ឋានឱ្យបានត្រឹមត្រូវ និងអនុញ្ញាតឲ្យសាមីខ្លួនដែលដាក់ពាក្យស្នើសុំ ពិនិត្យមើលអត្តសញ្ញាណរបស់ខ្លួនឱ្យបានគ្រប់ជ្រុងជ្រោយ មុននឹងយកសំបុត្រអត្រានុកូលដ្ឋានទៅប្រើប្រាស់ ដើម្បីជៀសវាងការយកសំបុត្រអត្រានុកូលដ្ឋានដែលខុសទិន្នន័យទៅប្រើប្រាស់ ធ្វើឱ្យខាតបង់ពេលវេលាដល់មន្ត្រីអត្រានុកូលដ្ឋាន និងសាមីខ្លួនផ្ទាល់ដែលត្រូវកែតម្រូវនៅពេលក្រោយ។ ម្យ៉ាងទៀត ត្រូវជួយផ្សព្វផ្សាយដល់ប្រជាពលរដ្ឋក្នុងឃុំ សង្កាត់ឱ្យបានយល់ដឹងពីកាតព្វកិច្ចរបស់ខ្លួនចំពោះអត្រានុកូលដ្ឋាន និងបង្កលក្ខណៈងាយស្រួលដល់ប្រជាពលរដ្ឋដែលមកទំនាក់ទំនងពីការងារអត្រានុកូលដ្ឋាន និងចលនាប្រជាពលរដ្ឋរស់នៅក្នុងឃុំ សង្កាត់របស់ខ្លួនឱ្យមកចុះសៀវភៅអត្រានុកូលដ្ឋានឱ្យបានគ្រប់ៗគ្នា និងទាន់ពេលវេលា។

# អនុសាសន៍

# អនុសាសន៍

ការចុះបញ្ជីអត្រានុកូលដ្ឋាននៅប្រទេសកម្ពុជា គឺនៅមានកម្រិតនៅឡើយ ដោយសារប្រជាពលរដ្ឋនៅពុំទាន់យល់ដឹងបានទូលំទូលាយអំពីសារៈប្រយោជន៍ និងដំណើរការនៃការចុះបញ្ជីអត្រានុកូលដ្ឋាន ជាពិសេសប្រជាពលរដ្ឋក្រីក្រ និងនៅតំបន់ដាច់ស្រយាល។ ដូច្នេះហើយ អាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធនឹងការងារអត្រានុកូលដ្ឋាន ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ គប្បីចូលរួមបណ្តុះបណ្តាលប្រជាពលរដ្ឋឱ្យមានការយល់ដឹងពីច្បាប់ឱ្យបានទូលំទូលាយ ដោយផ្សព្វផ្សាយពីសារៈប្រយោជន៍ នីតិវិធីនៃការចុះបញ្ជីអត្រានុកូលដ្ឋានតាមភូមិ ឃុំឬសង្កាត់ តាមរយៈទូរទស្សន៍ វិទ្យុ និងបង្កើតវីដេអូខ្លីៗតាមប្រព័ន្ធទំនាក់ទំនងសង្គម។

ចំពោះបែបបទ នីតិវិធីនៃការចុះបញ្ជីអត្រានុកូលដ្ឋានគឺមានលក្ខណៈស្មុគស្មាញ និងបច្ចេកទេសមិនទាន់មានភាពទំនើប ដែលបណ្តាលឱ្យមានកំហុសបច្ចេកទេសកើតឡើងលើព័ត៌មានរបស់ប្រជាពលរដ្ឋ ដូចជាឈ្មោះ ភេទ ថ្ងៃខែឆ្នាំកំណើត និងទីកន្លែងកំណើតជាអាទិ៍។ ដូច្នេះហើយអង្គភាព ឬស្ថាប័នមានសមត្ថកិច្ចគប្បីជួយពង្រឹង បណ្តុះបណ្តាលសមត្ថភាពមន្ត្រីអត្រានុកូលដ្ឋានតាមតំបន់នីមួយៗ ឱ្យយកចិត្តទុកដាក់បំពេញមុខងាររបស់ខ្លួនដោយការប្រុងប្រយ័ត្នខ្ពស់ និងពង្រឹងការត្រួតពិនិត្យលើការអនុវត្តការងាររបស់មន្ត្រីអត្រានុកូលដ្ឋាន ឃុំ ឬសង្កាត់ មានទំនួលខុសត្រូវខ្ពស់ក្នុងការបំពេញព័ត៌មានរបស់ប្រជាពលរដ្ឋ ដោយធានាថាទិន្នន័យរវាងបញ្ជី និងសំបុត្រអត្រានុកូលដ្ឋានគឺត្រឹមត្រូវដូចគ្នា ក្នុងករណីបើមានកំហុសកើតឡើងដោយអចេតនា ត្រូវកែសម្រួលឡើងវិញឆាប់រហ័ស ដើម្បីធ្វើឱ្យប្រជាពលរដ្ឋមានទំនុកចិត្តជឿជាក់លើអាជ្ញាធរមួយរយភាគរយ។ ម្យ៉ាងទៀតស្ថាប័នមានសមត្ថកិច្ចលើការងារអត្រានុកូលដ្ឋាន គប្បីបង្កើតប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋានដែលមានបច្ចេកទេសទំនើបបែបឌីជីថល អាចឱ្យប្រជាពលរដ្ឋស្នើសុំចុះបញ្ជីអត្រានុកូលដ្ឋាន និងមន្ត្រីអត្រានុកូលដ្ឋានអាចបញ្ចូលទិន្នន័យអត្រានុកូលដ្ឋានទៅក្នុងប្រព័ន្ធ ជំនួសដោយការប្រើប្រាស់សៀវភៅអត្រានុកូលដ្ឋាន ដើម្បីសម្រួលដល់ការចំណាយពេលវេលារបស់ប្រជាពលរដ្ឋ ជៀសវាងការបញ្ចូលព័ត៌មានខុស និងការបាត់បង់ទិន្នន័យដើម។

ជាពិសេសប្រជាពលរដ្ឋខ្មែរត្រូវចូលរួមបំពេញកាតព្វកិច្ចរបស់ខ្លួន ក្នុងការទៅស្នើសុំចុះបញ្ជីអត្រានុកូលដ្ឋានប្រភេទណាមួយដែលខ្លួនត្រូវការ ដោយអនុវត្តតាមលក្ខខណ្ឌ និងបែបបទដែលកំណត់ដោយច្បាប់ជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។

# ឯកសារយោង

# ឯកសារយោង

## ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

អនុសញ្ញាស្ដីពីសិទ្ធិកុមារ, ២០ វិច្ឆិកា ១៩៨៩។

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣។

ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

ច្បាប់ស្ដីពី អាពាហ៍ពិពាហ៍ និងគ្រួសារ, លេខ ៥៦ ក្រ., ២៦ កក្កដា ១៩៨៩។

ច្បាប់ស្ដីពី ឯកពន្ធភាព, លេខ នស/រកម/១០០៦/០២៦, ២១ តុលា ២០០៦។

អនុក្រឹត្យស្ដីពីអត្រានុកូលដ្ឋាន, លេខ ១០៣ អនក្រ.បក, ២៩ ធ្នូ ២០០០។

អនុក្រឹត្យស្ដីពីការកែសម្រួល អនុក្រឹត្យស្ដីពីអត្រានុកូលដ្ឋាន, លេខ ១៧ អនក្រ.បក, ១៤ មិថុនា ២០០៤។

អនុក្រឹត្យស្ដីពីការកែសម្រួលចំណុច "ក" និង "ខ" មាត្រា៥៩ថ្មីស្ទួន នៃអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ១៤ ខែមិថុនា ឆ្នាំ២០០៤ ស្ដីពីការកែសំរួលអនុក្រឹត្យស្ដីពីអត្រានុកូលដ្ឋាន, លេខ ១០៦ អនក្រ.បក, ២៣ សីហា ២០០៥។

អនុក្រឹត្យស្ដីពីការកំណត់បែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស, លេខ ១៨៣ អនក្រ.បក, ២៣ វិច្ឆិកា ២០០៨។

អនុក្រឹត្យស្ដីពីមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ, លេខ ១៣៤ អនក្រ.បក, ០៤ កក្កដា ២០១៦។

## សេចក្ដីណែនាំរបស់ក្រសួង

សេចក្ដីណែនាំរបស់ក្រសួងមហាផ្ទៃ ស្ដីពីការចុះសៀវភៅអត្រានុកូលដ្ឋានឱ្យមាននិរន្តរភាពក្រោយបញ្ចប់យុទ្ធនាការចុះសៀវភៅអត្រានុកូលដ្ឋានចល័ត, លេខ០០៨សណន, ១៨ ឧសភា ២០០៧។

សេចក្ដីណែនាំរបស់ក្រសួងមហាផ្ទៃ ស្ដីពីកាអនុវត្តអនុក្រឹត្យស្ដីពីកំណត់បែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស, លេខ ០០១សណន, ១២ មករា ២០០៩។

**ឃុំ សង្កាត់** (៣)...............................  **ឆ្នាំ** (៦)...............................................

## បញ្ជីមរណភាពសម្រាប់ជនបរទេស និងជនអន្តោប្រវេសន្តស្របច្បាប់

| | | | | |
|---|---|---|---|---|
| នាមត្រកូល(៧) | | | ភេទ(៩) | |
| នាមខ្លួនសព(៨) | | | | |
| ជាអក្សរឡាតាំង(១០) | នាមត្រកូល | | | |
| | នាមខ្លួនសព | | | |
| សញ្ជាតិ(១១) | | | | |
| ថ្ងៃ ខែ ឆ្នាំកំណើត(១២) | | | | |
| ទីកន្លែងកំណើត (១៣) | | | | |
| ស្ថានភាពសព(នៅលីវ មានប្ដី មានប្រពន្ធ ពោះម៉ាយ មេម៉ាយ) (១៤) | | | | |
| មុខរបរមុនពេលស្លាប់ (១៥) | | | | |
| ទីលំនៅមុនពេលស្លាប់ (១៦) | | | | |
| ទីលំនៅឯបរទេស (១៧) | | | | |
| លិខិតឆ្លងដែនលេខ មានសុពលភាពត្រឹមថ្ងៃ ខែ ឆ្នាំ (១៨) | | | | |
| ទិដ្ឋាការ ឬលិខិតអនុញ្ញាតឱ្យស្នាក់នៅកម្ពុជាលេខ ថ្ងៃខែឆ្នាំ(១៩) | | | | |
| ថ្ងៃ ខែ ឆ្នាំស្លាប់ (២០) | | | | |
| ទីកន្លែងស្លាប់ (២១) | | | | |
| មូលហេតុស្លាប់តាមបណ្ដឹងរបស់អ្នករាយការណ៍(២២) | | | | |
| នាមត្រកូល និងនាមខ្លួនឪពុកសព (២៣) | | | ថ្ងៃ ខែ ឆ្នាំកំណើត (២៤) | |
| ជាអក្សរឡាតាំង (២៥) | | | | |
| សញ្ជាតិ(២៦) | | | | |
| ទីលំនៅបច្ចុប្បន្នរបស់ឪពុកសព (២៧) | | | | |
| នាមត្រកូល និងនាមខ្លួនម្ដាយសព (២៨) | | | ថ្ងៃ ខែ ឆ្នាំកំណើត (២៩) | |
| ជាអក្សរឡាតាំង (៣០) | | | | |
| សញ្ជាតិ(៣១) | | | | |
| ទីលំនៅបច្ចុប្បន្នរបស់ម្ដាយសព (៣២) | | | | |
| នាមត្រកូល និងនាមខ្លួនអ្នករាយការណ៍អំពីសព(៣៣) | | | ភេទ(៣៤) | សញ្ជាតិ(៣៥) |
| ជាអក្សរឡាតាំង (៣៦) | | | | |
| ថ្ងៃ ខែ ឆ្នាំកំណើត (៣៧) | | | | |
| ត្រូវជាអ្វីនឹងសព (៣៨) | | | | |
| មុខរបរបច្ចុប្បន្ន (៣៩) | | | | |
| ទីលំនៅបច្ចុប្បន្ន (៤០) | | | | |
| លិខិតឆ្លងដែនលេខ មានសុពលភាពត្រឹមថ្ងៃ ខែ ឆ្នាំ (៤១) | | | | |
| លេខអត្តសញ្ញាណប័ណ្ណ (៤២) | | | | |

ជនណាបានរាយការណ៍មិនពិតអំពីអត្រានុកូលដ្ឋាន មន្ត្រីអត្រានុកូលដ្ឋានណាបានសមគំនិត ឃុបឃិត ក្លែងបន្លំ ចុះសៀវភៅអត្រានុកូលដ្ឋានឱ្យអ្នកដែលមកសុំ ជននោះ និងមន្ត្រីអត្រានុកូលដ្ឋាននោះ នឹងត្រូវទទួលទោសតាមបញ្ញត្តិច្បាប់ ។

(៤៤) ធ្វើនៅ................. ថ្ងៃទី......... ខែ............... ឆ្នាំ..........

(៤៣) **ស្នាមមេដៃស្ដាំអ្នករាយការណ៍**

(៤៥) **មន្ត្រីអត្រានុកូលដ្ឋាន**

(៤៦) ហត្ថលេខា និងត្រា

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**~~រាជធានី~~ ខេត្ត** (១) ---- *កណ្តាល* ------

**~~ក្រុង~~ ស្រុក ~~ខណ្ឌ~~** (២) ----- *ល្វាឯម* ----

**ឃុំ ~~សង្កាត់~~** (៣) ----- *កោះកែវ* ----

**លេខ** (៤)-------- *០៣* -----------------

**សៀវភៅមរណភាពលេខ** (៥)--០១/២០១៤--

**ឆ្នាំ** (៦)---------- *២០១៤* ----------------

## សំបុត្រមរណភាព

| | | | |
|---|---|---|---|
| នាមត្រកូល (៧) | | *ស៊ីម* | ភេទ (៩) |
| នាមខ្លួនសព (៨) | | *វណ្ណា* | *ស្រី* |
| ជាអក្សរឡាតាំង (១០) | នាមត្រកូល | SIM | |
| | នាមខ្លួនសព | VANNA | |
| សញ្ជាតិ (១១) | | *ខ្មែរ* | |
| ថ្ងៃ ខែ ឆ្នាំកំណើត (១២) | | *ថ្ងៃ ច័ន្ទ ទី ២៦ ខែ តុលា ឆ្នាំ ១៩៣១* | |
| ទីកន្លែងកំណើត (១៣)<br>ភូមិ ឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ រាជធានី ខេត្ត ប្រទេស | | ........ភូមិបឹង *ឃុំស្វាយអន្ទរ ស្រុកព្រៃវែង ខេត្តព្រៃវែង ប្រទេសកម្ពុជា* ................................................ | |
| ស្ថានភាពសព (១៤)<br>នៅលីវ មានប្តី មានប្រពន្ធ ពោះម៉ាយ មេម៉ាយ | | *មានប្តី* | |
| ថ្ងៃ ខែ ឆ្នាំស្លាប់ (១៥) | | *ថ្ងៃ ច័ន្ទ ទី ២០ ខែ មករា ឆ្នាំ ២០១៤* | |
| នាមត្រកូល និង នាមខ្លួនឪពុកសព (១៦) | | *ស៊ីម សារឿន* | សញ្ជាតិ (១៧) |
| ជាអក្សរឡាតាំង (១៨) | | SIM SAROEUN | *ខ្មែរ* |
| ថ្ងៃ ខែ ឆ្នាំកំណើត (១៩) | | *ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ១៩១០* | |
| នាមត្រកូល និង នាមខ្លួនម្តាយសព (២០) | | *ស្រី នាង* | សញ្ជាតិ (២១) |
| ជាអក្សរឡាតាំង (២២) | | SREY NEANG | *ខ្មែរ* |
| ថ្ងៃ ខែ ឆ្នាំកំណើត (២៣) | | *ថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ១៩១២* | |

(២៤) ធ្វើនៅ...កោះកែវ..... ថ្ងៃទី *២២* ខែ *មករា* ឆ្នាំ *២០១៤*

(២៥) **មន្ត្រីអត្រានុកូលដ្ឋាន**

**មេឃុំ**

(២៦) *ហត្ថលេខា និងត្រា*

*ប៊ុត ប៊ុន*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជធានី ~~ខេត្ត~~ (១)** ---- *កណ្ដាល* -----

**~~ក្រុង~~ ស្រុក ~~ខណ្ឌ~~ (២)** ----- *ល្វាឯម* ------

**ឃុំ ~~សង្កាត់~~ (៣)** ----- *កោះកែវ*-----

## សេចក្ដីចម្លងសំបុត្រមរណភាព

| ចម្លងសំបុត្រមរណភាពចេញពី | | (៤) សៀវភៅមរណភាព<br>លេខ៖ *០១/២០១៤* | (៥) សំបុត្រមរណភាព<br>លេខ *០៣* ចុះថ្ងៃទី *២២* ខែ *មករា* ឆ្នាំ *២០១៤* |
|---|---|---|---|
| នាមត្រកូល (៦) | | *ស៊ីម* | ភេទ(៨) |
| នាមខ្លួនសព (៧) | | *វណ្ណា* | *ស្រី* |
| ជាអក្សរឡាតាំង(៩) | នាមត្រកូល | SIM | |
| | នាមខ្លួនសព | VANNA | |
| សញ្ជាតិ (១០) | | *ខ្មែរ* | |
| ថ្ងៃ ខែ ឆ្នាំកំណើត (១១) | | *ថ្ងៃ ច័ន្ទ ទី ២៦ ខែ តុលា ឆ្នាំ ១៩៣១* | |
| ទីកន្លែងកំណើត (១២)<br>ភូមិ ឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ រាជធានី ខេត្ត ប្រទេស | | .........ភូមិបឹង *ឃុំស្វាយអន្ទរ ស្រុកព្រៃវែង ខេត្តព្រៃវែង ប្រទេសកម្ពុជា*<br>........................................................................................................ | |
| ស្ថានភាពសព (១៣)<br>នៅលីវ មានប្ដី មានប្រពន្ធ ពោះម៉ាយ មេម៉ាយ | | *មានប្ដី* | |
| ថ្ងៃ ខែ ឆ្នាំស្លាប់ (១៤) | | *ថ្ងៃ ច័ន្ទ ទី ២០ ខែ មករា ឆ្នាំ ២០១៤* | |
| នាមត្រកូល និងនាមខ្លួនឪពុកសព (១៥) | | *ស៊ីម សារឿន* | សញ្ជាតិ(១៦) |
| ជាអក្សរឡាតាំង (១៧) | | SIM SAROEUN | *ខ្មែរ* |
| ថ្ងៃ ខែ ឆ្នាំកំណើត (១៨) | | *ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ១៩១០* | |
| នាមត្រកូល និងនាមខ្លួនម្ដាយសព (១៩) | | *ស្រី នាង* | សញ្ជាតិ(២០) *ខ្មែរ* |
| ជាអក្សរឡាតាំង (២១) | | SREY NEANG | |
| ថ្ងៃ ខែ ឆ្នាំកំណើត (២២) | | *ថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ១៩១២* | |

(២៣) ធ្វើនៅ...កោះកែវ..... ថ្ងៃទី *១៧* ខែ *មីនា* ឆ្នាំ *២០១៤*

(២៤) **មន្ត្រីអត្រានុកូលដ្ឋាន**

*មេឃុំ*

(២៥) *ហត្ថលេខា និងត្រា*

*ប៊ុត ប៊ុន*

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

~~រាជធានី~~ ខេត្ត (១) ----- *កណ្ដាល* -----
~~ក្រុង~~ ស្រុក ~~ខណ្ឌ~~ (២) ----- *កោះធំ* ------
ឃុំ ~~សង្កាត់~~ (៣) --------ព្រែកស្ដី------

## សេចក្ដីចម្លងសំបុត្របញ្ជាក់មរណភាព

| ចម្លងសំបុត្របញ្ជាក់មរណភាពចេញពី | | (៤) សៀវភៅបញ្ជាក់មរណភាព លេខ៖ *០១/២០០៦* | (៥) សំបុត្របញ្ជាក់មរណភាព លេខ០៥ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៦ |
|---|---|---|---|
| នាមត្រកូល (៦) | | *ម៉ែន* | ភេទ(៨) |
| នាមខ្លួនសព (៧) | | *សាម៉ន* | *ប្រុស* |
| ជាអក្សរឡាតាំង(៩) | នាមត្រកូល | *MEN* | |
| | នាមខ្លួនសព | *SAMAN* | |
| សញ្ជាតិ (១០) | | *ខ្មែរ* | |
| ថ្ងៃ ខែ ឆ្នាំកំណើត (១១) | | *ថ្ងៃ សុក្រ ទី ០៣ ខែ មីនា ឆ្នាំ ១៩៣១* | |
| ទីកន្លែងកំណើត (១២) ភូមិ ឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ រាជធានី ខេត្ត ប្រទេស | | .... ភូមិវាលស្បូវ ឃុំវាលស្បូវ ស្រុកកៀនស្វាយ ខេត្តកណ្ដាល ប្រទេសកម្ពុជា | |
| ស្ថានភាពសព (១៣) នៅលីវ មានប្ដី មានប្រពន្ធ ពោះម៉ាយ មេម៉ាយ | | *ពោះម៉ាយ* | |
| ថ្ងៃ ខែ ឆ្នាំស្លាប់ (១៤) | | *ថ្ងៃ ពុធ ទី ១៥ ខែ មករា ឆ្នាំ ១៩៩៧* | |
| នាមត្រកូល និងនាមខ្លួនឪពុកសព (១៥) | | *ម៉ែន សាម៉ែន* | សញ្ជាតិ(១៦) |
| ជាអក្សរឡាតាំង (១៧) | | MEN SAMEN | *ខ្មែរ* |
| ថ្ងៃ ខែ ឆ្នាំកំណើត (១៨) | | *ថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ១៩១០* | |
| នាមត្រកូល និងនាមខ្លួនម្ដាយសព (១៩) | | *សួន ប្រាថ្នា* | សញ្ជាតិ(២០) |
| ជាអក្សរឡាតាំង (២១) | | *SUON PRATHNA* | *ខ្មែរ* |
| ថ្ងៃ ខែ ឆ្នាំកំណើត (២២) | | *ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ១៩១២* | |

លេខ(ក)..... *០១ ក.ធ.ប.ម* ...........
យើង(ខ).... *អភិបាលស្រុកកោះធំ* .................................
បានឃើញនិងបញ្ជាក់ថា ហត្ថលេខាខាងស្ដាំនេះ ជាហត្ថលេខា
របស់លោក(គ)..... *អ៊ុច ប៊ុនគីម*....... ជាមន្ត្រីរក្សាសៀវភៅ
អត្រានុកូលដ្ឋាន(ឃ)......... ស្រុកកោះធំ........ពិតប្រាកដមែន ។
(ង) ធ្វើនៅកោះធំ..... ថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៤
(ច) *ហត្ថលេខា និងត្រា*
*ខៀវ សំអាត*

(២៤) ធ្វើនៅ...កោះធំ.... ថ្ងៃទី *១៤* ខែ *មករា* ឆ្នាំ *២០១៤*
**(២៥) មន្ត្រីរក្សាសៀវភៅអត្រានុកូលដ្ឋាន**
*ហត្ថលេខា*
*អ៊ុច ប៊ុនគីម*

# ឧបសម្ព័ន្ធទី៤

# អនុក្រឹត្យស្តីពីអគ្រានុក្រូលដ្ឋាន

# ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២000

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាល**
**លេខ :** ១០៣ អនក្រ.បក

# អនុក្រឹត្យ
# ស្ដីពី
# អគ្គានុកូលដ្ឋាន
# រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១/៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញច្បាប់ស្ដីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ដែលប្រកាសអោយប្រើដោយក្រឹត្យលេខ ៥៦ ក្រ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៨៩
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីសញ្ជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម ០១/៩៦ /០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១៩ អនក្រ ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងយុត្តិធម៌

តាមការឯកភាពរបស់គណៈរដ្ឋមន្ត្រីក្នុងកិច្ចប្រជុំពេញអង្គថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០០០

## សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះ មានគោលដៅកំណត់បែបបទ និងនីតិវិធីនៃការងារអត្រានុកូលដ្ឋាន នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២.-**

អត្រានុកូលដ្ឋាន គឺជាចំណងរួមភ្ជាប់សញ្ជាតិទៅនឹងរដ្ឋ និងស្ថានភាពជាក់ស្តែង ដែលជននោះមាននៅក្នុងត្រកូល-គ្រួសារខ្លួន និងសង្គមជាតិ និងដែលបង្កើតឱ្យជននោះមានសិទ្ធិ និងករណីយកិច្ច ។

សំបុត្រអត្រានុកូលដ្ឋាន គឺជាសំបុត្រសម្រាប់កត់ត្រាភាពជាស៊ីវិលនៃពលរដ្ឋខ្មែរ និងជនបរទេសដែលរស់នៅស្របច្បាប់ ក្នុងដែនសមត្ថកិច្ចកំណត់ នៃច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា ។

សំបុត្រអត្រានុកូលដ្ឋានមាន សំបុត្រកំណើត សំបុត្រអាពាហ៍ពិពាហ៍ និងសំបុត្រមរណភាព ។

**មាត្រា ៣.-**

ការសុំចុះអត្រានុកូលដ្ឋានក្នុងសៀវភៅអនុត្រានុកូលដ្ឋាន ជាកាតព្វកិច្ចរបស់ប្រជាពលរដ្ឋខ្មែរគ្រប់រូប ។

**មាត្រា ៤.-**

រាល់ការសុំចុះសៀវភៅអនុត្រានុកូលដ្ឋាន កំណើត និងមរណភាព អ្នករាយការណ៍ និង/ឬ សាក្សី និង ឬសាមីខ្លួនត្រូវទៅផ្ទាល់ចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ។

ចំពោះការសុំចុះសៀវភៅអត្រានុកូលដ្ឋាន អាពាហ៍ពិពាហ៍ សាមីខ្លួន និងសាក្សី ត្រូវទៅផ្ទាល់ចំពោះមុខមន្ត្រីអត្រា-នុកូលដ្ឋាន ។

**មាត្រា ៥.-**

ទម្រង់បែបបទ និងសំបុត្រអត្រានុកូលដ្ឋាន នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តអោយឯកភាពគ្នាទូទាំងប្រ-ទេស ។

គំរូសំបុត្រអត្រានុកូលដ្ឋាន ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

**មាត្រា ៦.-**

ការចុះសៀវភៅអត្រានុកូលដ្ឋាន សម្រាប់ព្រះរាជវង្សានុវង្ស ត្រូវអនុវត្តដោយឡែក ដោយប្រគល់ភារកិច្ចនេះជូនរដ្ឋមន្ត្រីព្រះបរមរាជវាំង ។

**មាត្រា ៧.-**

រាល់សំបុត្រអត្រានុកូលដ្ឋានថតចម្លង មិនមានតម្លៃជាផ្លូវការឡើយ ។

មន្ត្រីអត្រានុកូលដ្ឋាន មិនត្រូវបញ្ជាក់លើសំបុត្រអត្រានុកូលដ្ឋានថតចម្លងទេ ។

រាល់ការចម្លង ឬសម្រង់សំបុត្រអត្រានុកូលដ្ឋាន មានចែងក្នុងជំពូកទី ១០ នៃអនុក្រឹត្យនេះ ។

## ជំពូកទី ២

## អំពីមន្ត្រីអត្រានុកូលដ្ឋាន

**មាត្រា ៨.-**

មេឃុំ ឬចៅសង្កាត់ ជាមន្ត្រីអត្រានុកូលដ្ឋានក្នុងដែនដីឃុំ ឬសង្កាត់ ដែលខ្លួនគ្រប់គ្រង ។

នៅពេលដែលមេឃុំ ឬចៅសង្កាត់អវត្តមាន ត្រូវផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរឱ្យជំទប់ ឬចៅសង្កាត់រង តាមឋានានុក្រម និងរាយការណ៍ជូនអភិបាលស្រុក ឬខណ្ឌតាមផ្លូវការ ។

ក្នុងករណីមេឃុំ ឬចៅសង្កាត់អវត្តមានដោយស្លាប់ ឬដោយបញ្ឈប់ពីមុខតំណែង ក្នុងចន្លោះពេលដែលមិនទាន់មានការរៀបចំមេឃុំ ឬចៅសង្កាត់ថ្មី សិទ្ធិជាមន្ត្រីអត្រានុកូលដ្ឋាន ត្រូវប្រគល់ជូនទៅជំទប់ ឬចៅសង្កាត់រង តាមឋានានុក្រម ។

**មាត្រា ៩.-**

មន្ត្រីអត្រានុកូលដ្ឋានមានភារកិច្ច :

- ទទួលពិនិត្យ កត់ត្រា រឿងហេតុសំខាន់ៗទាក់ទងនឹង កំណើត អាពាហ៍ពិពាហ៍ មរណភាពនៃជនទាំងឡាយចុះក្នុងសៀវភៅអត្រានុកូលដ្ឋាន
- ចេញសេចក្ដីចម្លង ឬសម្រង់នៃអត្រានុកូលដ្ឋាន ដែលមានក្នុងឆ្នាំមិនទាន់ដាច់
- កែតម្រូវអក្ខរាវិរុទ្ធ លើអត្រានុកូលដ្ឋានក្នុងឆ្នាំមិនទាន់ដាច់ តាមលក្ខខណ្ឌមាត្រា ១៣ នៃអនុក្រឹត្យនេះ
- អនុញ្ញាតអោយរៀបចំអាពាហ៍ពិពាហ៍ និងធ្វើបុណ្យបូជា ឬបញ្ចុះសព
- ទទួលខុសត្រូវចំពោះសំបុត្រអត្រានុកូលដ្ឋាន ដែលខ្លួនបានអនុវត្ត
- ចុះហត្ថលេខា និងបោះត្រា លើសំបុត្រអត្រានុកូលដ្ឋាន
- កែតម្រូវ ឬបដិសេធអត្រានុកូលដ្ឋាន តាមអំណាចសាលក្រមស្ថាពររបស់តុលាការ ឬតាមបទប្បញ្ញត្តិនៃច្បាប់
- ថែរក្សាទុកដាក់សៀវភៅអត្រានុកូលដ្ឋាន តាមប្រភេទឱ្យបានគត់មត់ល្អ ងាយស្រួលក្នុងការតាមដាន និងការគ្រប់គ្រង
- បញ្ជូនសៀវភៅអត្រានុកូលដ្ឋានឆ្នាំដែលដាច់ទៅ យកទៅតម្កល់ទុកនៅសាលាស្រុក ឬខណ្ឌផ្ទាល់ ០១ ច្បាប់ និងនៅតុលាការខេត្ត ឬក្រុងសាមី ០១ច្បាប់
- ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋក្នុងឃុំ ឬសង្កាត់ ឱ្យបានយល់ដឹងអំពីកាតព្វកិច្ចរបស់ខ្លួន ចំពោះអត្រានុកូលដ្ឋាន និងបង្កលក្ខណៈងាយស្រួលដល់ប្រជាពលរដ្ឋ ដែលមកទំនាក់ទំនងអំពីអត្រានុកូលដ្ឋាន
- ធ្វើរបាយការណ៍អំពី កំណើត អាពាហ៍ពិពាហ៍ មរណភាព ចំនួនគ្រួសារ ចំនួនប្រជាពលរដ្ឋក្នុងឃុំ ឬសង្កាត់ជារៀងរាល់ខែ និង រាល់ដំណាច់ឆ្នាំនីមួយៗ ផ្ញើទៅសាលាស្រុក ឬសាលាខណ្ឌ សាមី
- សហការជាមួយសមត្ថកិច្ចនៅមូលដ្ឋាន អំពីការងារអត្រានុកូលដ្ឋានក្នុងករណីចាំបាច់ ។

**មាត្រា ១០.-**

រាល់ការអនុវត្តការងារអត្រានុកូលដ្ឋាននៅ ស្ថានទូត ស្ថានអគ្គកុងស៊ុល ឬស្ថានកុងស៊ុល នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំនៅឯបរទេស ត្រូវមានទម្រង់បែបបទ និងសំបុត្រអត្រានុកូលដ្ឋានដូចការងារអត្រានុកូលដ្ឋាន ដែលអនុវត្តនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

ក្នុងករណីចាំបាច់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិអន្តរជាតិ ត្រូវធ្វើសេចក្តីណែនាំបន្ថែម ដោយប្រកាសរួម ។

**មាត្រា ១១.-**

ស្ថានទូត ស្ថានអគ្គកុងស៊ុល ឬស្ថានកុងស៊ុល នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំនៅឯបរទេស ត្រូវមានមន្ត្រី ០១រូប នៃស្ថានទូត ស្ថានអគ្គកុងស៊ុល ឬស្ថានកុងស៊ុល ឱ្យទទួលមុខងារជាមន្ត្រីអត្រានុកូលដ្ឋាន តាមសេចក្តីសម្រេចចាត់តាំងពីរដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដោយជូនព័ត៌មានទៅ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

បែបបទនៃការបំពេញមុខងារជាមន្ត្រីអត្រានុកូលដ្ឋាននេះ ត្រូវពិគ្រោះរវាងក្រសួងមហាផ្ទៃ និងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ។

## ជំពូកទី ៣

## អំពីសៀវភៅអត្រានុកូលដ្ឋាន

**មាត្រា ១២.-**

ក្នុងឃុំ ឬសង្កាត់នីមួយៗ ត្រូវមានសៀវភៅអត្រានុកូលដ្ឋាន សម្រាប់កត់ត្រាអំពីកំណើត អាពាហ៍ពិពាហ៍ មរណភាព បញ្ជាក់កំណើត បញ្ជាក់អាពាហ៍ពិពាហ៍ និងបញ្ជាក់មរណភាព ។

សៀវភៅនេះត្រូវធ្វើជា០២ច្បាប់ដូចគ្នា តាមប្រភេទនីមួយៗ តាមគំរូដែលកំណត់ ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

សៀវភៅនេះត្រូវចុះចំនួនសន្លឹក និងចុះលេខរៀងសន្លឹក ពីសន្លឹកទី១ ដល់សន្លឹកចុងក្រោយ ។ សន្លឹកទី១ និង សន្លឹកចុងក្រោយត្រូវសរសេរជាអក្សរ និងត្រូវចុះហត្ថលេខាពេញដោយអភិបាលស្រុក ឬអភិបាលខណ្ឌ ។ សន្លឹកទី២ និងសន្លឹកដទៃទៀតដែលអាចចុះហត្ថលេខាសង្ខេប និងបោះត្រារបស់អភិបាលស្រុក ឬអភិបាលខណ្ឌគ្រប់សន្លឹក ។

**មាត្រា ១៣.-**

សៀវភៅអត្រានុកូលដ្ឋានទាំងអស់ មិនត្រូវឱ្យមាន កោស ឆូត លុប សរសេរជ្រៀតថែមឡើយ ។ បើមានកោស ឆូត លុបត្រូវទុកពាក្យទាំងនោះឱ្យនៅមើលបាន ហើយសរសេរទឹកខ្មៅពណ៌ក្រហមនៅលើរឹមទំព័រខាងឆ្វេងថា យល់ព្រមលុបប៉ុន្មានពាក្យ និងយល់ព្រមថែមប៉ុន្មានពាក្យ ទើបមន្ត្រីអត្រានុកូលដ្ឋាន អ្នករាយការណ៍ និង ឬសាក្សី និង ឬសាមីខ្លួនចុះហត្ថលេខា ឬផ្ដិតមេដៃស្ដាំទាំងអស់គ្នា ។

ចំពោះសន្លឹកណា ដែលសរសេរខុស ត្រូវរក្សាទុកជាឯកសារមិនឱ្យរហែកចោលឡើយ ។

**មាត្រា ១៤.-**

សៀវភៅអត្រានុកូលដ្ឋានតាមឆ្នាំនីមួយៗ ត្រូវបើកឱ្យប្រើប្រាស់ចាប់ពីថ្ងៃទី ០១ ខែ មករា ហើយត្រូវបញ្ឈប់នៅថ្ងៃទី ៣១ ខែ ធ្នូ រៀងរាល់ឆ្នាំ ។

នៅខែមករាឆ្នាំបន្ទាប់ មន្ត្រីអត្រានុកូលដ្ឋាន ត្រូវបញ្ជូនសៀវភៅតាមប្រភេទនីមួយៗ ០១ច្បាប់ ទៅសាលាស្រុក ឬខ័ណ្ឌសាមី ដើម្បីត្រួតពិនិត្យ និងតម្កល់ទុកនៅទីនោះ និងបញ្ជូន ០១ច្បាប់ទៀតដែលដូចគ្នាទៅតម្កល់ទុកនៅតុលាការខេត្ត ឬក្រុងសាមី ដើម្បីមុខការតាមផ្លូវច្បាប់ ។

សៀវភៅអត្រានុកូលដ្ឋាន ដែលបានប្រើប្រាស់នៅស្ថានទូត ស្ថានអគ្គកុងស៊ុល ឬស្ថានកុងស៊ុល នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំនៅឯបរទេស ត្រូវបញ្ជូនតាមរយៈក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នៅខែ មករា ឆ្នាំបន្ទាប់ មកតម្កល់ទុក ០១ច្បាប់ នៅក្រសួងមហាផ្ទៃ និង ០១ច្បាប់ទៀតមកតម្កល់ទុកនៅក្រសួងយុត្តិធម៌ ។

**មាត្រា ១៥.-**

មន្ត្រីអត្រានុកូលដ្ឋាន ត្រូវរៀបចំទុកដាក់ ថែរក្សាសៀវភៅអត្រានុកូលដ្ឋាន និងសំណុំឯកសារដែលពាក់ព័ន្ធការងារអត្រានុកូលដ្ឋានឱ្យបានល្អ និងរក្សាការសម្ងាត់ របស់បុគ្គលម្នាក់ៗ ។

ចំពោះសាលាឃុំ សង្កាត់ណា ដែលមិនធានាសុវត្ថិភាព មន្ត្រីអត្រានុកូលដ្ឋាននៃឃុំ ឬសង្កាត់នោះ ត្រូវផ្ញើសៀវភៅអត្រានុកូលដ្ឋានទៅរក្សាទុកនៅសាលាស្រុក ឬខណ្ឌសាមី ។ ពេលធ្វើអត្រានុកូលដ្ឋាន មន្ត្រីអត្រានុកូលដ្ឋាននោះត្រូវទៅធ្វើនៅសាលាស្រុក ឬខណ្ឌ ទៅតាមបែបបទដូចបានអនុវត្តនៅសាលាឃុំ ឬសង្កាត់ ។

**មាត្រា ១៦.-**

ក្រសួងមហាផ្ទៃមានភារកិច្ចរៀបចំសៀវភៅអត្រានុកូលដ្ឋានឱ្យបានឯកភាពទូទាំងប្រទេស និងបណ្តុះបណ្តាលដល់មន្ត្រីអត្រានុកូលដ្ឋាន អំពីរបៀបកត់ត្រាចូលក្នុងសៀវភៅអត្រានុកូលដ្ឋានតាមប្រភេទនីមួយៗ និងធានាផ្គត់ផ្គង់សៀវភៅ និងសំបុត្រអត្រានុកូលដ្ឋានឱ្យបានគ្រប់គ្រាន់ និងទាន់ពេលវេលាដល់មន្ត្រីអត្រានុកូលដ្ឋាន ។

## ជំពូកទី ៤

## អំពីសំបុត្រកំណើត

**មាត្រា ១៧.-**

បើមានទារកកើត ឪពុក ឬម្តាយ មានកាតព្វកិច្ចត្រូវទៅរាយការណ៍ ចុះសៀវភៅកំណើតនៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន នៅសាលាឃុំ ឬសង្កាត់ នៃលំនៅដ្ឋានអចិន្ត្រៃយ៍របស់ឪពុក ម្តាយទារកនោះ មិនឱ្យហួស ៣០ថ្ងៃដោយបញ្ជាក់ឱ្យបានច្បាស់ថា ឪពុក និងម្តាយនៃទារកនោះ មានខាន់ស្លា ឬឥតខាន់ស្លា ។ បើមានខាន់ស្លាត្រូវបង្ហាញសំបុត្រអាពាហ៍ពិពាហ៍ របស់ឪពុក និងម្តាយទារកនោះ ។

បើឪពុក ម្តាយមានធុរៈទៅមិនបាន ត្រូវពឹងពាក់អ្នកជាសាច់ញាតិសន្តាន ឬអ្នកនៅជិតខាងដែលបានឃើញ និងដឹងឮផ្ទាល់ពីទារកនោះកើតឱ្យទៅចុះសៀវភៅកំណើត ឱ្យបានទាន់ពេលកំណត់ ដោយយកសំបុត្រអាពាហ៍ពិពាហ៍ ឪពុក និងម្តាយទារកនោះជាប់ទៅជាមួយផង ។

### មាត្រា ១៨.-

នាមត្រកូលរបស់ទារក អាចយកត្រកូល ដែលក្រុមគ្រួសារកំណត់យកតាំងពីដូនតាយូរលង់មកហើយ ឬអាចយកឈ្មោះជីតាខាងឪពុក ឬអាចយកឈ្មោះឪពុករបស់ទារកនោះក៏បាន ។

ឪពុក ម្ដាយ ឬអាណាព្យាបាល ជាអ្នកដាក់នាមខ្លួនឱ្យទារក ។

### មាត្រា ១៩.-

បើមានជនណារើសបានទារកដែលគេបោះបង់ចោល ត្រូវយកទៅប្រគល់ឱ្យមន្ត្រីអត្រានុកូលដ្ឋានក្នុងឃុំ ឬសង្កាត់នៃទីកន្លែងដែលរើសទារកនោះ ។ មន្ត្រីអត្រានុកូលដ្ឋាន ត្រូវធ្វើកំណត់ហេតុ និងចុះក្នុងសៀវភៅកំណើត ដោយរកឈ្មោះដាក់ឱ្យ ហើយបើក្នុងករណីចាំបាច់ មន្ត្រីអត្រានុកូលដ្ឋានត្រូវពិគ្រោះយោបល់ជាមួយមន្ត្រីសុខាភិបាល ដើម្បីដាក់ថ្ងៃ ខែ ឆ្នាំកំណើតទារកដែលរើសបាននោះ ដោយស្មាន និងឈ្មោះឪពុក ម្ដាយដាក់ថាមិនស្គាល់ ។

បើមានជនណា សុំទារកដែលរើសបាននោះធ្វើជាកូនចិញ្ចឹម ត្រូវយកនាមត្រកូលនៃអ្នកសុំ ។

ក្នុងករណីគ្មានជនណាសុំទារកដែលរើសបាននោះ ធ្វើជាកូនចិញ្ចឹម មន្ត្រីអត្រានុកូលដ្ឋានត្រូវបញ្ជូនទារកដែលរើសបាននោះ ទៅមជ្ឈមណ្ឌលសង្គ្រោះទារក ឬមជ្ឈមណ្ឌលកុមារកំព្រាដែលនៅជិតបំផុត ដោយភ្ជាប់ជាមួយនូវសំបុត្រកំណើតរបស់ទារកនោះ និងកំណត់ហេតុស្ដីអំពីការប្រគល់ទារកនោះ ជូនមជ្ឈមណ្ឌលសង្គ្រោះទារក ឬមជ្ឈមណ្ឌលកុមារកំព្រា ។

### មាត្រា ២០.-

ចំពោះទារក ឬកុមារ ដែលកំពុងចិញ្ចឹមបីបាច់ថែរក្សា ក្នុងមជ្ឈមណ្ឌលសង្គ្រោះទារក ឬមជ្ឈមណ្ឌលកុមារកំព្រា ហើយដែលពុំទាន់មានសំបុត្រកំណើត ឬសំបុត្របញ្ជាក់កំណើត អ្នកទទួលខុសត្រូវនៃមជ្ឈមណ្ឌលទាំងនោះត្រូវធ្វើសេចក្ដីរាយការណ៍ និងនាំទារក ឬកុមារនោះ ទៅជូនមន្ត្រីអត្រានុកូលដ្ឋាននៃឃុំ សង្កាត់ដែលមជ្ឈមណ្ឌលនោះតាំងនៅ ដើម្បីមន្ត្រីអត្រានុកូលដ្ឋានផ្ដល់សំបុត្រកំណើត ឬសំបុត្របញ្ជាក់កំណើតឱ្យ ។

### មាត្រា ២១.-

ការសុំទារក ឬកុមារ ពីមជ្ឈមណ្ឌលសង្គ្រោះទារក ឬមជ្ឈមណ្ឌលកុមារកំព្រា ការសុំទារកដែលរើសបាន និងការសុំទារក ឬកូនពីឪពុក ម្ដាយធ្វើជាកូនចិញ្ចឹម ត្រូវអនុវត្តទៅតាមនីតិវិធី ដូចមានចែងក្នុងច្បាប់ និងលិខិតបទដ្ឋានជាធរមាន ។

កិច្ចសន្យាសុំកូនខាងលើនេះ ត្រូវចុះក្នុងសៀវភៅអត្រានុកូលដ្ឋាន ។

### មាត្រា ២២.-

បើមានទណ្ឌិតណាម្នាក់សម្រាលកូន ទីកន្លែងកំណើតនៃទារកនោះ ត្រូវយកតាមលំនៅដ្ឋានរបស់ម្ដាយ ឬឪពុក ។

### មាត្រា ២៣.-

ទារកកើតពីឪពុក ម្ដាយគ្មានចំណងអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ ក៏ត្រូវចុះក្នុងសៀវភៅកំណើតដែរ ។ នៅពេលធ្វើសំបុត្រកំណើត បើឪពុក ម្ដាយដែលគ្មានចំណងអាពាហ៍ពិពាហ៍នោះ បានឆ្លើយទទួលស្គាល់ដោយដាក់លាក់ ចំពោះមុខមន្ត្រីអត្រានុកូលដ្ឋានថា ទារកដែលកើតមកនោះជាកូនរបស់ខ្លួន មន្ត្រីអត្រានុកូលដ្ឋានត្រូវចាត់ទុកឪពុក ម្ដាយនោះថា ជាឪពុក ម្ដាយរបស់កូននោះ ។

ករណីមានតែឪពុក ឬមានតែម្ដាយឆ្លើយទទួលស្គាល់តែម្នាក់ឯង ទារកនោះត្រូវចាត់ទុកថាជាកូនរបស់អ្នកដែលបានទទួលស្គាល់តែម្នាក់ឯងតែប៉ុណ្ណោះ ។

ក្រោយពេលឪពុក ឬម្ដាយបានប្ដឹងចុះក្នុងសៀវភៅកំណើត ឪពុក ឬម្ដាយណា ដែលមិនទាន់ទទួលស្គាល់ទារកនោះ ឪពុក ឬម្ដាយនោះ អាចប្ដឹងសុំទទួលស្គាល់កូនជាក្រោយបាន ។

កូនឥតខាន់ស្លាដែលឪពុក ម្ដាយបានទទួលស្គាល់នឹងទៅជាកូនមានខាន់ស្លាបាន ប្រសិនបើក្រោយពីកំណើតកូននោះ ឪពុក ម្ដាយរបស់កូននោះ បានចុះអាពាហ៍ពិពាហ៍ជាមួយគ្នា ។

ការទទួលស្គាល់កូនអាចធ្វើនៅមុនពេលចុះអាពាហ៍ពិពាហ៍ ធ្វើដំណាលគ្នា និងពេលចុះអាពាហ៍ពិពាហ៍ ឬក្រោយពេលចុះអាពាហ៍ពិពាហ៍ក៏បាន ។

**មាត្រា ២៤.-**

ក្រោយពេលចុះសៀវភៅកំណើតរួចហើយ មន្ត្រីអត្រានុកូលដ្ឋានត្រូវប្រគល់ឱ្យអ្នករាយការណ៍ នូវសំបុត្រកំណើតច្បាប់ដើម ០១ សន្លឹកទុកជាសម្គាល់ និងចេញសេចក្ដីចម្លងតាមការស្នើសុំរបស់សាមីខ្លួន ។

**មាត្រា ២៥.-**

បើមានទារកកើតហើយ ទុកឱ្យហួសរយៈពេល ៣០ថ្ងៃ ពុំបានទៅរាយការណ៍ ចុះសៀវភៅកំណើត ឪពុក ឬ ម្ដាយ ឬអាណាព្យាបាល ត្រូវទៅសុំសាលក្រមពីតុលាការខេត្ត ក្រុងសាមី ។

ឪពុក ឬម្ដាយ ឬអាណាព្យាបាលទារកនោះ ត្រូវយកសាលក្រមតុលាការនោះ មកសុំមន្ត្រីអត្រានុកូលដ្ឋានឃុំ ឬសង្កាត់ដែលខ្លួនរស់នៅ ដើម្បីចុះសៀវភៅកំណើត ។

ក្នុងករណីចាំបាច់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ត្រូវធ្វើសេចក្ដីណែនាំបន្ថែម ។

**មាត្រា ២៦.-**

ទារកកើតពីម្ដាយ ឪពុកជាពលរដ្ឋខ្មែរ រស់នៅស្របច្បាប់ឯបរទេស ឬពីឪពុកជាពលរដ្ឋខ្មែរ ម្ដាយជាជនបរទេស ឬពីឪពុកជាជនបរទេស ម្ដាយជាពលរដ្ឋខ្មែរ ឪពុក ម្ដាយ នៃទារកនោះ អាចសុំចុះសៀវភៅកំណើតនៅឯប្រទេសនោះតាមបញ្ញត្តិច្បាប់របស់ប្រទេសនោះ ។ ពេលវិលត្រឡប់មកព្រះរាជាណាចក្រកម្ពុជាវិញ ត្រូវទៅចុះសៀវភៅកំណើតនៅឃុំ ឬសង្កាត់ដែលខ្លួនរស់នៅតាមសំបុត្រកំណើតដែលប្រទេសនោះចេញឱ្យ ដោយយកសញ្ជាតិតាមច្បាប់សញ្ជាតិនៃព្រះរាជាណាចក្រកម្ពុជា ។ មន្ត្រីអត្រានុកូលដ្ឋានត្រូវយកសំបុត្រកំណើតថតចម្លងផ្លូវការនោះទុក ហើយចម្លងចេញពីសៀវភៅ នូវសំបុត្រកំណើតថ្មី ឱ្យយកទៅប្រើប្រាស់ ។

បើឪពុក ម្ដាយនៃទារកនោះ បានទៅរាយការណ៍ចុះសៀវភៅកំណើតនៅឯស្ថានទូត ស្ថានអគ្គកុងស៊ុល ឬស្ថានកុងស៊ុល នៃព្រះរាជាណាចក្រកម្ពុជាប្រចាំនៅប្រទេសនោះ ពេលវិលត្រឡប់មកព្រះរាជាណាចក្រកម្ពុជាវិញ អាចយកសំបុត្រកំណើតដែលប្រគល់ឱ្យនោះមកប្រើប្រាស់ជាផ្លូវការបាន ។

**មាត្រា ២៧.-**

ជនអន្តោប្រវេសន៍ និងជនបរទេស ដែលបានរស់នៅស្របច្បាប់នៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា បានកើតទារកនៅលើទឹកដីព្រះរាជាណាចក្រកម្ពុជា ឪពុក ម្តាយទារកនោះ អាចទៅចុះសៀវភៅកំណើតនៅសាលាឃុំ ឬសង្កាត់ ដែលខ្លួនរស់នៅជាប់លាប់ ឬអាចទៅចុះសៀវភៅកំណើតនៅ ស្ថានទូត ស្ថានអគ្គកុងស៊ុល ឬស្ថានកុងស៊ុល នៃប្រទេសរបស់ខ្លួន ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ។ បើចុះសៀវភៅកំណើតនៅសាលាឃុំ សាលាសង្កាត់ នាមត្រកូល និងនាមផ្ទាល់ខ្លួន និង នាមនៃឪពុក ម្តាយរបស់ទារកនោះ ត្រូវសរសេរជាអក្សរឡាតាំង អមជាមួយអក្សរខ្មែរផង ។

ចំពោះសញ្ជាតិនៃកូននោះ ត្រូវអនុវត្តតាមច្បាប់សញ្ជាតិនៃព្រះរាជាណាចក្រកម្ពុជា ។

## ជំពូកទី ៥

## អំពីសំបុត្រអាពាហ៍ពិពាហ៍

### មាត្រា ២៨.-

បុរស នារីដែលមានបំណងរៀបអាពាហ៍ពិពាហ៍ត្រូវដាក់ពាក្យសុំច្បាប់រៀបអាពាហ៍ពិពាហ៍ទៅមន្ត្រីអត្រានុកូលដ្ឋាននៃឃុំ សង្កាត់ នៃលំនៅដ្ឋានសាមីខ្លួនខាងនារី ។ មន្ត្រីអត្រានុកូលដ្ឋាន ត្រូវពិនិត្យឱ្យបានហ្មត់ចត់នូវពាក្យសុំនោះដោយផ្អែកទៅលើលក្ខខណ្ឌនៃច្បាប់ ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ជាធរមាននៅព្រះរាជាណាចក្រកម្ពុជា ។

### មាត្រា ២៩.-

មន្ត្រីអត្រានុកូលដ្ឋាន ត្រូវបិទប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ ដែលគ្រោងនឹងធ្វើនោះ ផ្សាយជាសាធារណៈ នៅលំនៅដ្ឋាន និងនៅសាលាឃុំ ឬសាលាសង្កាត់ នៃសាមីខ្លួននារី ០១ច្បាប់ ។ ប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ ០២ច្បាប់ទៀត ត្រូវផ្ញើទៅជូនមន្ត្រីអត្រានុកូលដ្ឋានឃុំ ឬសង្កាត់ខាងបុរស ដើម្បីយកទៅបិទផ្សាយនៅលំនៅដ្ឋាន និងបិទនៅសាលាឃុំ ឬសង្កាត់ នៃសាមីខ្លួនបុរស ០១ច្បាប់ ។

ប័ណ្ណប្រកាសត្រូវចុះ :

១- នាមត្រកូល នាមខ្លួន អាយុ មុខរបរ និងលំនៅនៃអនាគត ប្តី ប្រពន្ធ ។

២- នាមត្រកូល នាមខ្លួន អាយុ មុខរបរ និងលំនៅរបស់ឪពុក ម្តាយ នៃអនាគតប្តី ប្រពន្ធ បើឪពុក ឬម្តាយស្លាប់ ត្រូវដាក់ថាស្លាប់

៣- រយៈពេលប្តឹងជំទាស់ ។

ប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ត្រូវបិទផ្សាយក្នុងរយៈពេល ១០ថ្ងៃ មុនថ្ងៃរៀបអាពាហ៍ពិពាហ៍ ដើម្បីឱ្យជនដែលមានផលប្រយោជន៍ក្នុងរឿងនេះ អាចប្តឹងជំទាស់នឹងអាពាហ៍ពិពាហ៍នោះបាន ប្រសិនបើមានការមិនយល់ស្របនឹងអាពាហ៍ពិ-ពាហ៍នោះ ។ ផុតរយៈពេល ១០ថ្ងៃ អាពាហ៍ពិពាហ៍អាចធ្វើទៅបាន បើគ្មានការប្តឹងជំទាស់ ។ បើមានបណ្តឹងជំទាស់នឹងអាចរៀបអាពាហ៍ពិពាហ៍បាន លុះត្រាតែបណ្តឹងជំទាស់ត្រូវបានសមត្ថកិច្ចដោះស្រាយចប់ ។

### មាត្រា ៣០.-

អាពាហ៍ពិពាហ៍ នឹងចាត់ទុកជាត្រឹមត្រូវតាមលក្ខណៈច្បាប់បាន លុះត្រាតែបុរស និងនារី ដែលស្ម័គ្រចិត្តទទួលគ្នាជាប្តី ប្រពន្ធ ចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ នៅចំពោះមុខមន្ត្រីអាត្រានុកូលដ្ឋាន ខាងលំនៅដ្ឋានរបស់នារី ។

កិច្ចសន្យានេះ ត្រូវចុះក្នុងសៀវភៅអាពាហ៍ពិពាហ៍ ហើយត្រូវចុះហត្ថលេខា ដោយមន្ត្រីអត្រានុកូលដ្ឋាន និងផ្តិតមេដៃ ប្តី ប្រពន្ធ និងសាក្សីគ្រប់អាយុការចំនួន ០២នាក់ផង ។

**មាត្រា ៣១.-**

ពេលសាមីខ្លួនជាអនាគត ប្តី និងប្រពន្ធមករាយការណ៍សុំចុះសៀវភៅអាពាហ៍ពិពាហ៍ មន្ត្រីអត្រានុកូលដ្ឋានត្រូវចុះសៀវភៅអាពាហ៍ពិពាហ៍ រួចហើយត្រូវប្រគល់ឱ្យសាមីខ្លួនប្តី ប្រពន្ធនូវសំបុត្រអាពាហ៍ពិពាហ៍ច្បាប់ដើម ០១សន្លឹក និងចេញសេចក្តីចម្លងតាមការស្នើសុំរបស់សាមីខ្លួន ។

**មាត្រា ៣២.-**

ការសុំរៀបអាពាហ៍ពិពាហ៍ រវាងពលរដ្ឋខ្មែរ និងពលរដ្ឋខ្មែរ ឬរវាងពលរដ្ឋខ្មែរ និងជនបរទេស ដែលរស់នៅស្របច្បាប់ឯបរទេស ត្រូវប្រព្រឹត្តទៅនៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាននៃ ស្ថានទូត ស្ថានអគ្គកុងស៊ុល ឬស្ថានកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជា ប្រចាំនៅប្រទេស ដែលគូភាគីមានទីលំនៅ ។ ក្នុងករណីដែលអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងពលរដ្ឋខ្មែរ និងអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស បានប្រព្រឹត្តទៅត្រឹមត្រូវតាមទម្រង់នៃអាពាហ៍ពិពាហ៍ដែលមានចែងក្នុងច្បាប់នៃកន្លែងរៀបអាពាហ៍ពិពាហ៍នោះ ត្រូវទទួលស្គាល់យកជាការបាននៅព្រះរាជាណាចក្រកម្ពុជា ប្រសិនបើអាពាហ៍ពិពាហ៍នោះ មិនផ្ទុយនឹងបទបញ្ញត្តិច្បាប់នៃព្រះ រាជាណាចក្រកម្ពុជា ។ សំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ ឬសេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍នោះ ត្រូវយកមកចុះក្នុងសៀវភៅអាពាហ៍ពិពាហ៍នៃស្ថានទូត ស្ថានអគ្គកុងស៊ុល ឬស្ថានកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជាប្រចាំប្រទេសនៃកន្លែងរៀបអាពាហ៍ពិពាហ៍ នោះ ឬបើប្តី ប្រពន្ធមកតាំងលំនៅនៅព្រះរាជាណាចក្រកម្ពុជាត្រូវយកមកចុះសៀវភៅអាពាហ៍ពិពាហ៍នៅសាលាឃុំ ឬសង្កាត់ដែលខ្លួនបានរស់នៅ ។ ស្ថានទូត ស្ថានអគ្គកុងស៊ុល ឬស្ថានកុងស៊ុល ឬមន្ត្រី អត្រានុកូលដ្ឋាននៅព្រះរាជាណាចក្រកម្ពុជា ត្រូវយកសំបុត្រអាពាហ៍ពិពាហ៍ថតចម្លងផ្លូវការនោះទុក ហើយចម្លងចេញពី សៀវភៅនូវសំបុត្រពាហ៍ពិពាហ៍ថ្មី ឱ្យទៅជននោះយកទៅប្រើប្រាស់ ។

**មាត្រា ៣៣.-**

អាពាហ៍ពិពាហ៍ រវាងពលរដ្ឋខ្មែរ និងជនបរទេស ឬជនអន្តោប្រវេសន៍ ដែលរស់នៅស្របច្បាប់នៅព្រះរាជាណាចក្រកម្ពុជា ត្រូវប្រព្រឹត្តទៅតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៣៤.-**

ជនអន្តោប្រវេសន៍ និងជនបរទេស ដែលរស់នៅស្របច្បាប់នៅលើទឹកដី នៃព្រះរាជាណាចក្រកម្ពុជា អាចរៀបអាពាហ៍ពិពាហ៍ជាមួយជនបរទេស ឬជនអន្តោប្រវេសន៍នោះបាន ដោយអនុវត្តតាមច្បាប់ ស្តីពីអាពាហ៍ពិពាហ៍ ដែលមានចែងនៅក្នុងប្រទេសរបស់ខ្លួន តែត្រូវសុំអនុញ្ញាតច្បាប់ពីមន្ត្រីអត្រានុកូលដ្ឋានដោយប្រាប់ពី ទីកន្លែង និងពេលវេលាដែលខ្លួនរៀបអាពាហ៍ពិពាហ៍នេះឱ្យបានច្បាស់ ។

ពេលរៀបអាពាហ៍ពិពាហ៍ ប្ដី ប្រពន្ធ អាចទៅសុំចុះសៀវភៅអាពាហ៍ពិពាហ៍នៅ ស្ថានទូត ស្ថានអគ្គកុងស៊ុល ឬស្ថានកុងស៊ុលនៃប្រទេសរបស់ខ្លួនប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ប្រសិនបើមាន ឬសុំចុះសៀវភៅអាពាហ៍ពិពាហ៍នៅមន្ត្រីអត្រានុកូលដ្ឋានតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជាក៏បាន ។

ការចុះឈ្មោះនៃជនជាតិបរទេស ត្រូវសរសេរជាអក្សរឡាតាំង អមជាមួយអក្សរខ្មែរផង ។

## ជំពូកទី ៦
## អំពីសំបុត្រមរណភាព

### មាត្រា ៣៥.-

ពេលមានអ្នកស្លាប់ភ្លាម ក្រុមគ្រួសារ ឬសាច់ញាតិសន្តាន ឬអ្នកជិតខាង ឬអ្នកមានភារកិច្ចនៅក្រសួង ស្ថាប័ន អង្គភាពរបស់អ្នកស្លាប់ ត្រូវរាយការណ៍ជូនដល់មន្ត្រីអត្រានុកូលដ្ឋានសាលាឃុំ ឬសង្កាត់ នៃទីកន្លែងរស់នៅជាប់លាប់ របស់អ្នកស្លាប់ ។

មន្ត្រីអត្រានុកូលដ្ឋាន ត្រូវធ្វើលិខិតអនុញ្ញាតឱ្យធ្វើបុណ្យបូជា ឬបញ្ចុះសព បើស្លាប់ដោយជម្ងឺធម្មតា ដោយចាស់ជរា ដោយគ្រោះថ្នាក់ធម្មជាតិ ឬដោយគ្រោះថ្នាក់ផ្សេងៗ ដែលមិនមានមន្ទិលសង្ស័យទាក់ទង ដល់អំពើឃាតកម្មនៃបទល្មើសឧក្រិដ្ឋណាមួយ ។

ការចុះសៀវភៅមរណភាព និងចេញសំបុត្រមរណភាព ត្រូវធ្វើក្នុងរយៈពេលយ៉ាងយូរបំផុត ១៥ថ្ងៃ ក្រោយពីថ្ងៃទទួលមរណភាព ។

បើអ្នកស្លាប់ដោយជម្ងឺឆ្លងរាតត្បាត អាចបណ្តាលឱ្យគ្រោះថ្នាក់ដល់សង្គម ត្រូវរាយការណ៍ទៅមន្ទីរពេទ្យ ឬផ្នែកអនាម័យភ្លាម ។ បើពេទ្យ ឬផ្នែកអនាម័យសម្រេចយ៉ាងណា មន្ត្រីអត្រានុកូលដ្ឋានត្រូវធ្វើលិខិតអនុញ្ញាតឱ្យធ្វើបុណ្យបូជា ឬបញ្ចុះ សពតាមការសម្រេចនោះ ។

### មាត្រា ៣៦.-

បើមានអ្នកស្លាប់ដោយមូលហេតុណាមួយ ដែលពាក់ព័ន្ធដល់ការមន្ទិលសង្ស័យ ដល់អំពើឃាតកម្មនៃបទល្មើសឧក្រិដ្ឋ មន្ត្រីអត្រានុកូលដ្ឋាន ឬជនទាំងឡាយណា ដែលមានការពាក់ព័ន្ធត្រូវរាយការណ៍ភ្លាមដល់អាជ្ញាធរមានសមត្ថកិច្ចនៅកន្លែងអ្នកនោះស្លាប់ ដើម្បីឱ្យសមត្ថកិច្ចជំនាញនានា ពិនិត្យស្រាវជ្រាវ និងដោះស្រាយរួសរាន់ ។ ក្រោយពីមានការសម្រេចយ៉ាង ណាពីភ្នាក់ងារមានមសមត្ថកិច្ច ទើបមន្ត្រីអត្រានុកូលដ្ឋានអនុញ្ញាតឱ្យធ្វើបុណ្យបូជា ឬបញ្ចុះសពបាន ។

### មាត្រា ៣៧.-

បើមានពលរដ្ឋខ្មែររស់នៅក្នុងឃុំ ឬសង្កាត់ណាមួយ បានទៅស្លាប់នៅឃុំ ឬសង្កាត់ផ្សេង មន្ត្រីអត្រានុកូលដ្ឋាននៃឃុំ ឬសង្កាត់ដែលមានអ្នកស្លាប់ ត្រូវជូនដំណឹងទៅមន្ត្រីអត្រានុកូលដ្ឋាននៃឃុំ ឬសង្កាត់របស់អ្នកស្លាប់រស់នៅដើម្បីជូនដំណឹងដល់ក្រុមគ្រួសារនៃអ្នកស្លាប់ ឱ្យទៅយកសពធ្វើបុណ្យ និងចុះសៀវភៅមរណភាពនៅឃុំ ឬសង្កាត់នៃអ្នកស្លាប់នោះស្នាក់នៅជាប់លាប់ ។

បើអ្នកស្លាប់គ្មានក្រុមគ្រួសារ ឬគ្មានអ្នកស្គាល់ទេ មន្ត្រីអត្រានុកូលដ្ឋាននៃឃុំ ឬសង្កាត់ដែលមានអ្នកស្លាប់ត្រូវចាត់

ថែងបូជា ឬបញ្ចុះសពនោះ និងចុះសៀវភៅមរណភាពក្នុងឃុំ ឬសង្កាត់នោះ ។

**មាត្រា ៣៨.-**

បើមានអ្នកទោសណាម្នាក់ស្លាប់ក្នុងពន្ធនាគារ អ្នកទទួលខុសត្រូវនៃពន្ធនាគារនោះ ត្រូវធ្វើសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរទៅស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ និងទៅមន្ត្រីអត្រានុកូលដ្ឋាននៃលំនៅអចិន្ត្រៃយ៍របស់អ្នកទោសនោះដើម្បីមន្ត្រីអត្រានុកូលដ្ឋានចុះក្នុងសៀវភៅមរណភាព ។

**មាត្រា ៣៩.-**

ពេលមានអ្នករាយការណ៍អំពីមរណភាព មន្ត្រីអត្រានុកូលដ្ឋានត្រូវចុះសៀវភៅមរណភាព រួចប្រគល់ឱ្យអ្នកសុំនូវសំបុត្រមរណភាពច្បាប់ដើម ០១សន្លឹក និងចេញសេចក្តីចម្លងតាមការស្នើសុំរបស់សាមីខ្លួន ។

**មាត្រា ៤០.-**

បើមានអ្នកស្លាប់ទុកហួសរយៈពេល ១៥ថ្ងៃ ពុំបានទៅរាយការណ៍ចុះសៀវភៅមរណភាពទេ ក្រុមគ្រួសារ នៃអ្នកស្លាប់ ត្រូវទៅសុំសាលក្រមពីតុលាការខេត្ត-ក្រុងសាមី រួចយកសាលក្រមតុលាការនោះ មកសុំមន្ត្រីអត្រានុកូលដ្ឋានឃុំ ឬសង្កាត់ នៃអ្នកស្លាប់ ដើម្បីចុះសៀវភៅមរណភាព ។

**មាត្រា ៤១.-**

បើមានពលរដ្ឋខ្មែររស់នៅស្របច្បាប់ឯបរទេសបានស្លាប់ ក្រុមគ្រួសារ ឬសាច់ញាតិសន្តាន ឬអ្នកជិតខាង ឬអ្នកដែលបានឃើញអ្នកស្លាប់នោះផ្ទាល់ អាចទៅចុះសៀវភៅមរណភាពនៅប្រទេសនោះ តាមច្បាប់របស់ប្រទេសនោះ ។ ពេលត្រឡប់មកព្រះរាជាណាចក្រកម្ពុជាវិញ ត្រូវយកសំបុត្រមរណភាពដែលធ្វើនៅបរទេសនោះទៅចុះសៀវភៅនៅ ឃុំ ឬសង្កាត់ដែលសាមីខ្លួនអ្នកស្លាប់ ធ្លាប់ស្នាក់នៅជាប់លាប់មុនពេលចេញទៅបរទេស ។

មន្ត្រីអត្រានុកូលដ្ឋាន ត្រូវដកយកសំបុត្រមរណភាពថតចម្លងជាផ្លូវការទុកជាឯកសារ ហើយចម្លងចេញពីសៀវភៅមរណភាពនូវសំបុត្រមរណភាពថ្មី ប្រគល់ឱ្យសាមីខ្លួនអ្នកសុំយកទៅប្រើប្រាស់ ។

បើបានទៅរាយការណ៍ចុះសៀវភៅមរណភាពនៅ ស្ថានទូត ស្ថានអគ្គកុងស៊ុល ឬស្ថានកុងស៊ុល នៃព្រះរាជណាចក្រកម្ពុជាប្រចាំនៅប្រទេសនោះ រួចហើយពេលត្រឡប់មកប្រទេសកម្ពុជាវិញអាចយកសំបុត្រមរណភាពនោះមកប្រើប្រាស់ជាផ្លូវការបាន ។

**មាត្រា ៤២.-**

ជនអន្តោប្រវេសន៍ និងជនបរទេសរស់នៅស្របច្បាប់លើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានស្លាប់នៅ លើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ក្រុមគ្រួសារសាច់ញាតិ ឬអ្នកទទួលខុសត្រូវ អាចទៅចុះសៀវភៅមរណភាពនៅសាលាឃុំ ឬសង្កាត់ ដែលអ្នកស្លាប់ធ្លាប់រស់នៅជាប់លាប់ មុនពេលខ្លួនស្លាប់ ឬអាចទៅចុះសៀវភៅមរណភាព នៅស្ថានទូត ស្ថានអគ្គកុងស៊ុល ឬស្ថានកុងស៊ុលនៃប្រទេសរបស់អ្នកស្លាប់ ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ប្រសិនបើមាន ។

បើចុះសៀវភៅមរណភាពនៅឃុំ ឬសង្កាត់ ការចុះឈ្មោះជនជាតិបរទេស ត្រូវសរសេរជាអក្សរឡាតាំង អមជាមួយអក្សរខ្មែរផង ។

## ជំពូកទី ៧
## អំពីសំបុត្របញ្ជាក់កំណើត

### មាត្រា ៤៣.-

ពលរដ្ឋខ្មែរដែលបានកើតមុនពេលមានអនុក្រឹត្យ ស្ដីពីអត្រានុកូលដ្ឋានថ្មីនេះ ចូលជាធរមាន ហើយគ្មានសំបុត្រកំនើតប្រើប្រាស់ អាចសុំចុះសៀវភៅបញ្ជាក់សំបុត្រកំណើតបាន តាមគំរូណែនាំថ្មី នៅសាលាឃុំ ឬសង្កាត់ ដែលខ្លួនរស់នៅជាប់លាប់បច្ចុប្បន្ន ដោយមានសាក្សីចំនួន ០២រូប ជានីតិជន និងជាមនុស្សគួរឱ្យជឿទុកចិត្តបាន ដែលបានស្គាល់ច្បាស់ពីប្រវត្តិអ្នកត្រូវសុំធ្វើសំបុត្របញ្ជាក់កំណើត និងធ្លាប់រស់នៅក្នុងភូមិ ឃុំ ឬសង្កាត់ជាមួយ ពីពេលដែលសាមីខ្លួនកើតនាំមកបញ្ជាក់នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ។

ចំពោះមន្ត្រីរាជការដែលបានទទួលបៀវត្ស ឬទទួលសោធននិវត្តន៍ ត្រូវយកឯកសារបៀវត្ស ឬសោធននិវត្តន៍ ឬសេចក្ដីបញ្ជាក់ពីស្ថាប័នសាមី ដើម្បីសុំសំបុត្របញ្ជាក់កំណើត ហើយថ្ងៃ ខែ ឆ្នាំកំណើត ដែលចុះនៅក្នុងសៀវភៅបញ្ជាក់កំណើតមិនត្រូវឱ្យខុសពីថ្ងៃ ខែ ឆ្នាំកំណើត ដែលមាននៅក្នុងឯកសារបៀវត្ស ឬសោធននិវត្តន៍ជាផ្លូវការឡើយ ។

### មាត្រា ៤៤.-

ពេលមានអ្នកមកសុំចុះសៀវភៅកំនើត មន្ត្រីអត្រានុកូលដ្ឋានត្រូវចុះសៀវភៅបញ្ជាក់កំណើត រួចត្រូវប្រគល់អោយសាមីខ្លួន ឬក្រុមគ្រួសារនូវសំបុត្របញ្ជាក់កំណើតច្បាប់ដើម ០១សន្លឹក និងចេញសេចក្ដីចម្លងតាមការស្នើសុំរបស់សាមីខ្លួន ដោយមានហត្ថលេខារបស់មន្ត្រីអត្រានុកូលដ្ឋានឃុំ ឬសង្កាត់ ។

## ជំពូកទី ៨
## អំពីសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍

### មាត្រា ៤៥.-

ពលរដ្ឋខ្មែរដែលបានគ្នាជាប្ដី ឬប្រពន្ធ ពិតប្រាកដ នៅមុនពេលមានអនុក្រឹត្យស្ដីពីអត្រានុកូលដ្ឋានថ្មីនេះចូលជាធរមាន ហើយគ្មានសំបុត្រអាពាហ៍ពិពាហ៍ប្រើប្រាស់ សាមីខ្លួនប្ដី ប្រពន្ធអាចមកសុំចុះសៀវភៅបញ្ជាក់អាពាហ៍ពិពាហ៍បានតាមគំរូណែនាំថ្មីនៅសាលាឃុំ ឬសង្កាត់ដែលខ្លួនរស់នៅជាប់លាប់បច្ចុប្បន្ន ដោយមានសាក្សីចំនួន ០២រូប ជានីតិជន និងជាមនុស្សគួរឱ្យជឿទុកចិត្តបាន ដែលបានដឹងឮផ្ទាល់ពីសាមីខ្លួនប្ដី ប្រពន្ធនោះ និងធ្លាប់រស់នៅក្នុងភូមិ ឃុំ ឬសង្កាត់ជាមួយគ្នានាំមកបញ្ជាក់នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ។

### មាត្រា ៤៦.-

ពេលមានសាមីខ្លួនប្ដី និងប្រពន្ធមកសុំចុះសៀវភៅបញ្ជាក់អាពាហ៍ពិពាហ៍ មន្ត្រីអត្រានុកូលដ្ឋានត្រូវចុះសៀវភៅបញ្ជាក់អាពាហ៍ពិពាហ៍ រួចហើយត្រូវប្រគល់ឱ្យសាមីខ្លួនប្ដី ប្រពន្ធនូវសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ច្បាប់ដើម ០១សន្លឹក និង ចេញសេចក្ដីចម្លងតាមការស្នើសុំរបស់សាមីខ្លួន ដោយមានហត្ថលេខារបស់មន្ត្រីអត្រានុកូលដ្ឋានឃុំ ឬសង្កាត់ ។

## ជំពូកទី ៩
## អំពីសំបុត្របញ្ជាក់មរណភាព

### មាត្រា ៤៧.-

ពលរដ្ឋខ្មែរ ដែលស្លាប់មុនពេលអនុក្រឹត្យស្តីពី អត្រានុកូលដ្ឋានថ្មីនេះ ចូលជាធរមាន ហើយគ្មានសំបុត្រមរណភាព សាច់ញាតិសន្តានដែលនៅរស់ អាចមកសុំចុះសៀវភៅបញ្ជាក់មរណភាពតាមគំរូណែនាំថ្មីនៅសាលាឃុំ ឬសង្កាត់ដែលញាតិសន្តានរស់នៅជាប់លាប់បច្ចុប្បន្នបាន ដោយនាំសាក្សីចំនួន ០២រូប ជានីតិជន និងជាមនុស្សគួរឱ្យជឿទុកចិត្តបាន ដែលបានដឹងឮផ្ទាល់អំពីការស្លាប់ និងធ្លាប់រស់នៅក្នុងភូមិ ឃុំ ឬ សង្កាត់ជាមួយអ្នកស្លាប់ មកបញ្ជាក់នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ។

### មាត្រា ៤៨.-

ពេលមានអ្នកមកសុំចុះសៀវភៅបញ្ជាក់មរណភាព មន្ត្រីអត្រានុកូលដ្ឋានត្រូវចុះសៀវភៅបញ្ជាក់មរណភាព រួចត្រូវប្រគល់ឱ្យអ្នកសុំនូវសំបុត្របញ្ជាក់មរណភាពច្បាប់ដើម ០១សន្លឹក និងចេញសេចក្តីចម្លងតាមការស្នើសុំ ដោយមានហត្ថលេខារបស់មន្ត្រីអត្រានុកូលដ្ឋានឃុំ ឬសង្កាត់ ។

## ជំពូកទី ១០
## អំពីសេចក្តីចម្លង ឬសម្រង់អត្រានុកូលដ្ឋាន

### មាត្រា ៤៩.-

សេចក្តីចម្លង ឬសម្រង់អត្រានុកូលដ្ឋានមាន សេចក្តីចម្លង ឬសម្រង់សំបុត្រកំណើត សេចក្តីចម្លង ឬសម្រង់សំបុត្រអាពាហ៍ពិពាហ៍ សេចក្តីចម្លង ឬសម្រង់សំបុត្រមរណភាព សេចក្តីចម្លង ឬសម្រង់សំបុត្របញ្ជាក់កំណើត សេចក្តីចម្លង ឬសម្រង់សំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ និងសេចក្តីចម្លង ឬសម្រង់សំបុត្របញ្ជាក់មរណភាព ។

រាល់ខ្លឹមសារនៃសេចក្តីចម្លង ត្រូវអនុវត្តដូចគ្នា នឹងខ្លឹមសារក្នុងសំបុត្រអត្រានុកូលដ្ឋានដើម ។ សម្រង់អត្រានុកូលដ្ឋាន ត្រូវធ្វើតាមសំណើរបស់អ្នកសុំដោយដកស្រង់នូវខ្លឹមសារសំខាន់ៗ ចេញពីសៀវភៅអត្រានុកូលដ្ឋាន ។

### មាត្រា ៥០.-

បើមានអ្នកមកសុំចម្លង ឬសុំស្រង់សំបុត្រអត្រានុកូលដ្ឋានពីមន្ត្រីអត្រានុកូលដ្ឋាន អ្នកសុំត្រូវមានសំបុត្រអត្រានុកូលដ្ឋានច្បាប់ដើមយកមកជាមួយ តែការចម្លង ឬសម្រង់ត្រូវស្រង់ចេញពីសៀវភៅដែលតម្កល់ទុក ។ ក្នុងករណីបាត់សំបុត្រអត្រានុកូលដ្ឋានច្បាប់ដើម មន្ត្រីអត្រានុកូលដ្ឋានត្រូវចម្លងតាមសៀវភៅអត្រានុកូលដ្ឋាន ដែលបានចុះពីមុនមក និងកំពុងថែរក្សា ក្នុងឆ្នាំដែលមិនទាន់ដាច់ នៅសាលាឃុំ ឬសង្កាត់ ។ ក្នុងករណីសៀវភៅអត្រានុកូលដ្ឋានបានវិនាសដោយមានកំណត់ហេតុត្រឹមត្រូវ ហើយមានសេចក្តីណែនាំពីអន្តរក្រសួង ក្រសួងមហាផ្ទៃ និងក្រសួងយុត្តិធម៌ទើបធ្វើការចម្លង ឬសម្រង់ចេញពី សន្លឹកអត្រានុកូលដ្ឋាន ដែលសាមីខ្លួនអ្នកសុំមាន ហើយយកទៅប្រើការបាន ។

**មាត្រា ៥១.-**

ការសុំចម្លង ឬសម្រង់សំបុត្រអត្រានុកូលដ្ឋានក្នុងឆ្នាំមិនទាន់ដាច់ ត្រូវសុំចម្លង ឬសុំស្រង់នៅសាលាឃុំ ឬសាលាសង្កាត់ ចុះហត្ថលេខាដោយមន្ត្រីអត្រានុកូលដ្ឋាន ឃុំ ឬសង្កាត់ ហើយត្រូវបញ្ជាក់ហត្ថលេខានោះ ដោយអភិបាលស្រុក ឬខណ្ឌ និងបោះត្រាផង ។

**មាត្រា ៥២.-**

ការសុំចម្លង ឬសម្រង់សំបុត្រអត្រានុកូលដ្ឋានឆ្នាំដែលកន្លងផុតទៅ ត្រូវទៅសុំចម្លង ឬសុំស្រង់នៅសាលាស្រុក ឬខណ្ឌ ឬនៅតុលាការខេត្ត ក្រុងសាមី ។

ការសុំចម្លង ឬសម្រង់នៅសាលាស្រុក ឬសាលាខណ្ឌ ត្រូវចុះហត្ថលេខាដោយមន្ត្រីរក្សាសៀវភៅអត្រានុកូលដ្ឋាន និងត្រូវបញ្ជាក់ហត្ថលេខានោះ ដោយអភិបាលស្រុក ឬខណ្ឌ និងបោះត្រាផង ។

ការសុំចម្លង ឬសម្រង់នៅតុលាការខេត្ត ក្រុង ត្រូវចុះហត្ថលេខាដោយក្រឡាបញ្ជី និងត្រូវបញ្ជាក់ហត្ថលេខានោះដោយប្រធានតុលាការ ឬចៅក្រមជំនួស និងបោះត្រាផង ។

**មាត្រា ៥៣.-**

ពលរដ្ឋខ្មែររស់នៅស្របច្បាប់ឯបរទេស ដែលបានចុះសៀវភៅអត្រានុកូលដ្ឋាននៅ ស្ថានទូត ស្ថានអគ្គកុងស៊ុល ឬស្ថានកុងស៊ុល នៃព្រះរាជាណាចក្រកម្ពុជាប្រចាំនៅប្រទេសនោះ ការសុំចម្លង ឬសម្រង់អត្រានុកូលដ្ឋានក្នុងឆ្នាំមិនទាន់ដាច់ ត្រូវសុំចម្លង ឬសុំស្រង់នៅស្ថានទូត ស្ថានអគ្គកុងស៊ុល ឬស្ថានកុងស៊ុលនោះ ចុះហត្ថលេខាដោយមន្ត្រីអត្រានុកូលដ្ឋាននៅទីនោះ ហើយត្រូវបញ្ជាក់ហត្ថលេខានោះ ដោយឯកអគ្គរាជទូត អគ្គកុងស៊ុល ឬកុងស៊ុល និងបោះត្រាផង ។

ការសុំចម្លង ឬសម្រង់អត្រានុកូលដ្ឋានឆ្នាំដែលកន្លងផុតទៅ ត្រូវសុំចម្លង ឬសុំស្រង់នៅក្រសួងមហាផ្ទៃ ឬនៅក្រសួងយុត្តិធម៌ ដែលមានសៀវភៅអត្រានុកូលដ្ឋានឆ្នាំចាស់ តម្កល់ទុកនៅទីនោះ ។

## ជំពូកទី ១១
## អំពីការទទួលខុសត្រូវចំពោះមុខច្បាប់
## ស្ដីពីការខារអត្រានុកូលដ្ឋាន

**មាត្រា ៥៤.-**

សាមីខ្លួន និង ឬអ្នករាយការណ៍ និង ឬសាក្សី ត្រូវសំដែងនូវការស្មោះត្រង់ ចំពោះការបញ្ជាក់អះអាងរបស់ខ្លួនអំពីហេតុការណ៍ដែលកើតមានឡើង ហើយដែលខ្លួនបានដឹងឮ ឬឃើញផ្ទាល់នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ស្ដីពីអត្រានុកូលដ្ឋានតាមប្រភេទ ។

**មាត្រា ៥៥.-**

មន្ត្រីអត្រានុកូលដ្ឋាន ត្រូវស្មោះត្រង់ក្នុងការធ្វើអត្រានុកូលដ្ឋានជូនប្រជាពលរដ្ឋ ។ បើមានមន្ត្រីអត្រានុកូលដ្ឋានណាម្នាក់មានការឃុបឃិត ឬក្លែងបន្លំដោយចេតនា ក្នុងការធ្វើសំបុត្រអត្រានុកូលដ្ឋាន ត្រូវទទួលទោសតាមបញ្ញត្តិច្បាប់ ។

សំបុត្រអត្រានុកូលដ្ឋានក្លែងបន្លំដែលបានចេញរួចហើយ ត្រូវប្រមូលយកមកវិញ និងប្តឹងទៅតុលាការ ដើម្បីបដិសេធ និងសុំផ្តន្ទាទោសតាមច្បាប់ ។

## ជំពូកទី១២
## អំពីថវិកាអត្រានុកូលដ្ឋាន

**មាត្រា ៥៦.-**

ការបោះពុម្ពសៀវភៅ សំបុត្រអត្រានុកូលដ្ឋាន និងការបណ្តុះបណ្តាល អំពីការងារអត្រានុកូលដ្ឋានដល់មន្ត្រីអត្រានុកូលដ្ឋានទូទាំងប្រទេសត្រូវស្ថិតនៅក្នុងបន្ទុកថវិការដ្ឋ ។

**មាត្រា ៥៧.-**

ក្រសួងមហាផ្ទៃត្រូវលើកគម្រោងថវិកាប្រចាំឆ្នាំ សម្រាប់ការសុំបោះពុម្ពសៀវភៅ សំបុត្រអត្រានុកូលដ្ឋាន និងការបណ្តុះបណ្តាលការងារអត្រានុកូលដ្ឋាន ។

**មាត្រា ៥៨.-**

ការសុំចុះសំបុត្រអត្រានុកូលដ្ឋាន កំណើត និងមរណភាព អ្នកមកសុំមិនតម្រូវឱ្យបង់ថ្លៃអ្វីឡើយ ។

ការសុំច្បាប់រៀបអាពាហ៍ពិពាហ៍ និងការចុះសំបុត្រអត្រានុកូលដ្ឋាន អាពាហ៍ពិពាហ៍ ការសុំបញ្ជាក់កំណើត បញ្ជាក់អាពាហ៍ពិពាហ៍ និងបញ្ជាក់មរណភាព អ្នកសុំត្រូវបង់ថ្លៃក្រដាសតាមការកំណត់ ។

រាល់ការសុំចម្លង ឬសម្រង់សំបុត្រអត្រានុកូលដ្ឋានអ្នកមកសុំត្រូវបង់ថ្លៃក្រដាស និងថ្លៃបិទតែមប្រិ៍ ដើម្បីជាប្រយោជន៍សម្រាប់ ឃុំ ឬសង្កាត់ និងចំណូលថវិការដ្ឋ ។

ថ្លៃក្រដាសអត្រានុកូលដ្ឋាន និងថ្លៃតែមប្រិ៍ត្រូវកំណត់ដោយអនុក្រឹត្យ តាមសេចក្តីស្នើសុំរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

## ជំពូកទី ១៣
## អន្តរប្បញ្ញត្តិ

**មាត្រា ៥៩.-**

ការសុំបញ្ជាក់អត្រានុកូលដ្ឋានមានចុះសៀវភៅបញ្ជាក់កំណើត សៀវភៅបញ្ជាក់អាពាហ៍ពិពាហ៍ សៀវភៅបញ្ជាក់មរណភាព ត្រូវបានអនុវត្តចំពោះតែលើពលរដ្ឋខ្មែរ ហើយអនុវត្តតែក្នុងរយៈពេល ៣ឆ្នាំ ចាប់ពីថ្ងៃដែលអនុក្រឹត្យនេះចូលជាធរមាន ។ ផុតរយៈពេលនេះ ពលរដ្ឋខ្មែរដែលគ្មានសំបុត្រអត្រានុកូលដ្ឋាន កំណើត និងមរណភាព ត្រូវទៅសុំសាលក្រមពីតុលាការខេត្ត ក្រុងសាមី រួចយកសាលក្រមតុលាការនោះ មកសុំមន្ត្រីអត្រានុកូលដ្ឋានឃុំ ឬសង្កាត់ដើម្បីចុះសៀវភៅអត្រានុកូលដ្ឋាន ។ ឯការបញ្ជាក់អត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍អនុញ្ញាតឱ្យប្តីឯសុំចុះតាមការស្ម័គ្រចិត្តនៃសហព័ទ្ធ ។

**មាត្រា ៦០.-**

ហាមយកសំបុត្រអត្រានុកូលដ្ឋានរបស់ជនណាម្នាក់ ទៅប្រើប្រាស់ធ្វើជាសំបុត្រអត្រានុកូលដ្ឋានផ្ទាល់ខ្លួនរបស់ជន

ណាម្នាក់ផ្សេងទៀត ។

**មាត្រា ៦១.-**

រាល់សំបុត្រអត្រានុកូលដ្ឋានច្បាប់ចាស់ ដែលមានស្រាប់ពីសង្គមមុនៗ និងអត្រានុកូលដ្ឋានក្រោយឆ្នាំ ១៩៧៨ហើយ រក្សាទុករហូតដល់បច្ចុប្បន្ន សាមីខ្លួនត្រូវយកមកបង្ហាញមន្ត្រីអត្រានុកូលដ្ឋានបច្ចុប្បន្ន ដើម្បីចុះក្នុងសៀវភៅអត្រានុកូលដ្ឋានតាមគំរូថ្មី សម្រាប់ប្រើប្រាស់ទៅថ្ងៃក្រោយ ។

**មាត្រា ៦២.-**

ក្នុងករណីដែលពិនិត្យឃើញសំបុត្រអត្រានុកូលដ្ឋានចាស់ពីមុនណាមួយ ដែលមានលក្ខណៈពុំត្រឹមត្រូវ មន្ត្រីអត្រានុកូលដ្ឋានត្រូវប្រមូលសំបុត្រអត្រានុកូលដ្ឋាននោះមកវិញ រួចណែនាំឱ្យសាមីជនបំពេញបែបបទសុំអត្រានុកូលដ្ឋានថ្មី ។

**មាត្រា ៦៣.-**

ហាមមនុស្សម្នាក់ចុះសៀវភៅអត្រានុកូលដ្ឋានក្នុងប្រភេទនីមួយៗ លើសពី ០១ដង និងនៅច្រើនកន្លែងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

## ជំពូកទី ១៤

## អំពីទោសប្បញ្ញត្តិ

**មាត្រា ៦៤.-**

ជនណារាយការណ៍មិនពិត អំពីអត្រានុកូលដ្ឋានចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ឬយកអត្រានុកូលដ្ឋានរបស់អ្នកដទៃទៅប្រើប្រាស់ជារបស់ខ្លួន ឬរាយការណ៍សុំចុះអត្រានុកូលដ្ឋានលើសពី ០១ដង នៅទីកន្លែងដដែល ឬទីកន្លែងផ្សេងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬប្រើប្រាស់អត្រានុកូលដ្ឋានក្លែង ត្រូវពិន័យ និងត្រូវទទួលទោសតាមបញ្ញត្តិច្បាប់ ។

**មាត្រា ៦៥.-**

មន្ត្រីអត្រានុកូលដ្ឋានណា សមគំនិត ឃុបឃិត ក្លែងបន្លំ ចុះសៀវភៅអត្រានុកូលដ្ឋានឱ្យប្រជាពលរដ្ឋ ដែលមកសុំ ឬបានទារប្រាក់លើសច្បាប់កំណត់ពីប្រជាពលរដ្ឋសម្រាប់ការងារអត្រានុកូលដ្ឋាន ត្រូវពិន័យជាប្រាក់ និងត្រូវទទួលទោសតាមបញ្ញត្តិច្បាប់ ។

## ជំពូកទី ១៥

## អវសានប្បញ្ញត្តិ

**មាត្រា ៦៦.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៦៧.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង គ្រប់រដ្ឋលេខាធិការដ្ឋាន ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

ធ្វើនៅរាជធានីភ្នំពេញ. ថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០០

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា និងត្រា**

**ហ៊ុន សែន**

បានយកសេចក្តីជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

ដើម្បីចុះហត្ថលេខា

សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

| | | |
|---|---|---|
| ហត្ថលេខា | ហត្ថលេខា | ហត្ថលេខា |
| **ស ខេង** | **យូ ហុកគ្រី** | **អ៊ុក វិធុន** |

**ចម្លងជូន**

-ខុទ្ទកាល័យព្រះមហាក្សត្រ

-អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋាន រដ្ឋសភា

-ខុទ្ទកាល័យនាយករដ្ឋមន្ត្រី

-ដូចមាត្រា ៦៧

-កាលប្បវត្តិ-ឯកសារ